

# មហោស្រពលពណ៌

យុវជននិងការចូលរួមរបស់ពលរដ្ឋក្នុងវិស័យសិល្បៈ



**របាយការណ៍ស្រាវជ្រាវ**
អាម៉ាន់ដា រ៉ូជើស៍ និង សាយ តុលា
សាកលវិទ្យាល័យ Swansea ខែកក្កដា ឆ្នាំ ២០២៤

© អ្នកនិពន្ធឆ្នាំ ២០២៤។ អត្ថបទទាំងអស់គឺស្ថិតក្រោមអាជ្ញាប័ណ្ណ
Creative Com-mons Attribution-NonCommerical International 4.0
(CC-BY-NC 4.0)

https://creativecommons.org/licenses/by-nc/4.0/

**សម្រង់ព័ត៏មាន**
Rogers, A. and Say, T. (2024) មហោស្រពប្រាំពីរពណ៌ :
យុវជន និងការចូលរួមរបស់ពលរដ្ឋក្នុងវិស័យសិល្បៈ, សាកលវិទ្យាល័យ
Swansea

DOI: http://dx.doi.org/10.23889/SUreport.66346

**ប្រភពរូបភាព**
កញ្ញា សួល ណារី (អ្នកសម្របសម្រួលផ្នែកទំនាក់ទំនង និងផ្សព្វផ្សាយ)
លោក ថន ដីកា (អ្នកថត និងកាត់តវីដេអូ)
លោកស្រីបណ្ឌិត អាម៉ាន់ដា រ៉ូជើស៍
*រូបភាពទាំងអស់គឺជាកម្មវត្ថុនៃការរក្សាសិទ្ធដាច់ដោយឡែក។ រូបភាពទាំងអស់ត្រូវបានរក្សាសិទ្ធិ។*

**ការរចនា**
ចូអ៊ែល អេវ៉ៃនេស៍

# មហោស្រព៧ពណ៌

## យុវជននិងការចូលរួមរបស់ពលរដ្ឋក្នុងវិស័យសិល្បៈ

របាយការណ៍គម្រោង

---

អាម៉ាន់ដា និង សាយ តុលា

CAMBODIAN LIVING ARTS
Swansea University Prifysgol Abertawe
ស៊ុយអែត Sverige

# មាតិកា

*មហោស្រពពពលណ៍*


**សង្ខេប**
ទំ.៦-៩

- សារតារ
- សំណួរ
- សង្ខេបអំពីអនុសាសន៍

**វិធីសាស្ត្រ**
ទំ.១០-១១

**ការចូលរួមរបស់ពលរដ្ឋ**
ទំ.១២-១៣

**ការរកឃើញនៅក្នុងការស្រាវជ្រាវ (១,២,៣,៤,៥)**
ទំ.១៤-៧១

**សេចក្តីសង្ខេបអំពីការរកឃើញនិងអនុសាសន៍**
ទំ.៧២-៧៩

**០១** ទំ.១៤-២៣

ការស្វែងយល់ពីការចូលរួមរបស់យុវជន

**០២** ទំ.២៤-៣៩

ប្រភពដើម និងអត្ថន័យរបស់មហោស្រពពលណ៍

- ការបង្កើតកម្មវិធី
- កម្មវិធីមហោស្រព

**០៣** ទំ.៤០-៤៩

ការរចនាកម្មវិធីមហោស្រព

- ការស្វែងយល់អំពីសិល្បៈ
- ជំនាញសម្រាប់ការចូលរួមរបស់ពលរដ្ឋ

**០៤** ទំ.៥០-៦៣

ការចូលរួមក្នុងមហោស្រពពលណ៍

- ការផ្សព្វផ្សាយអំពីមហោស្រព
- ក្រុមអ្នកស្ម័គ្រចិត្ត
- ភាពចម្រុះនិងសមភាពនៃការចូលរួម

**០៥** ទំ.៦៤-៧១

ឥទ្ធិពលនៃការចូលរួមក្នុងមហោស្រពនេះចំពោះទស្សនិកជន

- បរិមាណនិងគុណភាពនៃការចូលរួម
- ការស្វែងយល់អំពីសិល្បៈ
- ការបង្កើតបណ្តាញនិងសហគមន៍ពីនានាភាព

# សេចក្តីសង្ខេប

## សារតារ

ផ្អែកតាមការស្រាវជ្រាវមុន (Roger et al 2021) យើងកត់សម្គាល់ឃើញថា ការគិតរបស់សិល្បករ និងការនឹកស្រមៃរបស់យុវជនអំពីទំនាក់ទំនងរបស់សិល្បៈទៅនឹងសង្គមគឺខុសគ្នា។ យុវជនចង់ឃើញ (និងផ្សាភ្ជាប់ខ្លាំងទៅនឹង) ស្នាដៃសិល្បៈដែលលើកឡើងអំពីបញ្ហាសង្គមសំខាន់ៗនៅកម្ពុជា ដែលភាគច្រើនជាបញ្ហានយោបាយក្នុងនោះមានការប្រែប្រួលអាកាសធាតុ ការបង្ហាញពីសិទ្ធិមនុស្សនិងអត្តសញ្ញាណ (ឧ.អត្តសញ្ញាណនៃសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា) អំពើ ឆបោក និងលទ្ធិប្រជាធិបតេយ្យជាដើម។ ប៉ុន្តែចំពោះសិល្បករជាពិសេសក្នុងទម្រង់សិល្បៈទស្សនីយភាពនិងតន្ត្រី ការបង្កើតស្នាដៃដែលលើកឡើងពីបញ្ហាទាំងនេះគឺដូចដើរលើខ្សែពួរដូច្នេះដែរ ជាពិសេសមានការ ត្រួតពិនិត្យរឹតត្បិតច្រើនតែកើតឡើងនៅក្នុងវិស័យតន្ត្រី (Brennert and Yean 2023)។ ចំណុចនេះនាំឱ្យមានការចោទជាសំណួរពីរបៀបដែលសិល្បៈអាចផ្សាភ្ជាប់នឹងសង្គម ហើយនឹងលទ្ធភាពនិងដែនកំណត់នៃទំនាក់ទំនងនេះ។ ការស្រាវជ្រាវនេះជាការបន្តពីការរកឃើញដំបូងរបស់យើងដែលផ្តោតលើយុវជនដែលមិនសូវមាន បទពិសោធន៍ក្នុងវិស័យសិល្បៈ។ យើងនឹងពិចារណាថាតើ សិល្បៈអាចជាទម្រង់មួយនៃការចូលរួមរបស់ពលរដ្ឋសម្រាប់យុវវ័យយ៉ាងដូចម្តេច ហើយថាតើវាមានលក្ខណៈដូចម្តេចដែរនៅកម្ពុជា។ ដើម្បីធ្វើដូច្នេះបាន យើងតាមដានដំណើររបស់យុវជនហាត់ការ៤រូបនៅក្នុងការ បង្កើតមហោស្រពយុវវ័យ (មហោស្រព៧ពណ៏) អំឡុងឆ្នាំ២០២៣ សម្រាប់អង្គការសិល្បៈខ្មែរអមតៈ។ យើងពិនិត្យមើលការចូលរួមរបស់ពួកគេនៅក្នុងការបង្កើតព្រឹត្តិការណ៍ ថាតើពួកគេផ្សាភ្ជាប់មហោស្រពនេះទៅនឹងកង្វល់សង្គមរបស់យុវជនដូចម្តេច និងវាយតម្លៃថាតើយុវជនចូលរួមយ៉ាងណាដែរនៅក្នុងមហោស្រពនេះ។



## សំណួរ

- ប្រសិនបើយុវជនទទួលបានឱកាសដឹកនាំការផលិត ឬបង្កើតព្រឹត្តិការណ៍សិល្បៈ តើពួកគេនឹងបង្កើតអ្វី?
- តើការណ៍នេះអាចប្រាប់យើងអ្វីខ្លះអំពីទំនាក់ទំនងរបស់យុវជនជាមួយសិល្បៈ ហើយតើពួកគេមើលឃើញយ៉ាងដូចម្តេចអំពីទំនាក់ទំនងពួកគេជាមួយសង្គម?
- តើសិល្បៈអាចជំរុញការចូលរួមកាន់តែប្រសើរនៅក្នុងមជ្ឈដ្ឋានសង្គម ឬស៊ីវិលដោយរបៀបណា?

# សង្ខេបអំពីអនុសាសន៍

- មហោស្រពនេះបានក្លាយជាព្រឹត្តិការណ៍កាន់តែធំមួយ ប្រហែលធំជាងការស្រមៃឬអាចគ្រប់គ្រង បានទៅទៀត ។អាចមានការពិចារណាបន្ថែមទៀតចំពោះការបង្កើតព្រឹត្តិការណ៍ប្រភេទនេះ និង ជំហានដែលត្រូវការដើម្បីជួយសម្រួលដល់ការចូលរួមរបស់ក្រុមអ្នកហាត់ការ។

- ការរំពឹងទុកច្បាស់លាស់អំពីលទ្ធផលដែលចង់បាននិងប្រភេទនៃការចូលរួមដែលចង់ឱ្យមាន នឹងជួយបង្កើតរចនាសម្ព័ន្ធដំណើរការរួមនិងបង្កើត «ភាពជាម្ចាស់ការ» ពីមនុស្សគ្រប់គ្នា។ សូចនាករកាន់តែប្រសើរដើម្បីបញ្ជាក់ចំណុចអ្វីខ្លះថាជោគជ័យនឹងជួយពង្រឹងការផ្តោតនៃកម្មវិធីនិងការវាយតម្លៃកម្រិតជោគជ័យនៃព្រឹត្តិការណ៍ ឧទាហរណ៍ តើការចូលរួមដោយជោគជ័យផ្អែកលើចំនួនទស្សនិកជន ឬជម្រៅនិងភាពលម្អិតនៃចំណេះដឹងដែលទស្សនិកជនទទួលបាន? តើការចូលរួមដោយជោគជ័យមានលក្ខណៈដូចម្តេចចំពោះក្រុមផ្សេងទៀត (ពោលគឺ ក្រុមអ្នកហាត់ការ ក្រុមអ្នកស្ម័គ្រចិត្ត ក្រុមបុគ្គលិកអង្គការសិល្បៈខ្មែរអមតៈ និងក្រុមទស្សនិកជន)?

- សមាសភាពនៃក្រុមហាត់ការ តម្រូវឱ្យមានការពិចារណាបន្ថែមទៀត ជាពិសេសការរក្សានៅត្រឹមកម្រិតទីក្រុងដើម្បីបង្កលក្ខណៈឱ្យមានការចូលរួមកាន់តែប្រសើរ។ ទោះជាយ៉ាងណា ក៏មិនគួរមើលរំលងបណ្តាខេត្តនោះទេ។ ប្រហែលប្រសើរជាងនេះបើផ្តល់បទពិសោធន៍នេះដល់សហគ្រិនសិល្បៈវ័យក្មេងដែលមានចំណេះដឹងនិងបទពិសោធន៍ខ្លះស្រាប់ ប៉ុន្តែជាអ្នកដែលអាចប្រើប្រាស់មហោស្រពនេះដើម្បីអភិវឌ្ឍជំនាញនិងសមត្ថភាពរបស់ពួកគេក្នុងវិស័យនេះ។ ជម្រើសមួយទៀត ក្រុមចម្រុះនៃសិល្បករនិងមនុស្សដែលមិនមែនជាសិល្បករនឹងបង្កើតបានកិច្ចសហការ គំនិត និងមធ្យោបាយថ្មីនៃការធ្វើការ ដោយសារក្រុមហាត់ការមានគំនិតប្លែកនិងជោគជ័យសម្រាប់ការភ្ជាប់សិល្បៈជាមួយបញ្ហាសង្គម ការប្រមូលយុវជនមកចូលរួម និងការឆ្លុះបញ្ចាំងកង្វល់របស់យុវជនក្នុងសង្គម។

- កម្មវិធីបណ្តុះបណ្តាលដែលមានរចនាសម្ព័ន្ធកាន់តែ ច្បាស់លាស់អំពីសិល្បៈនឹងផ្តល់ឱ្យក្រុមអ្នកហាត់ការនូវការតម្រង់ទិសកាន់តែរឹងមាំ និងជួយពួកគេឱ្យសម្រេចចិត្តបានកាន់តែមានប្រសិទ្ធភាព។ ត្រូវមានការចូលរួមដោយផ្ទាល់កាន់តែច្រើនក្នុងសិល្បៈសម្រាប់អ្នកដែលមិនមានចំណេះដឹងមូលដ្ឋានរឹងមាំ។ ការជួបជុំនិងការប្រាស្រ័យដោយផ្ទាល់មានប្រសិទ្ធភាពបំផុតក្នុងការរុញច្រានការអភិវឌ្ឍមហោស្រពនេះឆ្ពោះទៅមុខ ដើម្បីការចែករំលែកចំណេះដឹងនិងបទពិសោធន៍ និងដើម្បីការពិភាក្សាគំនិត។ ក្រុមអ្នកហាត់ការផ្តល់យោបល់ថា ការជួបជុំដោយផ្ទាល់គួរតែធ្វើឡើងជាប្រចាំ ដើម្បីរក្សាសាមគ្គីភាពក្នុងក្រុមឬ «ស្មារតីជាក្រុម»។



- ក្រុមអ្នកហាត់ការបានរៀនសូត្រច្រើនអំពីសិល្បៈ អភិវឌ្ឍជំនាញថ្មីៗ និងភ្ជាប់ទំនាក់ទំនងរវាងសិល្បៈនិងបញ្ហាសង្គម។ ទោះជាយ៉ាងណា ប្រភេទនៃការចូលរួមដែលបង្កើតឡើងនេះមានលក្ខណៈចម្រុះគ្នាហើយមានតុល្យភាពរវាងបរិមាណនិងគុណភាពនៃការចូលរួមជាមួយនឹងបញ្ហាសង្គម។

- ការចូលរួមអាចពាក់ព័ន្ធនឹងការបង្កើនកម្រិតយល់ដឹងបញ្ហាសំខាន់ៗ ដែលយុវជនវ័យក្មេងកំពុងប្រឈម ហើយមហោស្រពនេះបានប្រើប្រាស់សិល្បៈដើម្បីឆ្លើយតបនឹងចំណុចនេះ។ មហោស្រពនេះក៏ទទួលបានជោគជ័យខ្លាំងដែរក្នុងការអភិវឌ្ឍជំនាញនិងលើកកម្ពស់លំហសុវត្ថិភាពនៃការពិភាក្សាគ្នាជាមួយនឹង សំឡេងចម្រុះ។

- មានការរំពឹងចង់បានអ្វីខ្លះនិងព្រំដែនបែបណាខ្លះចំពោះសិល្បៈ តើគេគួរតែលើកកម្ពស់ការកៀរគរមតិឬទេ? ការណ៍នេះប្រហែលមិនអាចទៅរួចទេនៅក្នុងបរិបទបច្ចុប្បន្ននេះ(ជាក់ស្តែង ក្រុមអ្នកហាត់ការបានដកគំនិតរបស់ពួកគេពាក់ព័ន្ធនឹងការធ្វើការដោយផ្ទាល់ជាមួយនឹងអង្គការដែលធ្វើការលើរឿងសិទ្ធិមនុស្ស។ បន្ទាប់ពីពិចារណារួចមក ពួកគេយល់ថាមិនមានសុវត្ថិភាពចំពោះពួកគេ ចំពោះអង្គការនិងសិល្បករផងដែរ)។

- កញ្ចប់ថវិកាកាន់តែធំ ការចូលរួមពីបណ្តាញផ្សព្វផ្សាយកាន់តែប្រសើរ និងវិធីសាស្ត្រផ្សព្វផ្សាយថ្មីៗ (ដូចជាការសហការជាមួយនឹងបុគ្គលមានឥទ្ធិពលលើបណ្តាញសង្គម ការប្រើប្រាស់យុវជនដើម្បីបង្កើតនិងចែកចាយមាតិកា) គួរតែយកមកពិចារណា។ មនុស្សគ្រប់គ្នាក្នុងក្រុមរៀបចំមហោស្រពនេះលើកឡើងអំពីបញ្ហាក្នុងការអញ្ជើញក្រុមសិល្បករមកសម្តែងក្នុងកញ្ចប់តម្លៃដែលពួកគេមាន ប៉ុន្តែនោះមិនស្របនឹងតម្លៃពេលវេលារបស់សិល្បករទាំងនោះទេ។

- នៅមិនច្បាស់ទេថាក្រុមអ្នកហាត់ការនឹងទៅណាទៀតបន្ទាប់ពីនេះ ដំណើរការនេះបានបង្កើតសមត្ថភាពរបស់ពួកគេក្នុងទិដ្ឋភាពខ្លះប៉ុន្តែនៅខ្វះផ្នែកជាច្រើនទៀត។ ក្រុមអ្នកហាត់ការនេះមានភាពសកម្មណាស់ក្នុងការងារស្ម័គ្រចិត្ត ដូច្នេះតើវាជារឿងមួយ«ផ្សេងទៀត»ឬជាតួនាទីកាន់តែធំជាងនេះបន្តិចទេនៅក្នុងប្រវត្តិបទពិសោធន៍ការងាររបស់ពួកគេ? ដំណើរការនេះមិនបានបង្កើតសមត្ថភាពក្នុងវិស័យសិល្បៈទេ ហើយក៏មិនបាន លើកទឹកចិត្តពេញលេញឱ្យវិស័យនេះគិតហ្មត់ចត់អំពីទំនាក់ទំនងរវាងសិល្បៈនិងការអភិវឌ្ឍសង្គមឱ្យហួសពីកម្រិតទទួលយករបស់ទស្សនិកជននោះដែរ។ ទោះជាយ៉ាងណា ក្រុមអ្នកហាត់ការមានគំនិតថ្មីៗនិងបានបង្កើតកម្មវិធីចែករំលែកចំណេះដឹងដែលគួរឱ្យចាប់អារម្មណ៍ចំពោះវិស័យនេះ។

- ក្រុមអ្នកហាត់ការបានផ្តល់យោបល់ឱ្យ មានរបៀបបំពេញការងារដោយផ្ទាល់បន្ថែមទៀតឬការជ្រើសរើសឱ្យធ្វើការកាន់តែប្រសើរនៅកន្លែងដែលពួកគេបំពេញការងារក្នុងការិយាល័យអង្គការសិល្បៈខ្មែរអមតៈ និងទទួលបានប្រាក់ខែសមស្របសម្រាប់រយៈពេលនៃការងារ(ពោលគឺពារសៀលក្នុងមួយសប្តាហ៍)។ ពួកគេយល់ថាការធ្វើបែបនេះនឹងលើកទឹកចិត្តឱ្យមានការចែករំលែកកាន់តែច្រើននិងការសម្របសម្រួលរវាងគោលដៅនៃមហោស្រពនេះជាមួយនឹងបុគ្គលិកអង្គការសិល្បៈខ្មែរអមតៈ។ ក្នុងនោះដែរក៏មាន ការផ្តល់យោបល់ឱ្យមានការទទួលស្គាល់កាន់តែច្រើនចំពោះបរិមាណនៃការងារដែលពាក់ព័ន្ធនិងការផ្តល់កម្រៃឱ្យបានសមស្រប។

# វិធីសាស្ត្រ

## ០១

ការស្រាវជ្រាវជាមុនពីរបៀបដែលយុវជនយល់ឃើញពីទំនាក់ទំនងរវាងសិល្បៈនិងការចូលរួមរបស់ពលរដ្ឋនៅកម្ពុជា។ វាត្រូវបានធ្វើឡើងនៅក្នុងការស្រាវជ្រាវមុនរបស់យើងអំពីទស្សនិកជនសិល្បៈ ដោយរួមបញ្ចូលក្រុមពិភាក្សាចំនួន១៥ ដែលយើងសិក្សាពីបញ្ហានេះជាផ្នែកមួយនៃរដូវវប្បធម៌របស់សិល្បៈខ្មែរអមតៈឆ្នាំ២០២២ (មើល Rogers et al 2023)។

## ០២

ការប្រកាសជ្រើសរើសអ្នកហាត់ការរបស់សិល្បៈខ្មែរអមតៈ ដោយអ្នកហាត់ការចំនួន៤នាក់ដែលមានបទពិសោធន៍តិចតួចឬគ្មានសោះអំពីសិល្បៈ(ប៉ុន្តែចាប់អារម្មណ៍នឹងសិល្បៈ) ត្រូវបានជ្រើសរើសដើម្បីដឹកនាំការរៀបចំមហោស្រពសិល្បៈ។ អ្នកហាត់ការបានហៅកម្មវិធីនេះថាមហោស្រព៧ពណ៌។ អ្នកហាត់ការទាំងនោះរួមមាន ៖ ឃឿន កំសត់ មាឃ បុប្ផារតនៈ អ៊ុក លីគួយយូ និងសុទ្ធ ពៅសំណាង។ ពួកគេមានអត្តសញ្ញាណយេនឌ័រ និងមកពីប្រភពខុសគ្នា ហើយកំសត់មកពីខេត្តរតនៈគិរី។ ប៉ុន្តែពួកគេមានចំណុចរួមមួយ គឺពួកគេមានចំណេះដឹង និងអាយុប្រហាក់ប្រហែលគ្នា (ជាង២០ស្ទើង) និងមានបទពិសោធន៍ក្នុងការងារស្ម័គ្រចិត្ត ឬសកម្មភាពសង្គម។



## ០៣

គំនិតដើមដំបូងគឺថាមហោស្រពនេះជាការប្រារព្ធខួប២៥ឆ្នាំរបស់សិល្បៈខ្មែរអមតៈ។ អ្នកហាត់ការត្រូវបានស្នើឱ្យជ្រើសរើសស្នាដៃសិល្បៈពីរដូវវប្បធម៌របស់សិល្បៈខ្មែរ(២០១៨-២០២៣) ដើម្បីយកមកបង្ហាញឡើងវិញសម្រាប់ព្រឹត្តិការណ៍នេះ។ ក្រោយមកតួនាទីនៃព្រឹត្តិការណ៍ជាមហោស្រពយុវវ័យនេះក្លាយជាចលករនាំមុខមួយជាជាងការភ្ជាប់ទៅនឹងការប្រារព្ធខួបរបស់សិល្បៈខ្មែរអមតៈ។

## ០៤

យើងបានសិក្សាពីរបៀបដែលពួកគេធ្វើការសម្រេចចិត្តជាក្រុម និងអ្វីដែលពួកគេឱ្យតម្លៃនៅក្នុងដំណើរការងារនេះ។ យើងតាមដំណើររបស់អ្នកហាត់ការនៅក្នុងការរៀបចំមហោស្រព រួមទាំងការយល់ដឹងបន្ថែមអំពីសិល្បៈ ការសម្រេចចិត្ត និងការទទួលបានបទពិសោធន៍ក្នុងដំណើរការផលិតកម្មវិធីនេះ។ ទាំងនេះរួមបញ្ចូលទាំងការសង្កេតពេលប្រជុំ ការវាស់ស្ទង់ពីការអភិវឌ្ឍជំនាញនិងការយល់ដឹងអំពីសិល្បៈ ការសម្ភាសន៍ជាក្រុម និងជាឯកត្តជនក្រោយព្រឹត្តិការណ៍មហោស្រព។ យើងក៏បានសម្ភាសន៍លោក សុង សេង អ្នកសម្របសម្រួលមហោស្រពផងដែរ ដែលលោកជាអ្នកគ្រប់គ្រងនិងគាំទ្រអ្នកហាត់ការ។ យើងបានសុំឱ្យអ្នកហាត់ការរក្សាទុករូបថតជាកំណត់ហេតុប្រចាំសប្តាហ៍អំពីបទពិសោធន៍របស់ពួកគេដែលមានទាំងភាពជោគជ័យនិងបរាជ័យផងលាយគ្នា។

## ០៥

យើងបានវិភាគកម្មវិធីមហោស្រពនិងការសម្តែងធ្វើវីដេអូសម្ភាសន៍ខ្លីៗជាមួយទស្សនិកជននិងអ្នកស្ម័គ្រចិត្ត (ចម្លើយជាង៨០) ប្រមូលចម្លើយតាមអនឡាញនិងតាមការសរសេរផ្ទាល់ជាមួយនឹងពិព័រណ៍រូបថត ធ្វើបទសម្ភាសន៍ខ្លីៗចំនួន៤ជាមួយនឹងបេក្ខជនដែលបានបង្ហាញសមត្ថភាពក្នុងកម្មវិធី «បង្ហាញទេពកោសល្យចម្រុះ» ប្រមូលនិងវិភាគសារ៧៧នៅលើដើមឈើសារបំណង។

# ការចូលរួម
# របស់ពលរដ្ឋ

មានការពិបាកក្នុងការបកប្រែពាក្យ «civic participation» ជាភាសាខ្មែរដោយហេតុថាវាជា ទស្សនៈដែលប្រើដោយអង្គការអន្តរជាតិ ដូច្នេះហើយវាជៀសមិនផុតពីការល្មៀងទៅខាងអឺរ៉ុប-អាមេរិក។ យើងបានសាកល្បងជាមួយនឹងការបកប្រែផ្សេងៗនៅក្នុងបរិបទខុសៗគ្នា។ នៅតាមខេត្ត យើងប្រែថា«ស្មារតីសហគមន៍»ដែលពាក្យនេះងាយស្រួលយល់ជាង។ យើងបានសួរអំពីព្រឹត្តិការណ៍ដែលប្រជាជន ធ្លាប់បានឮនិងចាត់ទុកថាជាការចូលរួមរបស់ពលរដ្ឋ (ឧ.រត់ជាមួយសាយ ការប្រមូលមូលនិធិដើម្បីសង់បណ្ណាល័យក្នុងសហគមន៍ ការប្រើប្រាស់បណ្តាញសង្គម ការចូលរួមពិធីបុណ្យនៅតាមវត្ត) ហើយសួរពួកគេអំពីការចូលរួមរបស់ពួកគេផ្ទាល់នៅក្នុងជីវិត។ ចំពោះក្រុមពិភាក្សានៅតាមខេត្ត ពួកគេត្រូវការការពន្យល់បន្ថែមតាមរយៈឧទាហរណ៍ ប៉ុន្តែច្បាស់ណាស់ថាពួកគេមានគំនិតនិងយោបល់អំពីការចូលរួមរបស់ពលរដ្ឋ នៅពេលដែលពួកគេបានយល់ច្បាស់ពីវា។ កង្វះពេលវេលាជាបញ្ហាមួយជុំវិញកង្វះការចូលរួម។

ទោះយ៉ាងណា យុវជនខ្មែរមកពីគ្រួសារមធ្យមដែលរៀនមហាវិទ្យាល័យ ជាពិសេសនៅទីក្រុងភ្នំពេញ អាចធ្លាប់ធ្វើការស្ម័គ្រចិត្តឬធ្វើការឱ្យអង្គការ។ ដូច្នេះពួកគេយល់ដឹងពីពាក្យនេះបានច្រើន។ ទោះយ៉ាងណាសូម្បីនៅទីនេះ ដូចលទ្ធផលរបស់យើងបង្ហាញជាមួយអ្នកហាត់ការ ការយល់ដឹងអំពីពាក្យនេះគឺច្រើននៅត្រឹមតែការគិត អំពីទំនាក់ទំនងរវាងសិល្បៈនិងសង្គម ឬការប្រើសិល្បៈដើម្បីការអភិវឌ្ឍសង្គម។ នៅក្នុងបរិបទបច្ចុប្បន្ន ភាសានៃការអភិវឌ្ឍសង្គមគឺធ្ងន់ទៅខាងនយោបាយ ដោយរាជរដ្ឋាភិបាលកម្ពុជាប្រើពាក្យនេះសំដៅលើ ការចូលរួមបែបវិជ្ជមានក្នុងសង្គម ប៉ុន្តែបែបវិជ្ជមានយ៉ាងម៉េច? ចំណុចនេះគឺត្រូវជជែកនិងពិភាក្សាថែមទៀត។ ការខ្វែងគំនិតគ្នាខ្លះៗកើតមានឡើងនៅក្នុងចំណោមអ្នកហាត់ការ។ ឧទាហរណ៍ វាមានការរំពឹងថា សិល្បៈអាចរួមចំណែកក្នុងឧត្តមគតិដូចជាសមភាព សមធម៌ សមត្ថភាពការបង្ហាញជាភាពជាខ្លួនឯង (ពោលគឺ ក្នុងវិសាលភាពនៃសេរីភាពក្នុងការបញ្ចេញមតិ) ប៉ុន្តែក៏មានការយល់ដែរថា សិល្បៈអាចត្រូវប្រើដើម្បីផ្សព្វផ្សាយពីកម្ពុជា បែបជាតិនិយមដែលស្របនឹងការចង់បានរបស់រដ្ឋាភិបាល។





គោលនយោបាយនិងការស្រាវជ្រាវបច្ចុប្បន្នអំពី បញ្ហាពាក់ព័ន្ធនឹងទស្សនៈនៃការចូលរួមរបស់ពលរដ្ឋនៅក្នុងសង្គមឬសង្គមស៊ីវិលកម្ពុជា កម្រនឹងយកចិត្តទុកដាក់លើតួនាទីរបស់សិល្បៈនិងវប្បធម៌ណាស់។ ក្នុងន័យនេះ សិល្បៈតែងតែត្រូវញែកចេញពីការចូលរួមរបស់ពលរដ្ឋនៅក្នុងសង្គម។ ឧទាហរណ៍ សៀវភៅបោះពុម្ពផ្សាយដោយ Öjendal និង Lilja (2009) ស្តីអំពីការធ្វើលទ្ធិប្រជាធិបតេយ្យនៅកម្ពុជាសម័យក្រោយជម្លោះ និងរបាយការណ៍ឆ្នាំ២០២២ របស់អង្គការតម្លាភាពអន្តរជាតិស្តីអំពីការស្ទង់មតិគោលនយោបាយអំពីយុវជនកម្ពុជា សុទ្ធតែគិតថាការចូលរួមរបស់ពលរដ្ឋក្នុងសង្គមមានទំនាក់ទំនងនឹងបរិបទនយោបាយ។ ការចូលរួមរបស់ពលរដ្ឋត្រូវបានគេមើលឃើញថាជាប់ពាក់ព័ន្ធនឹងការសម្រេចចិត្តផ្នែកគោលនយោបាយ ការសម្រេចចិត្តនិងផែនការការងាររបស់អាជ្ញាធរមូលដ្ឋាន (ឧ.ការបោះឆ្នោត ការផ្តល់អំណោយនិងការធ្វើការងារស្ម័គ្រចិត្ត)។ ស្រដៀងគ្នានេះដែរ ស្នាដៃរបស់ Schröder និង Young (២០១៩) ផ្តោតលើការបង្រួញសង្គមស៊ីវិលកម្ពុជាដើម្បីវិស័យកសិកម្ម (i)សមភាពយេនឌ័រ (ii)សមភាពប្រាក់ចំណូលនិងបញ្ហាកម្មសិទ្ធិដីធ្លី។ លក្ខណៈពិសេសលើនិន្នាការទូទៅនេះគឺ Young (២០២១) ដែលសិក្សាពីរបៀបដែលរូបថតត្រូវបានសហគមន៍ដែលមានសំឡេងតិច ប្រើប្រាស់ដើម្បីបង្ហាញការទាមទារបែបនយោបាយពាក់ព័ន្ធនឹងយុត្តិធម៌បរិស្ថាន ផ្អែកលើការយល់ដឹងពីរបៀបដែលរូបថតប្រចាំថ្ងៃដោយ ប្រើស្មាតហ្វូនអាចឱ្យប្រជាជនបង្ហាញការទាមទារភាពជាពលរដ្ឋ សិទ្ធិ និងអត្តសញ្ញាណរបស់ខ្លួន (Young ២០២៣)។

ទោះយ៉ាងណា ស្នាដៃស្រាវជ្រាវធំទូលាយនៅក្នុងការសិក្សាអំពីការអភិវឌ្ឍន៍និងបរិបទក្រោយសង្គ្រាមពិតជាចាត់ទុកថាសិល្បៈអាចរួមចំណែកធ្វើឱ្យមាន បរិយាបន្ននិងភាពជាម្ចាស់នៃវប្បធម៌របស់ខ្លួន។ ការស្រាវជ្រាវនេះសិក្សាជាពិសេសពីរបៀបដែលយុវជនអាចប្រើសិល្បៈដើម្បីលើកឡើងពីការទាមទារសិទ្ធិ ជាពិសេសពាក់ព័ន្ធនឹងយេនឌ័រនិងសមភាព (Cooke និង Soria-Donlan ២០១៩)។ ស្នាដៃបែបនេះគិតគូរពីការចូលរួមរបស់ពលរដ្ឋនៅក្នុងសង្គមខ្លាំងណាស់ ប៉ុន្តែមិនបានប្រើវាក្យស័ព្ទនេះទេ។ បន្ថែមលើនេះទៀត ស្នាដៃបែបនេះច្រើនតែមើលឃើញសិល្បៈជាកន្លែងផ្តល់នូវភាពធន់តាមរយៈលទ្ធភាពនយោបាយ ឬសង្គមផ្សេងទៀតត្រូវបានធ្វើឡើងនិងបង្ហាញឱ្យឃើញ (Cin et al ២០២៣; Mkwananzi et al ២០២៣)។ កន្លែងដែលសំណួរពីការចូលរួមលេចឡើងច្រើនតែនៅក្នុងការសិក្សាពីការអភិវឌ្ឍ គឺមានការខ្វាយខ្វល់អំពីរបៀបដែលការចូលរួមរបស់ពលរដ្ឋនៅក្នុងសង្គមអាចបង្កើតឡើងវិញនូវអំណាចយុត្តិធម៌និងទំនាក់ទំនង (Cooke និង Kathari ២០០១)។ និយាយមួយបែបទៀត ការចូលរួមជាឃ្លាអះអាងពីអំណាច បរិយាបន្ន ប្រជាធិបតេយ្យនិងទម្រង់ផ្សេងៗនៃការអភិវឌ្ឍ«បែបវិជ្ជមាន» ប៉ុន្តែដំណើរការនៃការសម្រេចចិត្តនិងការអនុម័តអាចមិនត្រឹមតែធ្វើឱ្យដំណើរការទាំងនេះច្របូកច្របល់ប៉ុណ្ណោះទេ ប៉ុន្តែបង្ការវាយ៉ាងសកម្មថែមទៀត (មើល Breed និង Prentki ២០១៨ ទាក់ទងនឹងសិល្បៈ)។

ដូច្នេះការសិក្សានេះនាំយកផ្នែកទាំងអស់នេះមករួមគ្នា ដោយគិតពីរបៀបជំរុញយុវជនទៅក្នុងវិស័យសិល្បៈអាចលើកកម្ពស់ ការចូលរួមក្នុងរបៀបផ្សេងៗដែលអាចពាក់ព័ន្ធនឹងមជ្ឈដ្ឋាននៃសង្គមស៊ីវិល។ យើងក៏សិក្សាផងដែរពីរបៀបដែលសិល្បៈអាចជំរុញការផ្ទេរជំនាញដែលជាតម្រូវការសម្រាប់ការចូលរួមរបស់ពលរដ្ឋ និងកំណត់ព្រំដែននៃដំណើរការនេះ។

# ០១

# ការស្វែងយល់ពីការចូលរួមរបស់ពលរដ្ឋក្នុងចំណោមយុវជនវ័យក្មេង

**ផ្នែកនេះបង្ហាញថា៖**

- ទស្សនិកជនជាយុវជនវ័យក្មេងមើលឃើញថាការចូលរួមរបស់ពលរដ្ឋជា គម្រោងសមូហភាពមួយដើម្បីធ្វើឱ្យសង្គមប្រសើរឡើងនិងបង្កើតសាមគ្គីភាព។
- យុវជនវ័យក្មេងចាប់អារម្មណ៍ទៅលើវិសមភាព និងទម្រង់ផ្សេងៗនៃការចូលរួមរបស់ពលរដ្ឋនៅក្នុងសង្គម។
- សិល្បៈនិងវប្បធម៌ត្រូវបានគេមើលឃើញថា ជាចំណុចនៃការចាប់ផ្តើមការចូលរួមរបស់ពលរដ្ឋក្នុងសង្គម និងការបង្កើតទម្រង់ប្រជាធិបតេយ្យនៃកិច្ចសន្ទនា។
- យុវជនវ័យក្មេងពិចារណាអំពីបែបផែននៃ ការចូលរួមដែល«ល្អ»។
- ការអប់រំ និងការចូលរួមព្រឹត្តិការណ៍សិល្បៈត្រូវបានគេមើល ឃើញថាជាទម្រង់មួយនៃការចូលរួមរបស់ពលរដ្ឋក្នុងសង្គម។ សិល្បករក៏មើលឃើញដែរថាស្នាដៃរបស់ពួកគេជាការលើកកម្ពស់ការចូលរួមរបស់ពលរដ្ឋក្នុងសង្គម។
- អ្នកណាទទួលខុសត្រូវក្នុងការផ្សព្វផ្សាយពីសិល្បៈជា សំណួរគួរឱ្យចាប់អារម្មណ៍មួយដែល ច្រើនតែគ្មាននៅក្នុងការជជែកពិភាក្សា។




តាមការស្រាវជ្រាវមុនរបស់យើងជាមួយទស្សនិកជនជាយុវជនវ័យក្មេង និងសិល្បករទាំងនៅទីក្រុងភ្នំពេញ ទាំងនៅតាមខេត្ត យើងមានអារម្មណ៍ជារួមថា ប្រជាជនយល់ថាការចូលរួមរបស់ពលរដ្ឋក្នុងសង្គម គឺជាគម្រោងសមូហភាពមួយ ជាអ្វីមួយដែលពួកគេធ្វើរួមគ្នាជាប្រយោជន៍ដល់សង្គម។ *«យើងមិនធ្វើដើម្បីខ្លួនឯងទេប៉ុន្តែដើម្បីប្រយោជន៍រួម»* *(ក្រុមពិភាក្សា)*។ វាក៏ត្រូវបានមើលឃើញថាជា *«ការផ្តល់ត្រឡប់ទៅឱ្យសង្គម»* វិញដែរ ប៉ុន្តែវាក៏ជាបំណិនជីវិតនិង *«ការយកចិត្តទុកដាក់»* ចំពោះមនុស្ស បរិស្ថាន សហគមន៍ដែរ(ក្រុមពិភាក្សា)។ អ្នកចូលរួមក៏លើកឡើងដែរថា ការចូលរួមរបស់ពលរដ្ឋក្នុងសង្គមមិនសំដៅលើតែការរៃអង្គាសថវិកាឬឱ្យលុយទេ (ទាំងនេះគឺមានបង្ហាញនៅក្នុងរបាយការណ៍ឆ្នាំ២០២២របស់អង្គការតម្លាភាពអន្តរជាតិ ដែលមានលើកឡើងពីសំណួរមួយទាក់ទងនឹងការបរិច្ចាគ) ប៉ុន្តែជាអារម្មណ៍គាប់ចិត្តអារម្មណ៍ *«ពេញចិត្តនឹងខ្លួនឯង»* ដោយបានធ្វើអ្វីមួយដើម្បីអ្នកដទៃ (ក្រុមពិភាក្សា)។ ទស្សនិកជនតាមខេត្តហាក់ចូលរួមដោយផ្ទាល់ច្រើនជាង ព្រោះអ្នកចូលរួមបានពិភាក្សាអំពីការសង់បណ្ណាល័យ ជួសជុលផ្លូវថ្នល់ ការបរិច្ចាគប្រាក់ដល់មន្ទីរពេទ្យក្នុងតំបន់ បន្ទាប់ពីក្រុមរបស់ពួកគេសម្តែងចប់ ឬការជួយមនុស្សចាស់ជរា។



ក៏មានរបៀបផ្សេងៗនៃការចូលរួមដែលអ្នកចូលរួមបានពិភាក្សា ដូចជាការផ្តល់ពេលវេលា ប្រាក់ ជំនាញ សមត្ថភាព ប្រភពគំនិត។ ក៏មានការទទួលស្គាល់ដែរថា *«មិនមែនគ្រប់គ្នាចូលរួមស្មើគ្នាទេ»* ហើយថាវាអាចមកពីស្ថានភាព និងគោលជំហររបស់ប្រជាជនដែលអ្នកចង់ *«បញ្ឈប់ភាពអយុត្តិធម៌»* ប៉ុន្តែវាប្រថុយនឹងហានិភ័យផ្ទាល់ខ្លួន *(ក្រុមពិភាក្សា)*។ ដូច្នេះខណៈពេលដែល *«ប្រើសំឡេងខ្លួនឯង»* ដើម្បីនិយាយពីការគាបសង្កត់ឬធ្វើរឿងល្អមួយត្រូវបានមើលឃើញថាជាផ្នែកមួយនៃការចូលរួមរបស់ពលរដ្ឋក្នុងសង្គម *«ការមានសំឡេង»* មិនមែនចេះតែអាចទៅរួចនោះទេ *(ក្រុមពិភាក្សា)*។ ទិន្នន័យទាំងនៅភ្នំពេញទាំងនៅខេត្ត សមាជិកក្រុមពិភាក្សាខ្លះលើកឡើងថារឿងដែលត្រូវបានមើលឃើញថាជាប្រយោជន៍របស់គ្រប់គ្នានោះគឺផ្តោតតែទៅលើឯកត្តបុគ្គល។ ឧទាហរណ៍ក្រុមពិភាក្សាតែងតែថាការទៅវត្តឬការប្រើបណ្តាញសង្គមជាវិធីនៃការចូលរួមរបស់ពលរដ្ឋក្នុងសង្គម(ជាពិសេសមានពេលមួយនោះដែលសហគមន៍មូលដ្ឋានរកឃើញក្មេងប្រុសដែលបាត់ខ្លួន)។ ទោះយ៉ាងណាពួកគេក៏កត់សម្គាល់ដែរថាប្រជាជនអាចបញ្ចេញមតិតាមបណ្តាញសង្គមឬនិយាយពីខ្លួនឯង ប៉ុន្តែវាជាការចូលរួមបែបប្រយោលប៉ុណ្ណោះ វាមិនមែនជាសកម្មភាពដោយផ្ទាល់ ឬការចែករំលែកចំណេះដឹងដើម្បីអំពើល្អទេ។ ស្រដៀងគ្នានេះដែរ ការចូលរួមទំនៀមទម្លាប់បែបសាសនាត្រូវបានគេមើលឃើញថាត្រូវបានធ្វើឡើងដើម្បីប្រយោជន៍បុគ្គលដើម្បីបានបុណ្យខ្លួនឯងជាជាងការរួមគ្នាធ្វើអំពើល្អសម្រាប់សង្គម៖

> *«យើងចូលរួមដោយបើកទូលាយជាសាធារណៈ [...] ពួកគេគិតក្នុងនាមជាឯកត្តបុគ្គលប៉ុន្តែពួកគេចូលរួមជាសាធារណៈ និយាយអំពីសង្គម។ ប៉ុន្តែការគិតរបស់ពួកគេគឺជាឯកត្តបុគ្គល»។*
>
> *«ពួកគេគ្មានគោលបំណងផ្សេងក្រៅពីបានបុណ្យ (សម្រាប់ខ្លួនឯង)»*
>
> (ក្រុមពិភាក្សា)។

ទោះយ៉ាងណាការចូលរួមរបស់ពលរដ្ឋក្នុងសង្គមត្រូវបានមើលឃើញថាចាប់ផ្តើមពីបុគ្គល (តែវាមិនប្រាកដថាដើម្បីប្រយោជន៍បុគ្គលទេ) ហើយបន្ទាប់មកចូលទៅក្នុងសហគមន៍៖

> *«វាត្រូវផ្តើមចេញពីយើងក្នុងកម្រិតតូចសិន»។*
>
> *«សង្គមមួយអាចលូតលាស់បានមិនគ្រាន់តែមកពីមេភូមិឬមេឃុំទេ ប៉ុន្តែគឺចេញពីប្រជាជនគ្រប់គ្នាដែលរួបរួមគ្នានៅក្នុងសហគមន៍នោះ និងរួមគ្នាជាឆ្លុងមួយ ដូចជាការធ្វើផ្លូវឬសង់សាលារៀនជាដើម។ ប៉ុន្តែដើម្បីសម្រេចជាសមិទ្ធផលគឺមិនមែនចេញពីមនុស្សតែម្នាក់ទេ គឺផ្តើមចេញពីបុគ្គលគ្រប់គ្នាទើបយើងអាចសម្រេចបាន»*
>
> (ក្រុមពិភាក្សា)។

មនុស្សជាច្រើនផ្សេងទៀតទទួលស្គាល់ថា សមត្ថភាពទទួលយកការរិះគន់ក៏ជាផ្នែកមួយនៃការចូលរួមដែរ។ មានការជជែកពិភាក្សាច្រើនជុំវិញទម្រង់នៃការចូលរួមនិងប្រសិទ្ធភាពរបស់វា។ ការចូលរួមល្អបំផុតគឺ *«ការរួមចំណែកតូចៗនាំទៅរកការផ្លាស់ប្តូរធំ»* *(ក្រុមពិភាក្សា)*។ ទស្សនៈនេះមានរួមនឹងទស្សនៈបែបទុទិដ្ឋិនិយមដែលថាបើគ្មានមនុស្សច្រើនចូលរួមទេ ទោះបីមានការផ្លាស់ប្តូរតិចតួចតែវាអាចមានឥទ្ធិពលតិចតួចប៉ុណ្ណោះ។ ក៏មានការទទួលស្គាល់ដែរថាវាមិនមែនមានតែហេតុនិងផលរហូតទេ។ អ្នកចូលរួមខ្លះពិភាក្សាថាតើហេតុអ្វីការរួមចំណែកក្នុងសង្គមនិងការលើកឡើងពីបញ្ហាសង្គមធ្វើឱ្យមានអារម្មណ៍ថាជារឿង *«ធំខ្លាំងណាស់»* ហើយពួកគេអធិប្បាយពីតម្រូវការឱ្យមានការផ្លាស់ប្តូរតាមរយៈការចូលរួមជាមួយ*«សហគមន៍ជាក់លាក់»* ណាមួយ អង្គការ តួនាទី។ល។ *(ក្រុមពិភាក្សា)*។ ក្នុងកម្រិតតូចមួយក៏សិល្បៈ និងវប្បធម៌អាចបង្កើតការចូលរួមបានដែរ។ នេះគឺដោយសារសិល្បៈត្រូវបានគេមើលឃើញថាអាចទាញចំណាប់អារម្មណ៍ទៅលើបញ្ហាផ្សេងៗនិង *«បង្កើតកិច្ចសន្ទនា»* ដែលជាជំហានដំបូងមួយនៃការពង្រឹងការចូលរួមរបស់ពលរដ្ឋក្នុងសង្គម៖

*«ប៉ុន្តែមនុស្សខ្លះទៀត ដូចជាមិត្តខ្ញុំជាដើមដែលបានមើលការសម្តែងនោះខ្ញុំមានអារម្មណ៍ថា យើងមិនដែលចាប់អារម្មណ៍នឹងរឿងទាំងអស់នេះទេពីមុនមក។ ប៉ុន្តែបន្ទាប់ពីមើលហើយ យើងចាប់ផ្តើមនិយាយពីសាច់រឿងនោះ។ ហើយក៏មានអ្នកផ្សេងទៀតនិយាយពីរឿងនោះដែរ»*

(ក្រុមពិភាក្សា)។





គំនិតដែលថាស្មារតីសហគមន៍គឺដើម្បីប្រយោជន៍រួម និងថាវាអាចមានការខ្វែងគំនិតគ្នា ហើយការសន្ទនាគ្នាជាការជំរុញប្រជាធិបតេយ្យនិងការស្វែងយល់ពីការចូលរួមរបស់ពលរដ្ឋក្នុងសង្គម។ ពេលខ្លះ ការចូលរួមរបស់ពលរដ្ឋក្នុងសង្គមត្រូវបានយកមកពិភាក្សាដោយមានទំនាក់ទំនងនឹងប្រជាធិបតេយ្យ ហើយអ្វីដែលពិបាកនៅកម្ពុជាគឺដោយសារ *«យើងមិនអាចធ្វើអ្វីតាមចិត្តចង់ទេ»* ដោយសារបរិបទនយោបាយ *(ក្រុមពិភាក្សា)*។ អ្នកចូលរួមលើកឡើងពីការភ័យខ្លាចក្នុងការនិយាយពីបញ្ហាដែលអាចបង្កវិវាទ ប៉ុន្តែការចូលរួមរបស់ពលរដ្ឋក្នុងសង្គមគឺជា *«ការរកឃើញវិធីមួយផ្សេងទៀតក្នុងការធ្វើអ្វីមួយ»* *(ក្រុមពិភាក្សា)*។ ទោះយ៉ាងណាអ្នកខ្លះនិយាយ (ជាពិសេសក្នុងចំណោមសិល្បករ) ថាការចូលរួមរបស់ពលរដ្ឋក្នុងសង្គមមិនចាំបាច់ត្រូវតែប្រឆាំងនឹងរដ្ឋាភិបាលទេ ប៉ុន្តែត្រូវជួយដោះស្រាយបញ្ហាសង្គម សមូហភាព និងការពលីដើម្បីប្រយោជន៍រួម។ វាមិនចាំបាច់តែជាកម្មវិធីគាំទ្ររដ្ឋាភិបាលទេ ប៉ុន្តែជាការចង់បានការចេះវិភាគវែកញែកថាហេតុអ្វីបានជាបញ្ហាមួយចំនួនកើតឡើង ហើយតើត្រូវធ្វើអ្វីដើម្បីសម្រួលដំណោះស្រាយដល់ពួកគេ។ ទោះយ៉ាងណាសិទ្ធិមិនចូលរួម និងមិនយល់ស្រប ក៏ត្រូវបានកំណត់ថាជាផ្នែកមួយនៃការស្វែងយល់ពីប្រជាធិបតេយ្យនៃការចូលរួមរបស់ពលរដ្ឋក្នុងសង្គមដែរ៖

*«ការយល់ស្របនិងការមិនយល់ស្របអាចកើតមានឡើងក្នុងពេលតែមួយ»។*

*«ពួកគេមានសិទ្ធិចូលរួមឬមិនចូលរួមផ្អែកតាមការយល់ឃើញរបស់ពួកគេ។ យើងអាចមើលឃើញថា ពេលខ្លះពួកគេចូលរួមនៅក្នុងសកម្មភាពទាំងនោះដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួន ប៉ុន្តែពេលខ្លះពួកគេចូលរួមដើម្បីប្រយោជន៍រួម។ ការចូលរួមខ្លះផ្តល់ប្រយោជន៍ដោយផ្ទាល់ដល់សង្គម»។*

*«ខ្ញុំគិតថា ការចូលរួមអាចបង្កើតឱ្យមានសាមគ្គីភាព។ យើងត្រូវសាមគ្គីគ្នា។ មិនមែនមានន័យថាបុគ្គលគ្រប់រូបត្រូវតែចូលរួមទេ។ សាមគ្គីភាពបង្កើតជាសំឡេងរួមមួយដែលគ្រប់គ្នាសម្រេចថាត្រឹមត្រូវ និងសមស្របសម្រាប់ពួកគេ។ វាបង្កើតជាវេទិកាមួយសម្រាប់ឱ្យគ្រប់គ្នាចូលរួម និងចែករំលែកគំនិតរបស់ពួកគេ»*

(ក្រុមពិភាក្សា)។

នៅទីក្រុងភ្នំពេញ អ្នកចូលរួមខ្លះរិះគន់ខ្លាំងពីសង្គមកម្ពុជា ជាពិសេសទំនោរដែលមើលទៅតែក្រៅប្រទេសតែមិនខ្វល់នឹងអ្វីដែលកើតឡើងក្នុងផ្ទះខ្លួនឯង។ ពួកគេមើលឃើញពីតម្រូវការ *«និយាយនិងលើកស្ទួយសង្គមនិងវប្បធម៌នៅក្នុងផ្ទះ»* ប៉ុន្តែប្រាកដណាស់វាជាបញ្ហានយោបាយ (គោលនយោបាយតូចៗក្នុងជីវិតប្រចាំថ្ងៃ) *(ក្រុមពិភាក្សា)*។ នៅក្នុងក្រុមពិភាក្សា មានសំណួរអំពីចំណុចដែលការចូលរួមអាចនាំទៅដល់ ហើយបើនិយាយឱ្យងាយយល់ ប្រសិនបើមានទម្រង់ល្អនិងអាក្រក់នៃការចូលរួម វានឹងមានឥទ្ធិពលវិជ្ជមានឬអវិជ្ជមាន (ជាជាងនៅចន្លោះកណ្តាលមិនច្បាស់លាស់)។ អ្នកចូលរួមនៅតាមខេត្តនិយាយអំពីការពិបាកប្រមូលគ្រប់គ្នាឱ្យចូលរួមក្នុងសកម្មភាពណាមួយនៅក្នុងភូមិរបស់ពួកគេនៅពេលគ្រួសារមួយក្នុងចំណោម២០គ្រួសារក្លាយជាអ្នកមាន ហើយពួកគេមិនបានជួយធ្វើផ្លូវទេ ប៉ុន្តែបែរជាសុំឱ្យគ្រប់គ្នាដាំដើមឈើនិងស្មៅទៅវិញ។ ពួកគេជួយ ប៉ុន្តែវាចង្អុលបង្ហាញពីការលំបាកក្នុងការជំរុញស្មារតីសមូហភាពនៅពេលដែលមានវិសមភាពទ្រព្យសម្បត្តិកើនឡើង ឬលេចឡើងច្បាស់ពេក។ ជាទូទៅ អ្នកចូលរួមក៏និយាយដែរអំពី *«ការពិបាកផ្លាស់ប្រែ»* ដោយសារប្រជាជន «គេចពីបញ្ហាច្រើនជាងរកដំណោះស្រាយ» ហើយពួកគេក៏និយាយដែរអំពីរបៀបដែល *«ជនជាតិខ្មែរជួយខ្លួនឯងបំបាត់វប្បធម៌ពឹងគេ»* ឬយ៉ាងហោចណាស់ក៏ព្យាយាមដែរ (ក្រុមពិភាក្សា)។ វាស្របគ្នាជាមួយនឹង Ear (២០១២) ដែលបានពិពណ៌នាពីវប្បធម៌ពឹងគេនេះដោយនៅក្នុងប្រវត្តិសាស្ត្រមានអង្គការចំនួនច្រើននៅកម្ពុជា។ ទាក់ទងនឹងចំណុចនេះដែរ សិល្បៈនិងវប្បធម៌ត្រូវបានគេមើលឃើញថារួមចំណែកក្នុងសង្គមតាមរយៈ *«ការនាំមកនូវសេចក្តីសុខនិងសន្តិភាព» «មិនប្រាកដថាជាការផ្លាស់ប្តូរទេតែធ្វើយ៉ាងណាឱ្យស្ងប់សុខមានតុល្យភាព»* *(ក្រុមពិភាក្សា)* ។ អំណះអំណាងនេះសបញ្ជាក់ថាមនុស្សម្នាក់អាចចូលពាក់ព័ន្ធនិងចូលរួមក្នុងសង្គមបាន ប៉ុន្តែគេត្រូវរក្សាស្ថានភាពបច្ចុប្បន្ន។ នេះជារឿងមិនប្រក្រតីដោយហេតុថាមនុស្សភាគច្រើនដឹងពីការចូលពាក់ព័ន្ធនិងការធ្វើឱ្យប្រសើរឡើងនៅពេលពិភាក្សាពីការចូលរួមរបស់ពលរដ្ឋ ប៉ុន្តែគួរកត់សម្គាល់ថាគឺមានការយល់ឃើញបែបនេះ។

ការអប់រំកុមារអំពីសិល្បៈនិងការចូលរួមព្រឹត្តិការណ៍សិល្បៈតែងតែត្រូវបានគេមើលឃើញថាជាទម្រង់មួយនៃការចូលរួមរបស់ពលរដ្ឋ។ វាគួរឱ្យចាប់អារម្មណ៍ព្រោះថាទស្សនិកជនច្រើនតែអសកម្ម ប៉ុន្តែការទទួលបានបទពិសោធន៍នៃ *«អារម្មណ៍ផ្តោតលើអ្វីមួយ»* ត្រូវបានគេមើលឃើញថាធ្វើឱ្យយើងចូលរួមយ៉ាងសកម្ម *(ក្រុមពិភាក្សា)*។ ដូចបានគូសបញ្ជាក់នៅក្នុងការស្រាវជ្រាវមុនរបស់យើង (Rogers et al ២០២១, ២០២៣) សិល្បៈត្រូវបានគេមើលឃើញថាជា *«ឧបករណ៍សម្រាប់ទំនាក់ទំនង»* *(ក្រុមពិភាក្សា)* ដូច្នេះធាតុអប់រំរបស់សិល្បៈគឺជាគន្លឹះបណ្តុះសមត្ថភាពពលរដ្ឋ៖ការគាំទ្រសិល្បៈត្រូវបានគេមើលឃើញថាជាការគាំទ្រវប្បធម៌/សង្គមកម្ពុជា។ ចំពោះអ្នកចូលរួមផ្សេងទៀត វាច្បាស់ណាស់ថា សិល្បៈតែងតែនាំឱ្យមានសុខុមាលភាពផ្លូវចិត្ត ហើយការកម្សាន្តអារម្មណ៍អាចជាផ្លូវនាំទៅរកការគិតអំពីបញ្ហាសង្គម៖

> *«ភាគច្រើននៃស្នាដៃសិល្បៈកើតចេញពីការនិយាយពីសង្គម។ ទោះបីវាចេញពីការស្រមើស្រមៃក៏ដោយ ក៏វានៅតែទាក់ទងនឹងបញ្ហាសង្គមដែរ។ ប៉ុន្តែវាបង្ហាញពីបែបផែនជីវិតរបស់មនុស្សនៅក្នុងសង្គម។ ដូច្នេះពេលយើងមើលសិល្បៈ យើងរៀនពីវាដើម្បីអភិវឌ្ឍប្រទេស។ ហើយអត្ថប្រយោជន៍គឺដើម្បីលើកស្ទួយវប្បធម៌»*
>
> (ក្រុមពិភាក្សា)។

ក្នុងបរិបទនេះ នៅពេលអ្នកចូលរួមនៅក្នុងសិល្បៈ អ្នកដឹងពីបញ្ហាដែលសង្គមកំពុងប្រឈម បន្ទាប់មកអាចគិតនិងធ្វើការងារដើម្បីដោះស្រាយបញ្ហាទាំងនោះ។ បើតាមទិន្នន័យដែលយើងប្រមូលបាន គឺវាជាការពិតនៅក្នុងកម្រិតណាមួយ។ ប្រហែលជាការបង្ហាញពីការដោះស្រាយបញ្ហាមិនបានដល់កម្រិតក៏ពិតមែន ហើយក៏មានសំណួរដែរជុំវិញថាតើសិល្បៈអាចធ្វើដូចការពិតដល់កម្រិតណា ប៉ុន្តែទោះយ៉ាងណាចំណុចចាប់ផ្តើមនៃដំណើរការនេះគឺមានហើយ។

សិល្បករតែងតែមើលឃើញថាស្នាដៃរបស់ពួកគេជាទម្រង់មួយនៃការចូលរួមរបស់ពលរដ្ឋក្នុងសង្គម គឺប្រើសិល្បៈដើម្បីការកម្សាន្តនិងការអប់រំ លើកស្ទួយជំនឿ ជាតិ សហគមន៍ សមភាព និងពាំនាំនូវចំណេះដឹងវប្បធម៌។ នៅតាមខេត្ត សិល្បករម្នាក់ជាផ្នែកមួយនៃក្រុមដែលបរិច្ចាគប្រាក់បានមកពីការសម្តែងទៅឱ្យមន្ទីរពេទ្យក្នុងមូលដ្ឋានដើម្បីជួយមនុស្សចាស់ជរា។ សិល្បករមើលឃើញខ្លួនឯងជាគំរូ ហើយចាំបាច់ត្រូវប្រកាន់គុណតម្លៃសំខាន់ៗមួយចំនួនទាំងសម្រាប់សង្គមទាំងសម្រាប់ការអនុវត្តការច្នៃប្រតិដ្ឋរបស់ខ្លួនឯង៖

> *«ខ្ញុំមិនចង់ថាខ្លួនឯងជាគំរូទេ ប៉ុន្តែយើងដឹងថាពេលយើងធ្វើអ្វីមួយ យើងបំផុសគំនិតដល់អ្នកមើលជាពិសេសក្មេងជំនាន់ក្រោយ ឱ្យដើរតាមគន្លងរបស់យើង។ ហេតុដូច្នេះហើយបានជាយើងត្រូវធ្វើជាគំរូគេ។ យើងត្រូវធ្វើជាគំរូសម្រាប់ក្មេងជំនាន់ក្រោយ។ យើងមិនអាចធ្វើរឿងដែលខុសឆ្គងបានឡើយ។ សូម្បីនៅលើហ្វេសប៊ុក ខ្ញុំចែករំលែកព័ត៌មានទៅសាធារណជននិងអ្នកជំនាញខាងសិល្បៈថាដើម្បីយល់ដឹង ពួកគេត្រូវតែចែករំលែកព័ត៌មានទាំងអស់នោះដែរព្រោះថានៅក្នុងសហគមន៍សិល្បៈ យើងត្រូវតែជួយគាំទ្រយើងខ្លួនឯង។ ប្រសិនបើយើងជាអ្នកសិល្បៈហ្នឹងមិនគាំទ្រសិល្បៈយើងផង ទៅឱ្យអ្នកណាមកគាំទ្រ? ប្រសិនបើយើងជាអ្នកជំនាញ យើងបានប្រាក់ខែ ហេតុអ្វីយើងមិនចូលរួម? នេះជារឿងមួយ។ នេះជាអ្វីដែលខ្ញុំគិតឃើញអំពីការចូលរួមរបស់ខ្ញុំ។ បន្ទាប់ពីការចូលរួម ខ្ញុំតែងតែចែករំលែកវាជាមួយអ្នកផ្សេងទៀត។ ខ្ញុំចែករំលែកព្រោះខ្ញុំចង់ឱ្យក្មេងៗចូលរួមជាមួយពួកយើងដែរ ហើយទទួលបានឱកាសស្វែងយល់ពីវា។ បើត្រឡប់ទៅមើលកាលពីមុនវិញ យើងគិតថា ស្នាដៃនិងសកម្មភាពខ្លះអាចនាំប្រយោជន៍(ដល់សង្គម)។ វាបានជួយដល់ការយល់ដឹងរបស់ខ្ញុំ ទស្សនៈខ្ញុំនិងគំនិតបង្កើតស្នាដៃថ្មីៗឬអភិវឌ្ឍជំនាញសិល្បៈរបស់ខ្ញុំឱ្យប្រសើរឡើង។ វាជួយខ្ញុំឱ្យយល់ដឹងរឿងរ៉ាវផ្សេងៗកាន់តែស៊ីជម្រៅ។»*
>
> (ក្រុមពិភាក្សា)។

គ្រូបង្រៀននៅសាលាមធ្យមវិចិត្រសិល្បៈដែលជាកន្លែងរៀបចំការសម្តែងក៏គិតដូច្នេះដែរ។ ពួកគេយល់ថា វាជាទំនួលខុសត្រូវរបស់ពួកគេក្នុងការថែរក្សានិងផ្ទេរបន្តចំណេះដឹងវប្បធម៌។ នេះជាផ្នែកមួយនៃទំនួលខុសត្រូវជាពលរដ្ឋនិងបេសកកម្មរបស់ពួកគេ៖

*«ពេលយើងចេញទៅធ្វើការនៅតាមស្រុករៀងៗខ្លួន យើងគួរតែបញ្ចូលទៅក្នុងការអប់រំ បង្ហាញពួកគេពីគុណតម្លៃនៃវប្បធម៌និងលើកទឹកចិត្តពួកគេឱ្យចូលរួមស្រឡាញ់វប្បធម៌និងថែរក្សាវប្បធម៌យើងសម្រាប់ទាំងអស់គ្នា»។*

*«ក្នុងនាមជាគ្រូនិងយុវជនជំនាន់ក្រោយម្នាក់នៅក្នុងសង្គម យើងគួរតែមានការយល់ដឹងច្បាស់អំពីវប្បធម៌របស់យើង សិល្បៈរបស់យើងនិងពីអ្វីដែលយើងមាន។ ហើយបន្ទាប់ពីបានយល់ហើយ យើងនឹងចែករម្លែកតាមរយៈការបង្រៀនឬផ្សព្វផ្សាយឬចេញធ្វើសកម្មភាពដែលទាក់ទាញក្មេងៗ»*

(ក្រុមពិភាក្សា)។

មានការជជែកពិភាក្សាជាច្រើនអំពីតួនាទីរបស់បណ្តាញសង្គមនៅក្នុងរឿងនេះ ហើយអ្នកដែលចូលរួមក្នុងក្រុមពិភាក្សាចង្អុលបង្ហាញថាប្រសិនបើគ្រូមិនចាប់អារម្មណ៍នឹងរបាំឬសិល្បៈ ក្មេងៗក៏មិនចាប់អារម្មណ៍ដែរ។ ពួកគេក៏បានលើកឡើងដែរថាចំនួនគ្រូនិងសិស្សដែលចាប់អារម្មណ៍នឹងរបាំគឺតិចតួចមែនទែន ដោយសារការគ្មានមុខវិជ្ជាសិល្បៈនៅក្នុងប្រព័ន្ធអប់រំថ្នាក់ជាតិ ប៉ុន្តែត្រូវទាក់ទាញចំណាប់អារម្មណ៍របស់កុមារតាំងពីក្មេង។

*«ខ្ញុំណែនាំឱ្យពន្យល់ប្រជាជនថាសិល្បៈជាផ្នែកមួយនៃជីវិត។ មានកម្មវិធីសិល្បៈនៅក្នុងសាលារៀនឯកជន សាលារដ្ឋតាំងពីសាលាបឋមរហូតដល់វិទ្យាល័យ[...] បើនិយាយពីសិល្បៈនិងវប្បធម៌របស់កម្ពុជាគឺសម្បូរបែបណាស់។ ប៉ុន្តែពេលខ្ញុំមើលមកក្មេងៗសព្វថ្ងៃ រួមទាំងខ្ញុំខ្លួនឯងដែរ គឺមិនដឹងច្រើនអំពីសិល្បៈទេ។ ផ្ទុយទៅវិញ ក្មេងៗហាក់រក់នឹងភាពទាន់សម័យពីបរទេសដូចជា Kpop ជាដើម»*

(ក្រុមពិភាក្សា)។



តើវាជាសិទ្ធិនិងទំនួលខុសត្រូវរបស់អ្នកណាក្នុងការផ្សព្វផ្សាយពីសិល្បៈ? នេះគឺជាសំណួរដ៏គួរឱ្យចាប់អារម្មណ៍មួយនៅក្នុងបរិបទនៃការចូលរួមស៊ីវិល ប៉ុន្តែគួរឱ្យស្តាយនៅក្នុងកិច្ចពិភាក្សាជាច្រើនគឺគ្មានសំណួរនេះទេ។ សំណួរដែលថា«យើងគួរធ្វើឬរដ្ឋាភិបាលឬអាជ្ញាធរមូលដ្ឋានគួរធ្វើ?»គឺគ្មានទេ។ មានការទទួលយកនូវគំនិតដែលថាប្រសិនបើត្រូវធ្វើអ្វីមួយ ប្រជាជននឹងព្យាយាមធ្វើវាដោយខ្លួនឯង។ សូម្បីនៅក្នុងចំណោមសមាជិកនៃក្រុមពិភាក្សាក៏ពួកគេធ្វើផ្លូវពីភូមិទៅវត្តដោយខ្លួនឯងដែរ។ ទោះយ៉ាងណាមានអ្នកចូលរួមនៅក្នុងក្រុមពិភាក្សានៅខេត្តបាត់ដំបងបានចងភ្ជាប់ដោយប្រយោល បញ្ហានៃការចូលរួមរបស់ពលរដ្ឋក្នុងសង្គមទៅនឹងសំណួរអំពីសិទ្ធិនិងទំនួលខុសត្រូវដូចបានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់កម្ពុជា៖

*«ការចូលរួមរបស់ពលរដ្ឋក្នុងសង្គមមានន័យថាប្រជាពលរដ្ឋអាចធ្វើសកម្មភាពមួយចំនួននៅក្នុងសង្គមរបស់ពួកគេតាមរយៈការចូលរួមឬបញ្ចេញគំនិតនិងចែករម្លែកព័ត៌មានដោយសេរី។ សរុបទៅ មាត្រា៤៩នៃរដ្ឋធម្មនុញ្ញលើកឡើងពីសិទ្ធិរបស់ប្រជាពលរដ្ឋដែលមានន័យថាពួកគេមានសិទ្ធិចូលរួមក្នុងការងារសង្គមណាមួយមិនថាវាជាសកម្មភាពសិល្បៈ នយោបាយ ភាពជាអ្នកដឹកនាំឬសាសនា។ ប្រជាពលរដ្ឋត្រូវចូលរួមដោយសាមគ្គីភាព។ ប្រទេសយើងមិនអាចអភិវឌ្ឍបានទេបើយើងមិនរួមដៃគ្នា។ នេះជាអត្ថន័យនៃពាក្យការចូលរួមស៊ីវិល»។*

*«ខ្ញុំផ្ទាល់គិតថា ការចូលរួមរបស់ពលរដ្ឋក្នុងសង្គមគឺសំដៅលើការណ៍ដែលប្រជាពលរដ្ឋមានទំនួលខុសត្រូវក្នុងកសាងឬអភិវឌ្ឍប្រទេសរួមគ្នា។ គ្មានលេសអ្វីដែលមិនចូលរួមព្រឹត្តិការណ៍ណាមួយទេ។ យើងទាំងអស់គ្នាត្រូវចូលរួមគ្រប់សកម្មភាព»*

(ក្រុមពិភាក្សា)។

វាត្រូវបានមើលឃើញថាជាសិទ្ធិនិងទំនួលខុសត្រូវរបស់ប្រជាពលរដ្ឋក្នុងការចូលរួម ក្នុងកិច្ចការសង្គមសាមគ្គីភាព និងកិច្ចប្រឹងប្រែងសមូហភាព។ វាមានលក្ខណៈប្រជាធិបតេយ្យនៅពេលយល់ឃើញនៅក្នុងន័យបែបនេះព្រោះ *«ការចូលរួមរបស់ពលរដ្ឋក្នុងសង្គមក្នុងន័យនេះមានន័យថាប្រជាធិបតេយ្យ។ មានន័យថាប្រជាពលរដ្ឋអាចឈរជាស្នូល ហើយពួកគេអាចបញ្ចេញមតិឬចូលរួមក្នុងព្រឹត្តិការណ៍ណាមួយដោយសេរី»* *(ក្រុមពិភាក្សា)*។

ទោះយ៉ាងណាមានការរំពឹងទុកខ្លាំងជុំវិញតួនាទីនិងទំនួលខុសត្រូវរបស់សិល្បៈពីសំណាក់ទស្សនិកជន និងសិល្បករពាក់ព័ន្ធនឹងការផ្តល់ប្រយោជន៍ដល់សង្គម បង្ហាញមតិខ្លួនឯងនិងការកសាងសហគមន៍ជាដើម។ មហោស្រពពពណ៌ផ្តល់នូវការមើលឃើញស៊ីជម្រៅទៅក្នុងដំណើរការទាំងនេះនៅក្នុងចំណោមក្រុមយុវជនហាត់ការនិងការណ៍ដែលសិល្បៈនិងការបង្កើតព្រឹត្តិកាណ៍សិល្បៈអាចជំរុញការចូលរួមនៅក្នុងសង្គម។

# ០២

# ប្រភពដើមនិងអត្ថន័យមហោស្រពពលពណ៌



ដើមកំណើតនិងអត្ថន័យរបស់«មហោស្រពពលពណ៌»កើតចេញពីការចង់ផ្សាភ្ជាប់សិល្បៈនិងសង្គមនៅកម្ពុជា។ វាផុសចេញពីកិច្ចពិភាក្សាក្រុមអំពីថាតើអ្នកហាត់ការចង់ឱ្យមហោស្រពមានបង្ហាញគុណតម្លៃអ្វីនិងក្រោមមូលបទអ្វីខ្លះ។ កិច្ចសន្ទនាផ្តោតលើសិទ្ធិ នយោបាយនិងភាពភ័យខ្លាចក្នុងការនិយាយ។វាក៏នាំទៅដល់ការនិយាយពីលោកឯម រាម អ្នកច្នៃម៉ូដនិងជាសិល្បករដែលមកពីសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា សំណួរជុំវិញសេរីភាពនៃការបង្កើតការច្នៃប្រតិដ្ឋនិងការបញ្ចេញមតិពីអត្តសញ្ញាណជាអ្នកស្រឡាញ់ភេទដូចគ្នា។ មកដល់ត្រឹមនេះ អ្នកហាត់ការបានជជែកពិភាក្សាច្រើនថាតើពួកគេមានសេរីភាពប៉ុណ្ណាក្នុងការបញ្ចេញគំនិត ប៉ុន្តែពួកគេមិនច្បាស់ថាតើការច្នៃប្រតិដ្ឋ អត្តសញ្ញាណនិងសេរីភាពនៃការបញ្ចេញមតិមានទំនាក់ទំនងគ្នាយ៉ាងម៉េចទេ។ ដំបូង អ្នកហាត់ការចង់បានពាក្យ«សេរីភាព»នៅក្នុងចំណងជើងមហោស្រពព្រោះពួកគេមានអារម្មណ៍ថាពួកគេមានសំឡេងតិចមែនតែអាចប្រើសិល្បៈដើម្បីបញ្ចេញវាបាន។ មានការជជែកពិភាក្សាច្រើនអំពីភាពរសើបនិងដែនកំណត់នៃការប្រើប្រាស់ពាក្យនេះ។ បន្ទាប់មកពួកគេនិយាយអំពីក្តីសង្ឃឹមជាជាងសេរីភាព ហើយចេញពីនេះពួកគេក៏បោះគំនិតលើពណ៌និងឥន្ទធនូ។ ចំណងជើងក៏ចាប់ផ្តើមវិវឌ្ឍដោយបែបនេះ។ ទោះយ៉ាងណាចំណងជើងនេះបានកើតចេញពីកិច្ចពិភាក្សាអំពីនយោបាយនិងសង្គមស៊ីវិល និងការចង់ភ្ជាប់បញ្ហាសំខាន់ៗនៅក្នុងវិស័យនេះជាមួយនឹងសិល្បៈ។ គួរកត់សម្គាល់ថានៅក្នុងបរិបទកម្ពុជា កិច្ចពិភាក្សានេះគឺអំពីសេរីភាពនៃការបញ្ចេញមតិ មិនពាក់ព័ន្ធនឹងការចង់ផ្តួលរំលំរដ្ឋាភិបាលទេ (ពលពណ៌តែមិនពាក់ព័ន្ធនឹងចរន្ត«បដិវត្តន៍ពណ៌»ដែលរដ្ឋាភិបាលលើកឡើងថ្មីៗនេះទេ)។

**ប៉ុន្តែនេះជាការពន្យល់ដោយប្រើពាក្យរបស់ពួកគេផ្ទាល់៖**

> *«មហោស្រពពលពណ៌ជាកម្មវិធីសិល្បៈមួយ ដែលផ្សាភ្ជាប់សង្គមជាមួយនឹងគោលបំណងនៃភាពចម្រុះរបស់សង្គមនិងឆ្លុះបញ្ចាំងពីតួនាទីរបស់សិល្បៈក្នុងការផ្សាភ្ជាប់យុវជនជាមួយសង្គមដើម្បីលើកស្ទួយភាពចម្រុះក្នុងសង្គមនិងបរិយាបន្នសង្គមតាមរយៈការបង្ហាញស្នាដៃសិល្បៈ កិច្ចពិភាក្សានិងការចែករំលែកចំណេះដឹងនិងបទពិសោធន៍របស់មនុស្សនៅក្នុងសង្គម»*
>
> (សំណាង អ្នកហាត់ការ)។

សម្រាប់អ្នកហាត់ការ ចំណងជើងឆ្លុះបញ្ចាំងនិងផ្សព្វផ្សាយពីភាពចម្រុះ។ វាធ្វើឱ្យគិតដល់ឥន្ទធនូនិងផ្សាភ្ជាប់ទៅអត្តសញ្ញាណអ្នកស្រឡាញ់ភេទដូចគ្នា ។ ប្រាកដណាស់នេះជាអ្វីដែលពួកយើងក្នុងនាមជាអ្នកស្រាវជ្រាវ និងជាបុគ្គលិករបស់សិល្បៈខ្មែរអមតៈបានគិតដល់។ ទោះយ៉ាងណា គំនិតនៃពាក្យប្រាំពីរពណ៌គឺទូលាយជាងនេះ ដោយសារវាតំណាងឱ្យការផ្សព្វផ្សាយពីភាពចម្រុះជាទូទៅ (ជនជាតិដើម សាសនា អាយុ យេនឌ័រ ជំនាន់)។ និយាយឱ្យជាក់លាក់ជាងនេះទៀត វាចងភ្ជាប់មហោស្រពទៅនឹងវប្បធម៌កម្ពុជាបើនិយាយពីការគិតនិងជំនឿដែលលេខ៧គឺសំខាន់ណាស់។ វាបង្ហាញពី៧ថ្ងៃក្នុងមួយសប្ដាហ៍និងការផ្សាភ្ជាប់ទៅនឹងការប្រើពណ៌ខុសៗគ្នាប្រចាំថ្ងៃ។ គំនិតនៃញាតិទាំង៧សន្តាន (ដូនតា៣ជំនាន់ កូនចៅ៣ជំនាន់ និងជំនាន់ខ្លួនមួយ) គឺជាគំនិតបូរមបូរាណនៅក្នុងវប្បធម៌កម្ពុជា គឺដូចការដែលត្រូវគិតនិងគ្រលាស់អណ្ដាត៧ដងមុននិយាយអ៊ីចឹងដែរ។ ក្នុងន័យនេះ ចំណងជើងរបស់មហោស្រពគឺពហុអត្ថន័យមានន័យថាផ្សាភ្ជាប់នឹងវប្បធម៌និងសង្គមកម្ពុជា។

ក្នុងកម្រិតធម្មតា ពីដំបូង អ្នកហាត់ការមើលឃើញពីលទ្ធភាពដែលសិល្បៈរួមចំណែកបែបវិជ្ជមានទៅក្នុងសង្គម និងផ្សាភ្ជាប់ជាមួយយុវជន។ ចំណុចនេះក៏ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងគោលបំណងមហោស្រពដែរ៖

**០១** ជំរុញការចូលរួមរបស់យុវវ័យក្នុងការអភិវឌ្ឍសង្គមតាមរយៈសិល្បៈច្នៃប្រតិដ្ឋ។

**០២** លើកស្ទួយការគោរពនិងការឱ្យតម្លៃលើអត្តសញ្ញាណ។

**០៣** បង្កើតកិច្ចសន្ទនាអំពីទំនាក់ទំនងរវាងសិល្បៈនិងការអភិវឌ្ឍសង្គម។





ស្របពេលជាមួយគ្នានេះដែរ ពួកគេមានគំនិតប្រើពាក្យ«ដែកទាម»ជាមូលបទ ដែលប្រើក្នុងស្ថាបត្យកម្មខ្មែរបុរាណដើម្បីតភ្ជាប់ដុំថ្មប្រាសាទ។ នៅក្នុងន័យនេះ ពួកគេគិតអំពីការតភ្ជាប់ឆ្លងជំនាន់ ឆ្លងក្រុមផ្សេងៗនិងគំនិតផ្សេងៗ។ នេះជាវិធីងាយស្រួលក្នុងការក្ដោបគំនិតអ្វីដែលពួកគេចង់ធ្វើ។ ទោះយ៉ាងណាពេលធ្វើការរចនាកម្មវិធីមហោស្រព វាក្លាយទៅជាពិបាកនិងច្របូកច្របល់ក្នុងការដំឡើង។អ្នកហាត់ការមានអារម្មណ៍ថាពួកគេវង្វេងវង្វាន់ ដូច្នេះក៏សម្រួលការផ្ដោតមូលបទលើយុវជនវ័យក្មេង ស្របពេលដែលរក្សាគោលបំណងសំខាន់របស់មហោស្រពនៅដដែល។ពួកគេសម្រេចរួមគ្នាលើមូលបទសម្រាប់ថ្ងៃមួយៗនៃមហោស្រពដែលមានរយៈពេល៣ថ្ងៃ ៖ យុវជននិងអតីតកាល យុវជននិងបច្ចុប្បន្ន យុវជននិងអនាគត។ វាបានជួយសម្រួលដល់ការសម្រេចចិត្តរបស់ពួកគេអំពីអ្វីដែលត្រូវដាក់បញ្ចូលក្នុងកម្មវិធីនិងការរចនាមហោស្រព។ ទោះយ៉ាងណា ពេលអនុវត្តផ្ទាល់ វានាំឱ្យមានភាពស្មុគស្មាញមួយកម្រិតទៀតក្នុងការសម្រេចចិត្ត។ សម្រាប់ការជ្រើសរើសកម្មវិធីខ្លះ ជម្រើសនិងការសម្រេចចិត្តមិនចេះតែត្រូវនឹងមូលបទនិងគំនិតរបស់មហោស្រព ឬក៏មិនបានគិតឱ្យបានដិតដល់ (ឧទាហរណ៍ តើគួរហៅយ៉ាងម៉េចពេលរបាំបុរាណនិងរបាំជនជាតិដើមត្រូវដាក់ក្នុងផ្នែក«អតីតកាល» តើវាមានន័យថាម៉េចបើការប្រគំតន្ត្រីសម័យមានសុទ្ធតែអ្នកចម្រៀងប្រុសស្ថិតក្នុងផ្នែក «អនាគត» តើគុណតម្លៃផ្នែកសិល្បៈនិងសង្គមអ្វីខ្លះដែលចង់លើកស្ទួយ?)




# ការបង្កើតកម្មវិធី

អ្នកហាត់ការជួបគ្នាជាប្រចាំអំឡុងខែដំបូងៗជាមួយអ្នកសម្របសម្រួលគឺលោក សុង សេង និងកញ្ញា សាយ តុលា (ដែលបានជួយទាំងការសម្របសម្រួលមហោស្រពទាំងការស្រាវជ្រាវ)។ អាម៉ាន់ដា រ៉ូជើស៍ ក៏មានវត្តមានច្រើនដងនៅក្នុងការប្រជុំទាំងនេះដែរនៅដំណាក់កាលដំបូងៗនិងដំណាក់កាលក្រោយៗមកទៀត។ ការប្រជុំដំបូងៗមានជំនួបជាច្រើនជាមួយសិល្បករដែលចែករំលែកបទពិសោធន៍របស់ពួកគេក្នុងការរៀបចំមហោស្រពនិងផលិតកម្មវិធី។ អ្នកហាត់ការរួមគ្នាប្រមូលគំនិតអំពីអ្វីដែលពួកគេចង់ដាក់ជាគោលបំណងរបស់មហោស្រព មូលបទនិងចំណងជើងផងដែរ។ ទាំងអស់នេះត្រូវបានសម្រេចជាមុនដោយក្រុមនិងទុកជាតម្រុយសម្រាប់ដំណើរការទាំងមូល។ វាអនុញ្ញាតឱ្យអ្នកហាត់ការក្លាយជាម្ចាស់មហោស្រពតែម្តង។ បន្ទាប់មកអ្នកហាត់ការត្រូវបានស្នើឱ្យសិក្សាពីកម្មវិធីចាស់ៗរបស់រដូវវប្បធម៌ និងគិតថាតើស្នាដៃអ្វីខ្លះអាចនឹងបង្ហាញឡើងវិញ ហើយតើវាស្របតាមគោលបំណងនិងមូលបទរបស់មហោស្រពពួកគេទេ។ តាមរយៈការសង្កេតដំណើរការទាំងអស់នេះ លោកសុង សេង ក្នុងនាមជាអ្នកសម្របសម្រួល បានផ្តល់សេរីភាពនិងការគាំទ្រពេញទំហឹងដល់ពួកគេក្នុងការជ្រើសរើស។ គាត់តែងតែលើកទឹកចិត្តពួកគេឱ្យមានការច្នៃប្រតិដ្ឋនិងគិតចេញក្រៅពីប្រអប់ ដូច្នេះពួកគេអាចបញ្ចូលការសម្តែងផ្សេងៗទៀតដែលពួកគេធ្លាប់ឃើញនិងនាំយកគំនិតថ្មីៗមកពិភាក្សា។ គាត់មិនចង់ឱ្យពួកគេរាំងស្ទះដោយសារកង្វល់ថាគួរធ្វើមហោស្រពដូចម្តេចឬថាតើមហោស្រពគួរតែមានរូបរាងយ៉ាងម៉េចនោះទេ។



ពីដំបូង អ្នកហាត់ការគាំងខ្លាំងនឹងទម្រង់នៃរដូវវប្បធម៌ដែលគេបានមើល ហើយហាក់មិនសូវជជែកពីការចូលចិត្តរបស់ពួកគេទេ។ ពួកគេមានគំនិតខុសគ្នា ប៉ុន្តែហាក់ទទួលយកវា ហើយ *«សរសេរសិនទៅចាំសម្រេចពេលក្រោយ»* *(កំសត់និយាយទៅកាន់សំណាង)* ។ ពេលពួកគេមានភាពម្ចាស់ការនិងជឿជាក់ជាងមុន ពេលខ្លះពួកគេជួបគ្នាដោយមិនចាំបាច់មានសេងឬតុលា ប៉ុន្តែការណ៍នេះបាននាំរកការទាស់ទែងគំនិត និងពាក្យសម្តីគ្នាដែរ (ឧ.ជុំវិញការរចនាស្លាកសញ្ញាសម្រាប់មហោស្រព)។ ទោះបីមានការពិភាក្សាពីកម្មវិធីរួមមួយក៏ដោយ សេងបានឱ្យពួកគេម្នាក់ៗធ្វើកម្មវិធីរៀងខ្លួនដើម្បីឱ្យពួកគេអាចផ្តោតលើអ្វីដែល ម្នាក់ៗចង់បាន។ បន្ទាប់មកពួកគេចែករំលែកនិងពិភាក្សាជាមួយក្រុម។ សេងបានឱ្យពួកគេធ្វើកម្មវិធីរួមមួយដោយផ្អែកលើគំនិតពួកគេផ្ទាល់ ហើយជ្រើសរើសស្នាដៃចាស់ៗដែលបង្ហាញដោយសិល្បៈខ្មែរអមតៈ។ អំឡុងពេលដំណើរការនេះ ពួកគេចាប់ផ្តើមដឹងថាពួកគេមិនឃើញមានស្នាដៃដែលត្រូវបានបង្ហាញនៅក្នុងរដូវវប្បធម៌របស់សិល្បៈខ្មែរអមតៈ ផ្តោតលើកង្វល់របស់យុវជនទេ គឺមានតែរាង«ចាស់គំរិល»បន្តិច ហើយមើលឃើញថាស្នាដៃទាំងអស់នោះគឺសម្រាប់អ្នកដែលមានបទពិសោធន៍ច្រើនផ្នែកសិល្បៈជាជាងសម្រាប់អ្នកដែលត្រូវការស្វែងយល់ដំបូងអំពីសិល្បៈ៖

*«យើងមានមូលបទនិងគោលបំណងរបស់យើង។ កម្មវិធីយើងធ្វើឡើងសម្រាប់យុវវ័យ កម្មវិធីរដូវវប្បធម៌ត្រូវនឹងប្រធានបទរបស់គេ។ យើងមិនចង់ធ្វើតាមបែបរបស់សិល្បៈខ្មែរអមតៈទេ យើងចង់មានអ្វីថ្មីសម្រាប់យុវវ័យ»*

(កិច្ចសម្ភាសន៍មាយ បុប្ផារតនៈ)។

ទោះយ៉ាងណាពួកគេត្រឡប់ទៅគំនិតដើមរបស់ពួកគេ ហើយកែតម្រូវដាក់បញ្ចូលក្នុងកម្មវិធីដែលពួកគេបង្កើតរួមគ្នា។ វាបញ្ចូលគ្នានូវបែបផែនរបស់សិល្បៈខ្មែរអមតៈនិងគំនិតរបស់ពួកគេផ្ទាល់ខ្លះ ហើយកែសម្រួលលម្អិតជាមួយសេងនិងតុលាមុននឹងបង្ហាញទៅថ្នាក់ដឹកនាំរបស់សិល្បៈខ្មែរអមតៈដើម្បីទទួលបានការណែនាំ។ បន្ទាប់មកគឺ«ស្ងាត់ជ្រៀប»គ្មានអ្វីកើតឡើងច្រើនទេ ហើយការចូលរួមរបស់អ្នកហាត់ការហាក់ធ្លាក់ចុះដោយសារពួកគេចំណាយពេលច្រើនក្នុងការបំពេញភារកិច្ចដែលដាក់ឱ្យ។ អ្នកហាត់ការចង់ធ្វើច្រើនជាងនេះ ជាពិសេសជុំវិញការផ្សាយពាណិជ្ជកម្មនិងបណ្តាញសង្គម ហើយពួកគេតែងតែនិយាយពីរឿងនេះ។ទោះយ៉ាងណាសកម្មភាពពួកគេមិនត្រូវតាមឆន្ទៈដែលពួកគេលើកឡើងរហូតនោះទេ ហើយពេលពួកគេទទួលការបែងចែកការងារ គឺតែងតែប្រទាំងប្រទើសនឹងតារាងពេលវេលាផ្សេងទៀតនៃជីវិតរបស់ពួកគេ (ឧ.កិច្ចការសាលាការងារនៅកន្លែងធ្វើការសុខភាព។ល។)។ មានន័យថាពួកគេ មិនបានធ្វើការងារដែលដាក់ឱ្យឬធ្វើដែរតែយឺត។ មានមូលហេតុផ្សេងទៀតនៅក្នុងរឿងនេះដែលយើងនឹងលើកមកពិភាក្សានៅផ្នែកទី៤។ ប៉ុន្តែបញ្ហាសំខាន់គឺពីដំបូងឡើយ អ្នកហាត់ការបានចុះកិច្ចសន្យាតែលើការរចនាមហោស្រពមិនមែនដំណើរការផលិតកម្មមហោស្រពទាំងមូលទេ ប៉ុន្តែក្រោយមកពួកគេត្រូវបានស្នើឱ្យធ្វើលើសពីនេះ។ អ្នកហាត់ការបានគូសបញ្ជាក់ពីភាពខុសគ្នារវាងការងារស្ម័គ្រចិត្តនិងការងារជាក់ស្តែង ព្រោះថាការធ្វើមហោស្រពមួយគឺធំណាស់សម្រាប់ពួកគេ។ ការរំពឹងទុកប្រហែលខ្ពស់ខ្លាំងពេក។ ពិតណាស់ អ្នកហាត់ការម្នាក់មិនមានវត្តមានពេលមហោស្រពទេ ប៉ុន្តែទៅចូលរួមកម្មវិធីបណ្តុះបណ្តាលនៅប្រទេសថៃ ទោះបីគេបង្ហោះព័ត៌មានអំពីមហោស្រពនៅលើបណ្តាញសង្គមនិងទូរស័ព្ទមកក្រុមហាត់ការអំឡុងពេលមហោស្រពដើម្បីជួយសម្របសម្រួលក៏ដោយប៉ុន្តែគេមិនអាចមកជួយផ្ទាល់បានទេ។យើងមិនអាចងាកទៅរកអ្វីផ្សេងមកជួយសម្រាប់ស្ថានភាពបែបនេះទេ។

ដើម្បីឱ្យដំណើរការទៅមុខ អ្នកហាត់ការបានកត់ទុកមតិយោបល់វិជ្ជមាននិងប្លែកៗមួយចំនួនរបស់សិល្បៈខ្មែរអមតៈ។ ការណែនាំដ៏សំខាន់មួយដែលពួកគេបានទទួលគឺកុំឱ្យដូរទីកន្លែងរៀបចំកម្មវិធីច្រើន ដោយសារវាត្រូវការជំនួយផ្នែកបច្ចេកទេសច្រើនជាងអ្វីដែលអាចទៅរួច។ ពួកគេមិនបានគិតដល់រឿងទីតាំងរៀបចំព្រឹត្តិការណ៍ជាក់ស្តែងទេព្រោះពួកគេមិនដឹងពីរឿងនេះ ហើយវាជាអ្វីដែលពួកគេបានរៀនសូត្រនិងអនុវត្តតាម។ ជាលទ្ធផល មហោស្រពប្រារព្ធធ្វើនៅតែមួយកន្លែង (Coconut Park) ដោយមានការបញ្ចាំងភាពយន្តនៅមជ្ឈមណ្ឌលបុប្ផាណា។ អ្នកហាត់ការក៏ព្រមទទួលយកការណែនាំឱ្យបង្ហាញរបាំបុរាណនៅយប់ថ្ងៃទី១ ជាពិសេសរបាំជនជាតិដើមដែលពួកគេមិនបានដឹងច្រើនទេ ប៉ុន្តែពួកគេចង់មើល។ ពួកគេក៏ត្រូវបានលើកទឹកចិត្តឱ្យមានព្រឹត្តិការណ៍«គួរឱ្យភ្ញាក់ផ្អើល»ច្រើននៅយប់ថ្ងៃទី១ដែរ ដើម្បីជួយបង្កើតភាពភ្ញាក់ផ្អើលអំពីមហោស្រពនិងទាក់ទាញមនុស្សឱ្យចូលទស្សនាជាជាងការផ្តោតតែទៅលើការប្រគំតន្ត្រីនៅចុងបញ្ចប់។ ជាលទ្ធផល ពួកគេបានបញ្ចូលរបាំនិងតន្ត្រីស្គរដៃប៉ុកដែលទស្សនិកជនអាចចូលរាំបាននៅចុងបញ្ចប់នៃកម្មវិធីយប់ថ្ងៃទី១។

អ្នកហាត់ការបានរៀនសូត្រច្រើនអំពីសិល្បៈអំឡុងពេលរចនាកម្មវិធី ការរៀបចំថវិកា ទីតាំង សិល្បករដែលទំនេរនិងការរួមបញ្ចូលមធ្យោបាយសមស្របដែលចុងបញ្ចប់ទៅពួកគេធ្វើព្រឹត្តិការណ៍មួយដែលមិនខុសពីអ្វីដែលពួកគេចាប់ផ្តើមពីដំបូង។ ឧទាហរណ៍មាយ បុប្ផារតនៈ និងអ៊ុក លីគួយយូ បានដាក់ស្នើរបាំមណីមេខលាដែលពួកគេចូលចិត្ត មិនមែនដោយសារវាជារបាំបុរាណទេ ប៉ុន្តែដោយសារពួកគេមើលឃើញថា វាជារបាំបុរាណអំពីស្ត្រីរឹងមាំម្នាក់។ ឃឿន កំសត់ ក៏ចូលចិត្តរបាំនេះដែរ ដូច្នេះពួកគេសុទ្ធតែចង់បង្ហាញរបាំនេះនៅចុងបញ្ចប់នៃកម្មវិធី។ សិក្ខាសាលាពីសុខភាពផ្លូវចិត្ត សិទ្ធិមនុស្ស សូនរូបដីឥដ្ឋ ការបង្ហាញទេពកោសលចម្រុះ ទាំងអស់នេះសុទ្ធតែជារឿងដែលក្រុមអ្នកហាត់ការគិតថាសំខាន់ចំពោះពួកគេ ហើយក៏សំខាន់ចំពោះយុវជននៅកម្ពុជាដែរ។ ចំណុចទាំងអស់នេះសុទ្ធតែមាននៅក្នុងពេលប្រមូលគំនិតដំបូងៗ ហើយនៅចុងបញ្ចប់ក៏មានបញ្ចូលនៅក្នុងកម្មវិធី (ទោះបីវាបាត់មួយរយៈអំឡុងពេលនៃការរកមើលស្នាដៃសិល្បៈដែលបង្ហាញដោយសិល្បៈខ្មែរអមតៈក៏ដោយ)។ ក្នុងរយៈពេល៦ខែ ក្រុមអ្នកហាត់ការបានអភិវឌ្ឍជាពិសេសលើភាពជឿជាក់លើខ្លួនឯងនិងបំណិនជីវិត ប៉ុន្តែអ្វីដែលពួកគេចូលចិត្តមិនបានផ្លាស់ប្តូរទេ។ ពិតណាស់នៅក្នុងមហោស្រពនេះ មានសម្តែងស្នាដៃសិល្បៈតែមួយប៉ុណ្ណោះដែលមានប្រភពចេញពីកម្មវិធីរបស់សិល្បៈខ្មែរអមតៈ (ល្ខោនអានរឿង កូនមើលហ្នំ! ឥន្ទធនូស្អាតណាស់! ដែលនិយាយអំពីការយល់ព្រមទទួលយកភាពជាអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងរង្វង់គ្រួសារ)។ ព្រឹត្តិការណ៍រដូវវប្បធម៌របស់សិល្បៈខ្មែរអមតៈគឺអស់ថ្លៃជាងសកម្មភាពសិល្បៈប្រភេទផ្សេងៗទៀត (ឧ.ការសម្តែងការប្រគំតន្ត្រី) ដោយសារប្រាក់ខែនិងពេលវេលាហាត់សម។ ការជួលទីតាំងក៏ថ្លៃដែរ គឺអស់ច្រើនជាងអ្វីដែលយើងគិត។ ចំណុចនេះនាំឱ្យមានការលើកឡើងថាតើយុវជនអាចបង្កើតព្រឹត្តិការណ៍ផ្សព្វផ្សាយពីសិល្បៈដោយឯករាជ្យពីអង្គការនិងម្ចាស់ជំនួយធំៗយ៉ាងម៉េចកើត។ ជាលទ្ធផល ស្នាដៃជាច្រើនដែលសិល្បៈខ្មែរអមតៈបង្ហាញ គឺមិនអាចយកមកសម្តែងបានទេ ហើយក្រុមអ្នកហាត់ការចង់បានស្នាដៃខ្លីៗ ទោះបីពួកគេសោកស្តាយដែលមិនអាចបង្ហាញល្ខោននិយាយរឿងជម្រើសខ្ញុំ ក៏ដោយ។



# កម្មវិធីមហោស្រព

កម្មវិធីសម្រេចចុងក្រោយគឺចាប់ពីថ្ងៃទី៨ដល់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣ ដោយមានព្រឹត្តិការណ៍បីថ្ងៃជាប់គ្នា និងពិព័រណ៍រូបថតរបស់អ្នកមិនមែនជាអ្នកថតរូបអាជីព ស្តង់អាហារនិងភេសជ្ជៈ។

# ថ្ងៃទី ១

## «យុវជននិងអតីតកាល»

### យប់បើកកម្មវិធី

ការបង្ហាញខ្លីៗពីទម្រង់ផ្សេងៗនៃរបាំបុរាណនិងតន្ត្រី រួមមានភ្លេងមហោរី របាំជូនពរ របាំមណីមេខលា និងតន្ត្រីស្គរប៉ុក។











# ថ្ងៃទី ២

*«យុវជននិងបច្ចុប្បន្ន»*



## ពេលព្រឹក

សិក្ខាសាលា «ការថែទាំសុខភាពផ្លូវចិត្ត»



## ពេលរសៀល

ទិដ្ឋភាពសង្គមពីក្រសែភ្នែកយុវជន - អានដោយអ្នកនិពន្ធវ័យក្មេង



## ពេលល្ងាច

ការសម្តែងផ្សេងៗ រួមមានរបាំប្រពៃណី ដូចជា របាំភោគផលនិងរបាំបេះក្រវាញ ល្ខោនអានកូនមើលហ្នំ! ឥន្ទធនូស្អាតណាស់! របាំសហសម័យ ដោយក្រុម SilverBelle និងការសម្តែងរបស់ក្រុមស្គរស្រ្តី មេធា។











# ថ្ងៃទី ៣

*«យុវជននិងអនាគត»*



## ពេលព្រឹក

វេទិកាពិភាក្សាពីតួនាទីយុវជន នៅក្នុងការចូលរួមអភិវឌ្ឍសង្គមតាមរយៈសិល្បៈ ការសម្តែងបទចម្រៀងអំពីគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ និងដើមឈើសារបំណងដែលអ្នកចូលរួមអាចសរសេរសារទុកសម្រាប់អនាគត។



## ពេលរសៀល

សិក្ខាសាលាជំនាញសិល្បៈ ដូចជាសូនរូបដីឥដ្ឋ គំនូររបាំប្រពៃណីនិងសហសម័យ ការនិពន្ធទំនុកចម្រៀង ការបញ្ចាំងភាពយន្តនៅមជ្ឈមណ្ឌលបុប្ផាណា។





## ពេលល្ងាច

ការបង្ហាញទេពកោសល្យចម្រុះ ការប្រកាសអ្នកឈ្នះ ការប្រកួតរូបថត ការសម្តែងអត្តសញ្ញាណ និងការប្រគំតន្ត្រីប៉បនិងហ៊ីបហបជាមួយតន្ត្រីករចម្រុះ។















អ្វីដែលលេចធ្លោគឺថា នៅក្នុងកម្មវិធីជាការ«រើសនិងលាយ»យ៉ាងប៉ិនប្រសប់ដើម្បីលើកស្ទួយការចូលរួមសកម្ម ដោយមានការសម្តែងខ្លីៗ វេទិកាពិភាក្សានិងសិក្ខាសាលា។ កម្មវិធីទាំងនេះទាក់ទាញយុវជនផងខណៈដែលលើកឡើងពីកង្វល់សំខាន់ៗក្នុងសង្គមផង ដូចដែលក្រុមអ្នកហាត់ការពិពណ៌នា *«យើងព្យាយាមផ្សាភ្ជាប់យុវជននិងសិល្បៈ ហើយនិងបញ្ហារបស់យុវជនតាមរយៈសិល្បៈ មិនមែនបញ្ហាទូទៅទេ។ ប៉ុន្តែខ្ញុំគិតថា វាឆ្លើយតបនឹងការចង់បានរបស់យើងគឺការផ្សាភ្ជាប់យុវជននិងសិល្បៈតាមរយៈមហោស្រពរបស់យើង»* *(កិច្ចសម្ភាសន៍សុទ្ធ ពៅ សំណាង)*។ អ្នកសម្របសម្រួលមហោស្រព លោកសុង សេង គូសបញ្ជាក់ថា ក្រុមអ្នកហាត់ការរចនាមហោស្រពបែបផ្សេងធៀបនឹងសិល្បករដោយសារចំណាប់អារម្មណ៍របស់ពួកគេជាយុវជន។ វារួមមានការផ្តោតលើសុខភាពផ្លូវចិត្តនិងសុខុមាលភាព សិទ្ធិមនុស្ស ភាពចម្រុះ សមភាព និងការប្រើបណ្តាញសង្គម ជាជាងការផ្តោតលើតែវប្បធម៌ខ្មែរឬអត្តសញ្ញាណជាតិ។ *«ប្រសិនបើធ្វើការជាមួយសិល្បករប្រហែលពួកគេមិនប្រើពាក្យ ឬផ្តោតលើចំណុចទាំងអស់នោះទេ»* *(កិច្ចសម្ភាសន៍សុង សេង)*។ ពិតណាស់ កម្មវិធីមហោស្រពគឺខុសប្លែកគេបើនិយាយពីភាពចម្រុះនិងទម្រង់ និងការសម្តែងខ្លីៗ។ នេះជាជម្រើសរបស់ក្រុមអ្នកហាត់ការដែលមើលឃើញថាការសម្តែងវែងពេកធ្វើឱ្យពិបាកផ្ទង់អារម្មណ៍និងមិនសូវគួរឱ្យចាប់អារម្មណ៍។ ដោយសារពួកគេជាក្មេងជំនាន់ Tik Tok ពួកគេចូលចិត្តរឿងខ្លីដែលងាយស្រួលមើល ហើយពួកគេគិតថាអាចទាក់ទាញយុវជនចូលក្នុងសិល្បៈ។ ជាលទ្ធផល គ្មានការសម្តែងមួយណាវែងជាង២០នាទីទេ។ ក្រុមអ្នកហាត់ការបារម្ភពីការធ្វើឱ្យសាធារណជនចូលមើលមហោស្រព ឧទាហរណ៍សិក្ខាសាលាពីគំនូរ សូនរូបដីឥដ្ឋ រាំ និងនិពន្ធទំនុកចម្រៀង គឺអនុញ្ញាតឱ្យមានការចូលរួមដោយផ្ទាល់ក្នុងសិល្បៈ ដោយគ្មានគំនាបឬការរំពឹងលើភាពជំនាញ។ កម្មវិធីទាំងអស់នេះបើកឱ្យសាធារណជនសាកល្បងតែប៉ុណ្ណោះ។ បន្ថែមលើនេះទៀត ក្រុមអ្នកហាត់ការថែមទាំងបានពិពណ៌នាពីមហោស្រពប្រាប់ទៅមិត្តភក្តិទៀតផង ដើម្បីឱ្យប្រាកដថាយុវជនដែលគ្មានបទពិសោធន៍ពីសិល្បៈអាចយល់បាន។

មានធាតុបីដែលត្រូវយកចិត្តទុកដាក់នៅពេលគិតអំពី ទំនាក់ទំនងរវាងក្រុមអ្នកហាត់ការនិងមហោស្រពក្នុងទម្រង់ជាការចូលរួមរបស់ពលរដ្ឋក្នុងសង្គម៖

- ទី១គឺរបៀបដែលដំណើរការ នៃការរចនានិងបង្កើតមហោស្រពបង្ហាញធាតុផ្សេងៗនៃការចូលរួមរបស់ពលរដ្ឋក្នុងសង្គមឬអភិវឌ្ឍជំនាញសម្រាប់រឿងនេះ។

- ទី២គឺរបៀបដែលមហោស្រព និងកម្មវិធីមហោស្រពលើកកម្ពស់ការចូលរួមសកម្មតាមរបៀបដែលឆ្លុះបញ្ចាំងពីយុវជននិងកង្វល់របស់សង្គមស៊ីវិល។

- ចុងក្រោយគឺគិតពីឥទ្ធិពលនៃការចូលរួមក្នុងមហោស្រពចំពោះទស្សនិកជននិងអ្នកស្ម័គ្រចិត្ត។



នៅផ្នែកទី ៣ នឹងផ្តោតលើចំណុចទី ១ ខាងលើ ផ្នែកទី ៤ ផ្តោតលើចំណុចទី ២ និងផ្នែកទី ៥ ផ្តោតលើចំណុចទី៣។.

# ០៣

# ការរចនា
# កម្មវិធីមហោស្រព

**ពេលល្ងាច ការរចនានិងការអភិវឌ្ឍដំណើរការផ្សព្វផ្សាយធាតុផ្សេងៗនៃការចូលរួមរបស់ពលរដ្ឋក្នុងសង្គមតាមរយៈ**

- ការស្វែងយល់អំពីសិល្បៈ
- ការអនុវត្ត និងរៀនជំនាញដែលជួយដល់ការចូលរួមរបស់ពលរដ្ឋក្នុងសង្គម។



# ការស្វែងយល់អំពីសិល្បៈ

រឿងសំខាន់មួយដែលក្រុមអ្នកហាត់ការចង់បានអំឡុងដំណើរការរចនាមហោស្រពគឺការយល់ដឹងបន្ថែមអំពីសិល្បៈ។ ពួកគេសុទ្ធតែអះអាងពីការស្រឡាញ់សិល្បៈតាំងពីដំបូង ប៉ុន្តែពួកគេចង់ដឹងបន្ថែម។ ដូចបញ្ជាក់ខាងលើ ការចែករំលែកចំណេះដឹងនិងការរៀនសូត្រពីសិល្បៈត្រូវបានគេមើលឃើញថាជាផ្នែកមួយនៃការចូលរួមស៊ីវិលនៅក្នុងចំណោមយុវជន។ នេះព្រោះតែសិល្បៈត្រូវបានគេមើលឃើញថាមានគុណតម្លៃវប្បធម៌ចំពោះជាតិ ថែរក្សាវប្បធម៌និងអត្តសញ្ញាណឱ្យគង់វង្ស និងផ្សាភ្ជាប់នឹងសង្គម។ តាំងពីលើកដំបូងពេលជួបសួរពួកគេពីអ្វីដែលពួកគេសង្ឃឹមទទួលបានតាមរយៈការរចនាមហោស្រពនេះ ក្រុមអ្នកហាត់ការប្រាប់ថាពួកគេចង់រៀនបន្ថែមពីដំណើរការច្នៃប្រតិដ្ឋនិងកម្លាំងជំរុញរបស់សិល្បករ រួមមានតើសិល្បករបានគំនិតមកពីណា តើពួកគេផ្សាភ្ជាប់នឹងសង្គមដូចម្តេច ហើយតើពួកគេធ្វើដូចម្តេចឱ្យស្នាដៃពួកគេទាក់ទាញទស្សនិកជន។ ក្រុមអ្នកហាត់ការក៏ចង់រៀនពីប្រវត្តិទម្រង់សិល្បៈនិងអត្ថន័យរបស់វាផងដែរ ព្រោះពួកគេមានអារម្មណ៍ថាពួកគេដឹងខ្លះៗពីសិល្បៈ ប៉ុន្តែមិនទាន់គ្រប់គ្រាន់។ ឧទាហរណ៍ពេលជួបគ្នាដំបូងៗ ពេលពួកគេប្រមូលគំនិត ក្រុមអ្នកហាត់ការមិនស្គាល់ពាក្យបច្ចេកទេសឬឈ្មោះទម្រង់សិល្បៈផ្សេងៗទេ។ ការមើលកម្មវិធីចាស់ៗរបស់រដូវវប្បធម៌ជំរុញពួកគេឱ្យបានមើលឃើញទម្រង់ផ្សេងៗនិងបញ្ជាក់ពីកង្វះការយល់ដឹងរបស់ពួកគេក្នុងវិស័យនេះ។

ពីមុនមកក្រុមអ្នកហាត់ការធ្លាប់បានឃើញនិងចូលរួមក្នុងសិល្បៈទស្សនីយភាពបុរាណដែរ។ នៅពេលពួកគេទទួលបានបទពិសោធន៍ប្លែកពីមុន បានឃើញទម្រង់សិល្បៈប្លែកពីមុន គឺអាចពត់ការគិតនិងការចូលចិត្តដើមដំបូងរបស់ពួកគេបាន។ ឧទាហរណ៍ លីគួយយូចូលចិត្តល្ខោននិយាយ ភាពយន្តនិងតន្ត្រី រតនៈចូលចិត្តសិល្បៈបុរាណដោយសារទទួលឥទ្ធិពលពីគ្រូៗរបស់នាង កំសត់ចូលចិត្តរបាំបុរាណ សំណាងមានបទពិសោធន៍ច្រើនទាក់ទងនឹងសិល្បៈនិងមានចំណេះដឹងច្រើនដែរ។ ចំណុចរួមគឺថាពួកគេមិនយល់ពីសិល្បៈសហសម័យទាំងស្រុងទេ (មិនថាទម្រង់សូន្យរូបឬទស្សនីយភាព)។ ក្រុមអ្នកហាត់ការចូលចិត្តជាពិសេសល្ខោននិយាយ ព្រោះវាងាយស្រួលយល់និងនិយាយពីបញ្ហាសង្គម ហើយធ្វើឱ្យមនុស្សគិតពិចារណា។ ក្រុមអ្នកហាត់ការសុទ្ធតែយល់ថាសិល្បៈផ្សាភ្ជាប់ (ឬគួរតែ) នឹងបញ្ហាហើយនិងតម្រូវការសង្គម។ ពួកគេថាសិល្បៈគឺសម្រាប់ផ្សព្វផ្សាយសារ នាំមនុស្សមកជួបជុំគ្នា បង្កើតឱ្យមានការផ្លាស់ប្តូរនៅក្នុងសង្គម និងសម្រាប់«ការអភិវឌ្ឍសង្គម» (ទោះបីឃ្លានេះត្រូវបានប្រើច្បោលៗក៏ដោយ)៖

> *«សិល្បៈជាឧបករណ៍ទំនាក់ទំនង រវាងរឿងវិជ្ជមាននិងអវិជ្ជមាន បុរាណនិងសម័យ និងរឿងផ្សេងទៀតដែលប្រជាជនអាចស្រូបយកបានពេលមើល ស្តាប់និងប៉ះពាល់វា។»*
>
> (ចម្លើយរបស់កំសត់) ។

> *«សិល្បៈគឺជាមធ្យោបាយមួយដ៏មានឥទ្ធិពលក្នុងការលើកកម្ពស់ចំណេះដឹង និងបញ្ហាសង្គម ក៏ដូចជាការកៀគរមតិសម្រាប់ការផ្លាស់ប្តូរ។»*
>
> (ចម្លើយរបស់សំណាង)

អ្នកហាត់ការខ្លះក៏បានឱ្យដឹងដែរថាការដែលចូលរួមក្នុងដំណើរការនេះ និងចូលរួមក្នុងសិល្បៈគឺបង្ហាញពីភាពជា *«ពលរដ្ឋល្អ» (ចម្លើយរបស់រតនៈ)* និងអនុញ្ញាតឱ្យមានការចូលរួមពេញលេញក្នុងសង្គម៖

> *«ខ្ញុំគិតថាយើងកំពុងតែចូលរួមហើយពេលនេះ (តាមរយៈការហាត់ការងារនេះ) ព្រោះការបង្កើតមហោស្រពមួយគឺមានអត្ថន័យខ្លាំងណាស់។ នេះជាការចូលរួមដ៏ធំមួយសម្រាប់យុវជនព្រោះយើងមកពីវិស័យ៤ខុសគ្នា ហើយយើងកំពុងបង្កើតមហោស្រពមួយដ៏មានន័យនិងមានឥទ្ធិពល កើតចេញពីការដាក់គំនិតពួកយើងបញ្ចូលគ្នា»*
>
> (កំសត់ អ្នកហាត់ការ)។

ទោះយ៉ាងណាការយល់ដឹងអំពីសិល្បៈមិនមែនងាយស្រួលទេសម្រាប់អ្នកហាត់ការ ហើយដោយសារត្រូវគេបោះចូលក្នុងដំណើរការដែលពួកគេមិនថ្មីក ធ្វើឱ្យពួកគេខ្វះទំនុកចិត្តក្នុងការបញ្ចេញគំនិត។ បន្ទាប់ពីជួបគ្នាអាទិត្យទី១ ពួកគេឆ្លើយភ្លាមៗថា សិល្បៈគឺជាការងារពិបាកជាងការគិតនិងការរំពឹងទុករបស់ពួកគេ។ ពួកគេមិនបានតាមឬយល់ពីការពិភាក្សាឬអ្វីដែលកើតឡើងទេ។ ចំណុចនេះបង្ហាញច្បាស់នៅក្នុងកំណត់ហេតុប្រចាំសប្តាហ៍របស់អ្នកហាត់ការដែលនិយាយតែពេលណាពួកគេច្បាស់ពីគំនិតខ្លួនឯងឬមានអារម្មណ៍«យ៉ាប់ខ្លាំង» ព្រោះពួកគេមិនច្បាស់ពីគំនិតរបស់ពួកគេឬមានអារម្មណ៍ថាពួកគេយល់មិនបានគ្រប់គ្រាន់ពីសិល្បៈ។ ម្តងនោះយើងបានផ្ទៀងផ្ទាត់ពីរឿងនេះតាមរយៈការស្រាវជ្រាវ គុលា និងខ្ញុំបាននិយាយជាមួយសេងអំពីរឿងនេះ។

បន្ទាប់ពីកិច្ចពិភាក្សារបស់ពួកយើង គុលានិងសេងបានប្រាប់ព័ត៌មានពីព្រឹត្តិការណ៍សិល្បៈផ្សេងៗដល់អ្នកហាត់ការ ហើយលើកទឹកចិត្តពួកគេឱ្យទៅចូលរួម ដើម្បីឱ្យពួកគេបានឃើញច្រើន និងពង្រីកចំណេះដឹងរបស់ពួកគេ (ព្រឹត្តិការណ៍សិល្បៈអាចនឹងពិបាករកប្រសិនបើយើងមិនតាមដានព័ត៌មានឱ្យត្រូវមនុស្ស ទំព័រហ្វេសប៊ុកឬតេលេក្រាមឱ្យត្រូវទេនោះ)។ ក្រុមអ្នកហាត់ការធ្វើវាបានម្តងម្កាល ហើយជំនួបផ្ទាល់បញ្ចប់ទៅដោយការទស្សនាពិព័រណ៍ឬព្រឹត្តិការណ៍សិល្បៈស្រដៀងនេះ។

តាមរយៈការរៀនបន្ថែមអំពីសិល្បៈ ក្រុមអ្នកហាត់ការបានឈានទៅដល់កម្រិតយល់ដឹងស៊ីជម្រៅ ទាំងរឿងសិល្បៈទាំងខ្លួនឯងក្នុងនាមជាឯកត្តបុគ្គល ៖

*«ខ្ញុំចូលរួមក្នុងសិល្បៈ ប៉ុន្តែខ្ញុំនៅឈរត្រង់ទីតាំងមួយដែលមានខ្ញុំម្នាក់ឯង។ ខ្ញុំមិនបានឱ្យខ្លួនឯងទៅស្គាល់សិល្បករ និងបរិយាកាសសិល្បៈទេ។ [...] ខ្ញុំមិនដឹងថាខ្ញុំអាចចូលរួមចំណែកក្នុងសិល្បៈរបៀបណា ហើយអភិវឌ្ឍខ្លួនឯងរបៀបណាទេ ប៉ុន្តែខ្ញុំចង់ចូលឱ្យជិតវាសិនដំបូង។ ដោយសារថាខ្ញុំជាផ្នែកមួយនៃកម្មវិធីនេះ ខ្ញុំបានយល់ដឹងអំពីសិល្បៈបន្តិចម្តងៗ។ ខ្ញុំចាប់ផ្តើមស្រាវជ្រាវពីទម្រង់សិល្បៈដែលខ្ញុំអត់ស្គាល់ពីមុន។ ប៉ុន្តែវាមិនមែនតែអំពីស្នាដៃសិល្បៈទេ។ មានទម្រង់សិល្បៈខ្លះដែលខ្ញុំធ្លាប់មើលពីមុន ប៉ុន្តែខ្ញុំមិនដឹងថាអ្នកណាជាអ្នកបង្កើតវា។ មានសិល្បករខ្លះខ្ញុំទើបតែស្គាល់ ប៉ុន្តែខ្ញុំមិនទាន់បានមើលស្នាដៃពួកគេទេ។ តាមរយៈការរួមគ្នាជ្រើសរើសស្នាដៃសម្រាប់ដាក់ក្នុងកម្មវិធីពួកយើង ខ្ញុំបានពង្រីកចំណេះដឹងមួយកម្រិតទៀត»*

(សម្ភាសន៍អ៊ុក លីគួយយូ)។

*«ពីមុន ខ្ញុំមើលតែការសម្តែងបានត្រឹមតែមើល។ ខ្ញុំមិនបានយកចិត្តទុកដាក់ដើម្បីមើលឱ្យឃើញពីតម្លៃវាទេ។ [...] ខ្ញុំស្គាល់ខ្លួនឯងជាងមុន ហើយខ្ញុំអាចចូលរួមចំណែកក្នុងសិល្បៈ»*

(កិច្ចសម្ភាសន៍ឃឿន កំសត់)។



ក្រុមអ្នកហាត់ការបានរៀបរាប់ដែរថាពួកគេ *«ទៅមើលពិព័រណ៍ វេទិកាពិភាក្សានិងសិក្ខាសាលាសកម្មជាងមុន»* *(កិច្ចសម្ភាសន៍មាឃ បុប្ផារតនៈ)* ព្រោះតែពួកគេចូលរួមរៀបចំមហោស្រព។ ទោះបីពួកគេបានយល់អំពីសិល្បៈខ្លះតាមរយៈការស្រាវជ្រាវពីការសម្តែងនៅក្នុងកម្មវិធីរដូវវប្បធម៌មុនៗក៏ដោយ ក្រុមអ្នកហាត់ការមានអារម្មណ៍ថា ពួកគេបានរៀន និងចូលរួមច្រើនបំផុតពេលពួកគេទៅចូលរួមព្រឹត្តិការណ៍សិល្បៈជាក្រុមបន្ទាប់ពីការប្រជុំនៅសិល្បៈខ្មែរអមតៈ ឬពេលពួកគេនិយាយជាមួយសិល្បករផ្ទាល់។ នៅក្នុងដំណាក់កាលរចនា និងរៀបចំផែនការសម្រាប់មហោស្រព សិល្បករត្រូវបានអញ្ជើញមកធ្វើបទបង្ហាញខ្លីមួយអំពីមហោស្រពឬនិយាយជាមួយអ្នកហាត់ការអំពីសិល្បៈរបស់ពួកគេ ហើយក្រោយមកទៀតក្រុមអ្នកហាត់ការចូលទៅរកសិល្បករខ្លួនឯងដើម្បីសួរសំណួរ។ ក្រុមអ្នកហាត់ការមានអារម្មណ៍ថា ជំនួបផ្ទាល់ប្រភេទនេះមានន័យនិងជំរុញឱ្យពួកគេចូលរួមបានច្រើនបំផុត។ ពួកគេចូលចិត្តទស្សនកិច្ចដែលមានការដឹកនាំ និងទៅជាមួយអ្នកផ្សេងៗទៀត ជាជាងការទៅមើលតែឯង៖

*«ការពិភាក្សាក្រុមនិងយោបល់ផ្សេងៗ យើងបានទទួលពីអ្នកធ្លាប់មានបទពិសោធន៍ពីវា និងអ្នកធ្លាប់រៀបចំព្រឹត្តិការណ៍ និងសិល្បករ។ ថ្ងៃមួយ ខ្ញុំបានសួរបងរ៉ាឌី (ង៉ែត រ៉ាឌី) អំពីរបាំមណីមេខលា។ ប្រសិនបើខ្ញុំមិនបានសួរគាត់ទេ ខ្ញុំប្រហែលចេះតែដាក់របាំនេះសម្តែងលើឆាកតាមចិត្ត។ ខ្ញុំអត់ដឹង។ [...] យើងតែងតែរៀនពីនេះពីនោះព្រោះពេលយើងរចនា យើងចាប់ផ្តើមមានអារម្មណ៍មិនពេញចិត្ត ហើយរកអ្វីដែលល្អសមរម្យ។ យើងសួរសំណួរ និងដេញដោលគ្នាទៅវិញទៅមក»*

(សុទ្ធ ពៅសំណាង អ្នកហាត់ការ)។



# ជំនាញនានាសម្រាប់ការចូលរួមរបស់ពលរដ្ឋក្នុងសង្គម

ក្រុមអ្នកហាត់ការត្រូវឆ្លងកាត់ការកសាងទំនាក់ទំនងជាក្រុម និងរៀនពីរបៀបធ្វើការជាមួយមនុស្សខុសៗគ្នា។ តាមរយៈការងារនេះ ឥទ្ធិពលសំខាន់មួយនៃការចូលរួមក្នុងមហោស្រពគឺការប្រើប្រាស់និងការអភិវឌ្ឍជំនាញដែលមានសារសំខាន់ក្នុងការលើកកម្ពស់ការចូលរួមស៊ីវិល។ ជំនាញសម្របសម្រួល ចរចា យល់ ជឿជាក់ និងដឹកនាំ គឺសំខាន់ណាស់នៅក្នុងបរិបទប្រទេសកម្ពុជា៖

*«ខ្ញុំមិនដឹងថាត្រូវចាប់ផ្ដើមវាយ៉ាងម៉េច [រចនាមហោស្រព]។ បន្ទាប់មក ខ្ញុំបានដឹងថា យើងត្រូវរកមូលបទនិងមើលពីបញ្ហាសង្គមរបស់យើង។ យើងក៏ត្រូវមើលដែរថាវាឆ្លើយតបនឹងតម្រូវការរបស់អ្នកទទួលផលឬអត់ តើពួកគេមកពីណា តើមហោស្រពប្រារព្ធនៅឯណា។ យើងត្រូវមានវត្ថុបំណងសម្រាប់មហោស្រព ហើយយើងជ្រើសរើសស្នាដៃដែលស្របនឹងវត្ថុបំណងរបស់មហោស្រពយើង។ យើងម្នាក់ៗមានកម្មវិធីរៀងខ្លួន តែយើងត្រូវសម្របសម្រួលគ្នាទៅវិញទៅមកដើម្បីជ្រើសរើសស្នាដៃដែលត្រូវនឹងទស្សនិកជន និងមូលបទប្រចាំថ្ងៃរបស់យើង។ នេះជាចំណេះដឹងថ្មីដែលខ្ញុំបានរៀន។ ធ្វើការជាក្រុមក៏ជាបទពិសោធន៍ថ្មីដែរ»*

(ឃឿន កំសត់ អ្នកហាត់ការ)។

ក្រុមអ្នកហាត់ការបាននិយាយអំពីតម្រូវការនៃការសម្របសម្រួលជាមួយគ្នាទៅវិញទៅមកដើម្បីជ្រើសរើសការសម្ដែងដែលពួកគេចង់បាននិងថ្លឹងថ្លែងវាជាមួយនឹងមូលបទរបស់មហោស្រពនិងថវិកា។ លើសពីនេះទៀត លោក សុង សេង តែងតែសួរក្រុមអ្នកហាត់ការជាក្រុមថាតើពួកគេយល់ស្របទាំងអស់គ្នាលើការសម្រេចណាមួយឬអត់ ហើយប្រាប់ពួកគេថា *«ទាំងអស់គ្នាត្រូវការពារគំនិតខ្លួនឯង។ កុំចេះតែគួរសមនិងយកចិត្តអ្នកផ្សេង បើមិនអ៊ីចឹងទេនឹងមិនបានឃើញគំនិតខ្លួនឯងនៅក្នុងហ្នឹងទេ។ ប៉ុន្តែវាមិនមែនមានន័យថាទាំងអស់គ្នាត្រូវឈ្លោះគ្នាដោយគ្មានមូលហេតុនោះទេ។ ទាំងអស់គ្នាត្រូវតែមានហេតុផលខ្លួនឯង» (កិច្ចសម្ភាសន៍ សុង សេង)*។ នៅក្នុងបទសម្ភាសន៍និងក្រុមពិភាក្សា ក្រុមអ្នកហាត់ការរៀបរាប់ពីសារៈសំខាន់ដែលគ្រប់គ្នាត្រូវយល់ពីគំនិតសំខាន់និងទិសដៅ ទោះបីជាពួកគេដើរតាមឬអនុវត្តតាមគំនិតនរណាម្នាក់ក៏ដោយ។ ការសម្រេចបែបសមូហភាពនិងប្រជាធិបតេយ្យបែបនេះមិនមែនងាយស្រួលអនុវត្តទេ ដោយសារតែម្នាក់ៗមានបុគ្គលិកលក្ខណៈនិងការចូលចិត្តខុសៗគ្នា។ សេងក៏បានពិពណ៌នាដែរថាគាត់មានអារម្មណ៍មិនច្បាស់ថាត្រូវធ្វើអន្តរាគមន៍ពេលណា។ វាជាបទពិសោធន៍ថ្មីសម្រាប់ទាំងអស់គ្នាដែលធ្វើការរបៀបនេះ។

ដោយសង្កេតមើលក្រុមអ្នកហាត់ការជាច្រើនខែ វាច្បាស់ណាស់ថា អ្នកហាត់ការខ្លះមានភាពជឿជាក់និងហ៊ាននិយាយច្រើន អ្នកខ្លះទៀតចូលចិត្តអង្គុយស្ដាប់ហើយពិចារណា ខ្លះទៀតចូលចិត្តច្បាស់ពីគំនិតខ្លួនឯងសិនមុននឹងនិយាយ ហើយខ្លះមិនចូលចិត្តបង្កើតការពិភាក្សាឬជជែកវែកញែកតែម្ដង។ លើសពីនេះទៀត លក្ខណៈពិសេសនៃវប្បធម៌ត្រូវតែយកចិត្តទុកដាក់ ជាពិសេសដោយសារយុវតីពីរនាក់ច្រើនតែស្ងាត់ស្ងៀមមិនសូវនិយាយស្ដី។ ដូចអ៊ុក លីគួយយូ និយាយនៅក្នុងបទសម្ភាសន៍នេះ *«ខ្ញុំមិនទុកចិត្តលើគំនិតខ្លួនឯង»* ហើយនាងបារម្ភខ្លាចធ្វើខុស។ នៅក្នុងបទសម្ភាសន៍ ក្រុមអ្នកហាត់ការដឹងថា ប្រសិនបើពួកគេមានគំនិតអ្វីមួយ ពួកគេត្រូវការការគាំទ្រពីអ្នកផ្សេងទៀតដើម្បីអនុវត្តវា ហើយតស៊ូមតិអំពីគំនិតនេះព្រោះពួកគេដឹងថាវានឹងទទួលបានការគាំទ្រនៅក្នុងក្រុម។អ្នកហាត់ការមិនអាចជួបគ្នាផ្ទាល់រហូតទេហើយតែងតែជួបគ្នាតាមហ្សូមដោយហេតុថាកំសត់រស់នៅរតនៈគិរី ការលំបាកក្នុងការរៀបចំការជួបផ្ទាល់ និងថ្លៃចាយវាយពេលជួបគ្នាផ្ទាល់ម្ដងៗ។ ក្រុមអ្នកហាត់ការយល់ឃើញថាការជួបតាមអនឡាញគឺពិបាក ព្រោះមានការរំខាននៅផ្ទះនិងប្រព័ន្ធអ៊ីនធឺណែតរអាក់រអួល ជាពិសេសកំសត់។ មានការជជែកគ្នាកើតឡើងជុំវិញថាតើបញ្ចូលអ្នកដែលមានបទពិសោធន៍តិចដោយរបៀបណា ហើយថាតើការចូលរួមនៅក្នុងស្នាដៃសិល្បៈនៅតាមខេត្ត ឬក្រុងនៅក្រៅក្រុងភ្នំពេញដោយរបៀបណា។ វាសំខាន់ណាស់ក្នុងការរក្សាឱកាសសម្រាប់យុវជននៅតាមខេត្ត ប៉ុន្តែវាអាចនឹងមានប្រយោជន៍ជាងបើនិយាយពីភាពងាយស្រួលនៃការចូលរួមនិងអារម្មណ៍ម្ចាស់ការ ដោយមិនលាយការចូលរួមពីយុវជនទូទាំងកម្ពុជា ប៉ុន្តែផ្អែកតាមក្រុងឬខេត្តទៅតាមសកម្មភាពដឹកនាំរបស់យុវជន។ គឺព្រោះតែវាងាយស្រួលក្នុងការសម្របសម្រួលការប្រជុំក្រុមនិងការងារដោយជួបផ្ទាល់។











ក្រុមអ្នកហាត់ការចូលចិត្តនិងស្នើការប្រជុំផ្ទាល់ និងចូលចិត្ត«ដើរលេង»ជាមួយគ្នា។ ពួកគេនិយាយថា ពួកគេគួរតែជួបគ្នាឱ្យបានច្រើនដើម្បីពង្រឹងទំនាក់ទំនងជាក្រុមដោយហេតុថាដំណើរការរៀបចំមហោស្រពកាន់តែស្រ្តេស តានតឹង និងបង្កើតគម្លាតក្នុងចំណោមពួកគេ។ ទោះយ៉ាងណាយើងកត់សម្គាល់ឃើញថា ក្រុមអ្នកហាត់ការមានភាពជឿជាក់ និងអាចបញ្ចេញមតិច្រើនឡើង។ ពួកគេព្យាយាមស្វែងរកគំនិតថ្មីៗ។ ដំណើរការក្នុងការបង្កើតមហោស្រពអនុញ្ញាតឱ្យមានការបង្ហាញជាខ្លួនឯងប្រកបដោយភាពច្នៃប្រតិដ្ឋ ហើយសម្រាប់ក្រុមអ្នកហាត់ការ ពួកគេត្រូវចរចាទៅកាន់ក្រុម ឧទាហរណ៍កិច្ចពិភាក្សាពីទីតាំង៖

*«នៅក្នុងការប្រជុំដាច់ដោយឡែកដំបូងរបស់យើង យើងឈ្លោះគ្នាជាលើកដំបូងទាក់ទងនឹងរឿងទីតាំង (កំសត់ ៖ វាជារឿងសំខាន់ណាស់)។ មហោស្រពបីថ្ងៃ មែនទេ? តាមពិត ខ្ញុំអវត្តមានពេលក្រុមពិភាក្សាថាធ្វើបីថ្ងៃ។ ពួកគាត់បានសម្រេចថាធ្វើពាថ្ងៃទៅហើយ។ ខ្ញុំគិតថា វាច្រើនពេក។ ខ្ញុំគិតថា ២ថ្ងៃល្អជាង។ បន្ទាប់ពីកិច្ចពិភាក្សារបស់យើង យើងបានសម្រេចថាធ្វើ២ថ្ងៃកន្លះ។ (សំណាង៖ ប៉ុន្តែខ្ញុំគិតថាធ្វើតែ២ថ្ងៃដូចពីដើមដំបូង។) ខ្ញុំគិតថា មហោស្រព២ថ្ងៃអាចធ្វើតែនៅកន្លែងមួយប៉ុន្តែបង(សំណាង)ថា ប្អូនទាក់យើងត្រូវទទួលខុសត្រូវព្រឹត្តិការណ៍៤នៅទីតាំងខុសៗគ្នា។ ក្នុងមួយថ្ងៃ មានព្រឹត្តិការណ៍នៅទីតាំងខុសៗគ្នា។ ខ្ញុំវិលវល់ហើយ ខ្ញុំមិនដឹងត្រូវឆ្លើយយ៉ាងម៉េច។ [សំណាង៖ យើងអត់យល់ដូចគ្នា]។ វាពិតជាត្រូវការពេល*

(អ៊ុក លីគួយយូ អ្នកហាត់ការ)។

ក្នុងនាមជាអ្នកសម្របសម្រួលម្នាក់ សេងមើលឃើញពីភាពជឿជាក់និងសេរីភាពដែលមាននៅក្នុងខ្លួនអ្នកហាត់ការ ហើយភាពជាម្ចាស់ការលើមហោស្រពរបស់ពួកគេក៏ខ្លាំងជាងមុន។ នៅក្នុងការស្ទង់មតិអំពីជំនាញដែលអ្នកហាត់ការមានអារម្មណ៍ថាបានប្រើ បានរៀន និងទទួលបានតាមរយៈដំណើរការរៀបចំមហោស្រពនេះ ពួកគេរៀនហ៊ាននិយាយនិងបញ្ចេញមតិជាជំនាញដែលពួកគេបានអភិវឌ្ឍ ហើយរៀនពីអ្នកសម្របសម្រួលអំពីការប្រើជំនាញជាច្រើនដើម្បីរីកចម្រើន។ ពួកគេចង់រៀនថែមអំពីជំនាញទំនាក់ទំនងនិងការបញ្ចុះបញ្ចូល ដោយពួកគេលើកឡើងថា ភាពមិនស្មើគ្នាក្នុងការចូលរួមគឺជាអ្វីដែលពួកគេចង់ធ្វើឱ្យប្រសើរឡើង។





គួរឱ្យចាប់អារម្មណ៍ គ្មានអ្នកហាត់ការណាម្នាក់ចង់«ដឹកនាំ»មហោស្រព ហើយក៏គ្មានអ្នកចង់ជំរុញនរណាម្នាក់ឱ្យគ្រប់គ្រងដែរ ដោយសារពួកគេផ្តោតលើការសម្រេចចិត្តជាសមូហភាព។ ទោះបីជាអ្នកខ្លះមានលក្ខណៈជាអ្នកគ្រប់គ្រង ប៉ុន្តែពួកគេមើលមិនឃើញខ្លួនឯងធ្វើជាអ្នកដឹកនាំទេ។ អ្នកហាត់ការភាគច្រើនលើកឡើងនៅក្នុងការស្ទង់មតិពីជំនាញ ថាជំនាញភាពជាអ្នកដឹកនាំជាអ្វីដែលពួកគេចង់អភិវឌ្ឍអំឡុងពេលរចនាមហោស្រព ពាក់ព័ន្ធនឹងធ្វើម៉េចឱ្យមានគំនិតច្បាស់ សមត្ថភាពផ្នែកទំនាក់ទំនងនិងការសម្របសម្រួល។ ប៉ុន្តែពួកគេមានអារម្មណ៍ថា ការរចនាមហោស្រពបានផ្លាស់ប្តូរពួកគេឱ្យមានទំនួលខុសត្រូវជាងមុន ចេះជំនាញដោះស្រាយបញ្ហា និងមានគំនិតវិភាគ អាច *«មើលឃើញឫសគល់នៃបញ្ហា» (កិច្ចសម្ភាសន៍អ៊ុក លីគួយយូ)*។ អ្នកហាត់ការខ្លះមានអារម្មណ៍ថាពួកគេប្រើជំនាញដែលគេមានស្រាប់ជាងការអភិវឌ្ឍជំនាញថ្មី ជាពិសេសពេលពួកគេត្រូវប្រើបណ្តាញដែលពួកគេមានស្រាប់ដើម្បីជួយរចនាកម្មវិធីមហោស្រព (ជាពិសេសសុទ្ធ ពៅសំណាង ពាក់ព័ន្ធនឹងអ្នកចូលរួមការបង្ហាញម៉ូដនិងវេទិកាពិភាក្សា)។ ក្រុមអ្នកហាត់ការចង់រៀនថែមអំពីការកៀរគរធនធានជាពិសេសការស្វែងរកអ្នកឧបត្ថម្ភ និងការចរចាជាមួយពួកគេ។ បញ្ហាថវិកាត្រូវបានបង្ហាញទៅកាន់អ្នកហាត់ការបន្ទាប់ពីកម្មវិធីដំបូងរបស់ពួកគេត្រូវបានរចនាឡើង នាំឱ្យមានការផ្លាស់ប្តូរ ហើយពួកគេគ្មានពេលគ្រប់គ្រាន់ក្នុងការស្វែងរកអ្នកឧបត្ថម្ភផ្សេងទៀតទេ (ទោះបីពួកគេបានធ្វើការលើផ្នែកនេះក៏ដោយ)។ នេះប្រហែលជាអ្វីមួយដែលគួរតែបង្ហាញប្រាប់ពួកគេតាំងពីចាប់ផ្តើមដំបូងដោយហេតុថាអ្នកហាត់ការចាប់អារម្មណ៍នឹងរឿងនេះដោយសារជាជំនាញអាចផ្ទេរបន្តដែលអាចនឹងមានប្រយោជន៍នៅក្នុងសង្គម។

# ០៤

# ការចូលរួមក្នុងមហោស្រពល្ខោន

**ក្នុងផ្នែកនេះ យើងពិភាក្សាអំពីរបៀបផ្សព្វផ្សាយមហោស្រពនិងកម្មវិធីមហោស្រពឱ្យមានការចូលរួមយ៉ាងសកម្ម និងរបៀបដែលសកម្មភាពនេះមានទំនាក់ទំនងនឹងសង្គម។ យើងនឹងពិចារណាជរភាពមួយចំនួនខាងក្រោមនេះ៖**

- ការផ្សព្វផ្សាយព្រឹត្តិការណ៍
- អ្នកស្ម័គ្រចិត្ត
- ភាពចម្រុះនិងបរិយាបន្នក្នុងការចូលរួម និងសមត្ថភាពបង្កើតសាមគ្គីភាព និងការប្រើប្រាស់ភាពស្វាហាប់របស់យុវជនឱ្យទៅជាប្រយោជន៍។

# ការផ្សព្វផ្សាយមហោស្រព

រឿងដំបូងគេដែលត្រូវយកមកពិចារណាក្នុងការចូលរួមនេះគឺការផ្សព្វផ្សាយអំពីមហោស្រពនេះ និងសមត្ថភាពក្នុងការទាក់ទាញទស្សនិកជន។ ចំណុចមួយនេះជាបញ្ហា ហើយអ្នករៀបចំគ្រប់គ្នាខកចិត្ត នៅពេលឃើញមនុស្សចូលរួមតិចជាងការរំពឹងទុក។ ការកំណត់ដឹងចំនួនទស្សនិកជនជាក់លាក់ជារឿងពិបាកដោយសារមនុស្សចូលនិងចេញនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍ មនុស្សខ្លះទិញសំបុត្រចូលមើល ប៉ុន្តែបើព្រឹត្តិការណ៍នៅក្នុងទីធ្លាសាធារណៈវិញ មនុស្សជាច្រើនចូលរួមទស្សនាខ្លះៗដោយមិនបង់ប្រាក់។ មានព្រឹត្តិការណ៍ជាច្រើននៅក្នុងអំឡុងពេលចុងសប្តាហ៍នៃមហោស្រពនេះដែលអាចនាំទៅរកការធ្លាក់ចុះចំនួនទស្សនិកជនជារួមបាន។ គួរគត់សម្គាល់ថាអង្គការសិល្បៈខ្មែរអមតៈបានស្នើឱ្យរៀបចំព្រឹត្តិការណ៍នេះចំនឹងទិវាសិទ្ធិមនុស្សអន្តរជាតិ ហើយត្រូវគ្នាទាំងមូលបទនិងគោលបំណងនៃមហោស្រពនេះផង ប៉ុន្តែការរៀបចំបែបនេះក៏អាចនាំឱ្យបំបែកចំនួនទស្សនិកជនពីព្រឹត្តិការណ៍ធំៗផ្សេងទៀតដែរ។ ថ្ងៃសៅរ៍និងថ្ងៃអាទិត្យបង្ហាញឱ្យឃើញចំនួនទស្សនិកជនតិចជាងថ្ងៃធម្មតា ជាពិសេសចំពោះការប្រគំតន្ត្រីដែលជាការខកចិត្តចំពោះមនុស្សគ្រប់គ្នា។ ទោះជាយ៉ាងណា រាត្រីដែលបើកព្រឹត្តិការណ៍នោះមានការចូលរួមយ៉ាងល្អដោយសារមនុស្សជាច្រើនក្នុងសហគមន៍សិល្បៈទទួលបានការអញ្ជើញ ប៉ុន្តែក្រៅពីនេះ ចំនួនទស្សនិកជនហាក់ដូចជាតិចតួចទេ។ ការណ៍នេះមិនមែនមានន័យថាការចូលរួមពីសាធារណជនមិនមានការផ្សព្វផ្សាយនោះទេ ប៉ុន្តែមនុស្សគ្រប់គ្នាខកចិត្តចំពោះចំនួនអ្នកចូលរួមជាទូទៅ និងកម្រិតសាយភាយមហោស្រពនេះ ដោយរួមទាំងអ្នកហាត់ការផង៖

*«ទោះបីមិនមានទស្សនិកជនច្រើនក៏ដោយ ក៏អ្នកដែលបានមកចូលរួមសុទ្ធតែទទួលបានអ្វីម្យ៉ាងពីមហោស្រពរបស់យើង[...]។ ខ្ញុំជឿថាពួកគាត់ទទួលបានអ្វីម្យ៉ាងពីព្រឹត្តិការណ៍របស់ពួកយើង។ ខ្ញុំយល់ថាវាជាជោគជ័យខ្លះដែរ។ ដំបូងខ្ញុំមានការរំពឹងធំណាស់ដោយសង្ឃឹមថានឹងមានទស្សនិកជនជាច្រើន ហើយដំបូងឡើយខ្ញុំរំពឹងថាពួកគាត់នឹងទទួលយ៉ាងហោចណាស់៨០%ពីមហោស្រពនេះ [យល់ដឹងនិងចូលរួម៨០%]។ ជាក់ស្តែង យើងមិនបានឃើញអ្នកចូលរួមច្រើនកុះករដូចការរំពឹងទុកនោះទេ [ប្រហែល២០ទៅ៣០នាក់សម្រាប់សិក្ខាសាលានិងព្រឹត្តិការណ៍ដែលតូចជាងនេះ]។ ទោះជាយ៉ាងណាខ្ញុំរីករាយដែលពួកគាត់សុខចិត្តចូលរួមចំណែកក្នុងព្រឹត្តិការណ៍របស់យើងដោយខ្លួនឯង ហើយពួកគាត់សង្ឃឹមថាយើងអាចបន្តរៀបចំសិក្ខាសាលាសុខភាពផ្លូវចិត្ត វេទិកាពិភាក្សា អំណានបែបច្នៃប្រតិដ្ឋ និងការសម្តែងផ្សេងៗខ្លះទៀត។»*

(កិច្ចសម្ភាសន៍ មាឃ បុប្ផារតនៈ)។

សម្រង់កិច្ចសម្ភាសន៍ខាងលើនេះក៏បង្ហាញពីការពិបាកជ្រើសរើសរវាងគុណភាពនិងបរិមាណនៃការចូលរួមក្នុងសិល្បៈ ហើយបើពង្រីកឱ្យលើសពីនេះទៀត គឺសក្តានុពលរបស់ពួកគេចំពោះការចូលរួមក្នុងសង្គមស៊ីវិល។ ទោះជាយ៉ាងណាក៏មហោស្រពនេះអនុញ្ញាតឱ្យមានការចូលរួមពិចារណាកាន់តែស៊ីជម្រៅរួមជាមួយនឹងការបង្ហាញសិល្បៈកម្សាន្តជាច្រើនទម្រង់ដែរ។






ក្នុងការកំណត់ហេតុផល សម្រាប់បញ្ហាផ្សព្វផ្សាយលទ្ធផលដែលទទួលបានពីការសម្ភាសន៍គ្រប់ផ្នែកមុនពេលឈានដល់ព្រឹត្តិការណ៍នេះ គឺការផ្សព្វផ្សាយយឺតយ៉ាវពេក ហើយក៏ដូចជាមិនមានយុទ្ធសាស្ត្រសមស្របទៀតផង។ ហេតុផលនៃកង្វះប្រសិទ្ធភាពនេះកើតចេញពីកត្តាជាច្រើន ដោយរួមទាំងកង្វះសកម្មភាពក្នុងការចូលរួមរបស់អ្នកហាត់ការ និងការមិនបានបំពេញភារកិច្ចរួចរាល់តាមពេលកំណត់ កង្វះថវិកា ភាពយឺតយ៉ាវក្នុងការប្រមូលក្រុមការងារស្នូលនៃអង្គការសិល្បៈខ្មែរអមតៈមកចូលរួមដំណើរការផលិតដោយសារខ្វះបទពិសោធន៍និងខ្វះការគាំទ្របុគ្គលិក កង្វះការរំពឹងទុកអំពីតួនាទី និងភាពមិនច្បាស់លាស់ថាតើនរណាគួរមានតួនាទីលើការផ្សព្វផ្សាយ ព្រោះដំបូងឡើយការចូលរួមរបស់ក្រុមអ្នកហាត់ការគឺទាក់ទងនឹងការរៀបចំនិងការរចនាកម្មវិធី កង្វះទំនាក់ទំនងរវាងក្រុមអ្នកហាត់ការនិងបុគ្គលិកអង្គការសិល្បៈខ្មែរអមតៈដោយសារការមិនហ៊ាននិងកង្វះបទពិសោធន៍ (ឬផ្ទុយពីនេះនាំទៅរកការខ្វែងគំនិតគ្នា) ហើយបើតាមការយល់ឃើញរបស់ក្រុមអ្នកហាត់ការនិងក្រុមអ្នកសម្របសម្រួលគឺកង្វះ«ភាពជាម្ចាស់ការ»លើផ្នែកផលិតកម្ម។ ទាក់ទងនឹងផ្នែកនេះដែរ ការរៀបចំរចនាសម្ព័ន្ធនៃមហោស្រពនេះតម្រូវឱ្យមានការពិចារណាបន្ថែមទៀតតាំងពីពេលចាប់ផ្តើមទៅ។

ដោយមិនមានការទម្លាក់កំហុសទៅខាងណា ហើយបើមើលពីទស្សនៈអ្នកនៅខាងក្រៅវិញ ចំណុចដែលគួរកត់សម្គាល់គឺមានការធ្វើទីផ្សារនិងការចូលរួមគួរសមដែរនៅពេលចាប់ផ្តើមនៃដំណើរការនេះ (ដូចជាការសម្ភាសន៍តាមវីដេអូជាមួយក្រុមអ្នកហាត់ការនៅលើបណ្តាញសង្គម) ប៉ុន្តែស្ទើរតែមិនមានមាតិកាបែបនេះទៀតនៅពេលបញ្ចប់ព្រឹត្តិការណ៍នេះ ក្រៅពីអ្វីដែលក្រុមអ្នកហាត់ការព្យាយាមបង្កើតដោយខ្លួនឯងនិងតាមរយៈបណ្តាញផ្ទាល់ខ្លួនរបស់ពួកគេនៅនាទីចុងក្រោយ។ ការដាក់ក្រុមអ្នកហាត់ការឱ្យធ្វើការជាក្រុមជាមួយបុគ្គលិកអង្គការសិល្បៈខ្មែរអមតៈ បានផ្តល់បទពិសោធន៍ផ្ទាល់អំពីតួនាទីទាំងនោះ នៅក្នុងក្របខ័ណ្ឌនៃអង្គការសិល្បៈខ្មែរអមតៈ ជាពិសេសគឺការងារជាបទពិសោធន៍«ស្រមោល»និងអាចឈានទៅផ្តល់ឱ្យមានការផ្លាស់ប្តូរគំនិតបានកាន់តែច្រើនរវាងយុវជននិងប្រតិបត្តិការអង្គការសិល្បៈខ្មែរអមតៈដែលមានស្រាប់។ ក្រុមអ្នកហាត់ការបានដឹកនាំកិច្ចការមួយចំនួនដែលពួកគេបានកំណត់ ហើយក្រោយមកក៏បានបង្កើតជាទំនួលខុសត្រូវ។ ទោះជាយ៉ាងណាកិច្ចការនេះក៏បាននាំឱ្យពួកគេបាត់បង់ការគ្រប់គ្រងមួយចំនួន ហើយមានកិច្ចពិភាក្សាមួយចំនួនអំពីរឿងនេះ ដែលទាក់ទងនឹងរបៀបអនុវត្តការងារ និងការរៀបចំដំណើរការនៃព្រឹត្តិការណ៍។ ក្រុមអ្នកហាត់ការមួយចំនួនមានគំនិតជាក់លាក់អំពីរបៀបដែលព្រឹត្តិការណ៍គួររៀបចំ ប៉ុន្តែគំនិតទាំងនោះបែរជាផ្ទុយនឹងគំនិត និងបទពិសោធន៍របស់បុគ្គលិកអង្គការសិល្បៈខ្មែរអមតៈនិងសមាជិកក្រុមផ្សេងទៀតវិញ។ ទង្វើបែបនេះបង្កើតជាបញ្ហាលំបាកមួយចំពោះការចូលរួមដោយសមភាពរបស់ក្រុមអ្នកហាត់ការ ទាក់ទងនឹងឯករាជ្យភាពរបស់ពួកគេ និងការគ្រប់គ្រងលើព្រឹត្តិការណ៍ទាំងមូល។



នៅក្នុងកិច្ចសម្ភាសន៍ដែលធ្វើឡើងក្រោយពេលរៀបចំមហោស្រពនេះ ក្រុមអ្នកហាត់ការបានឆ្លុះបញ្ចាំងរបៀបដែលព្រឹត្តិការណ៍ផ្សេងៗទៀត ដូចជារដូវវប្បធម៌របស់អង្គការសិល្បៈខ្មែរអមតៈ ឬពិព័រណ៍សៀវភៅកម្ពុជាជាដើមដែលបានផ្សព្វផ្សាយព័ត៌មាននិងប្រកាសជាសាធារណៈមួយខែមុន។ ផ្ទុយទៅវិញ មហោស្រពនេះមិនសូវមានតំណភ្ជាប់ព្រឹត្តិការណ៍លើបណ្តាញសង្គមបានទាន់ពេលវេលាទេ ហើយមាតិកាអំពីមហោស្រពនេះ ដោយរួមទាំងវាគ្មិននិងព្រឹត្តិការណ៍ទាំងមូលផ្សព្វផ្សាយយឺតពេលពេក(ពោលគឺនៅថ្ងៃចុងក្រោយ)។ ហេតុដូច្នេះហើយ ការទាក់ទាញយុវជនមកចូលរួមព្រឹត្តិការណ៍ទាំងនេះមិនបានទូលំទូលាយទេ ប៉ុន្តែក៏មិនមែនន័យថាមិនជោគជ័យដែរ។ ទស្សនិកជនដែលយើងបានជួបសាកសួរ បានដឹងអំពីព្រឹត្តិការណ៍នេះភាគច្រើនតាមរយៈហ្វេសប៊ុក តាមរយៈទំព័របណ្តាញសង្គមព្រឹត្តិការណ៍មហោស្រព៧ពណ៌(ដែលជួលគេផ្សព្វផ្សាយ) ក្រុមតេលេក្រាមរបស់អង្គការសិល្បៈខ្មែរអមតៈ សិល្បករនិងព្រឹត្តិការណ៍សិល្បៈដទៃទៀតដែលចែករំលែកព័ត៌មានអំពីព្រឹត្តិការណ៍នេះ ក៏ដូចជាតាមរយៈបណ្តាញទំនាក់ទំនងផ្ទាល់ខ្លួនក្នុងចំណោមមិត្តភក្តិនិងមិត្តរួមការងារ។ លោកសុង សេង ជាអ្នកសម្របសម្រួលព្រឹត្តិការណ៍នេះក៏បានសារភាពដែរនៅក្នុងកិច្ចសម្ភាសន៍ថា លោកត្រូវការក្រុមអ្នកហាត់ការវ័យក្មេងនិងបុគ្គលិកអង្គការសិល្បៈខ្មែរអមតៈឱ្យជួយទាក់ទងជាមួយសិល្បករប្រជាប្រិយក្មេងៗដោយសារនេះមិនមែនជាពិភពដែលលោកស្គាល់ច្បាស់ទេ៖

*«បញ្ហាមួយគឺការទាក់ទងជាមួយអ្នកចម្រៀង។ នៅពេលពួកគេលើកឈ្មោះអ្នកទាំងអស់នោះឡើង ខ្ញុំស្តាប់ទៅដូចជាថ្មីថែស ដោយសារខ្ញុំមិនដែលស្គាល់ពួកគេ។ ខ្ញុំមិនស្គាល់តារាចម្រៀងក្មេងៗទេ។ ការនាំតារាចម្រៀងទាំងនោះមកចូលរួមក្នុងកម្មវិធីរបស់យើងជាបញ្ហាធំបំផុតចំពោះខ្ញុំ។ ហេតុដូច្នេះហើយ ទើបខ្ញុំត្រូវការជំនួយពីក្រុមអ្នកហាត់ការ។ សំណាងស្គាល់តារាចម្រៀងទាំងនោះច្រើននាក់ណាស់។ បន្ទាប់មកខ្ញុំទៅរកគាត់និងសួរតើគាត់អាចជួយបានទេ។ គាត់ថាមិនមានបញ្ហាអ្វីទេ។ សំណាងណាស់ មិត្តរួមការងារ(នៅអង្គការសិល្បៈខ្មែរអមតៈ)របស់យើងម្នាក់ក៏មានទំនាក់ទំនងល្អជាមួយមនុស្សនៅក្នុងវិស័យនោះដែរ។ ទីបំផុត យើងក៏បានសហការជាមួយពួកគេ។»*

លោកសេងក៏បានគាំទ្រក្រុមអ្នកហាត់ការដែរនៅក្នុងការរុករកច្រកថ្មីៗដើម្បីផ្សព្វផ្សាយជាសាធារណៈនៅនាទីចុងក្រោយដោយផ្តល់សេរីភាពដល់ពួកគេបង្កើតគណនី TikTok (ដែលមានការទស្សនា២០០០ដងក្នុងរយៈពេល២ថ្ងៃមុនពេលបើកព្រឹត្តិការណ៍)។ ក្រុមអ្នកហាត់ការក៏មានគំនិតស្រមើស្រមៃផ្សេងៗគ្នាជាច្រើនសម្រាប់ទាក់ទាញទស្សនិកជនក្មេងៗថ្មីៗដែរ ដូចជាសុំឱ្យមនុស្ស១០នាក់នៅក្នុងបណ្តាញផ្ទាល់ខ្លួនរបស់ពួកគេបង្កើតវីដេអូមួយអំពីព្រឹត្តិការណ៍នេះ សុំអ្នកមានឥទ្ធិពលលើបណ្តាញសង្គមឬអ្នកបង្កើតមាតិកា ឱ្យជួយផ្សព្វផ្សាយអំពីមហោស្រពនេះ ហើយក្រុមអ្នកសម្តែងទាំងអស់ក៏បានផ្សព្វផ្សាយអំពីមហោស្រពនេះនៅលើទំព័រផ្ទាល់ខ្លួនរបស់ពួកគេដែរ។ បញ្ហាស្ថិតនៅត្រង់ថាសកម្មភាពផ្សព្វផ្សាយទាំងនេះធ្វើឡើងយឺតពេក។



# ក្រុមអ្នកស្ម័គ្រចិត្ត

ការងារស្ម័គ្រចិត្តជាសកម្មភាពគន្លឹះដើម្បីទាក់ទាញយុវជនក្នុងសង្គមនិងដើម្បីចូលរួមមានទំនួលខុសត្រូវសង្គម និងធ្វើសកម្មភាពសម្រាប់សង្គមទាំងនោះដោយក្តីរីករាយ។ ការប្រកាសរកក្រុមបអ្នកស្ម័គ្រចិត្តសម្រាប់មហោស្រពនេះតាមរយៈបណ្តាញសង្គមហ្វេសប៊ុកជាជោគជ័យធំដែលមានអ្នកដាក់ពាក្យមកជាង៤០០នាក់ ជាចំនួនច្រើនបំផុតដែលអង្គការសិល្បៈខ្មែរអមតៈមិនធ្លាប់ទទួលបាន ហើយជាគុណបំណាច់មួយផ្នែកពីការផ្សព្វផ្សាយនៅក្នុងក្រុមហ្វេសប៊ុក ឈ្មោះ «ឱកាស-Opportunities»។ ចំនួនដ៏ច្រើននេះបង្ហាញឱ្យឃើញការចង់បានឱកាសដើម្បីចូលរួមក្នុងសង្គមក្នុងចំណោមយុវជន។ ទោះជាយ៉ាងណានេះជាលើកទីមួយដែលយុវជនមួយចំនួនមានឱកាសស្ម័គ្រចិត្តចូលរួមព្រឹត្តិការណ៍ ហើយយុវជនជាច្រើននាក់ធ្លាប់ជាអ្នកស្ម័គ្រចិត្តពីមុនមកនៅក្នុងព្រឹត្តិការណ៍ផ្សេងៗ ដូចជាព្រឹត្តិការណ៍តាមសាលារៀន ព្រឹត្តិការណ៍អភិវឌ្ឍបច្ចេកវិទ្យាជាដើម។ យុវជនជាច្រើនគ្រាន់តែចង់បានបទពិសោធន៍ការងារស្ម័គ្រចិត្ត ប៉ុន្តែមហោស្រពដែលផ្តោតលើយុវជននិងសិល្បៈបែបនេះទាក់ទាញពួកគេជាពិសេស។ ពួកគេស្ទើរតែទាំងអស់ចង់ស្គាល់សិល្បៈកាន់តែច្រើន ឬបង្ហាញចំណាប់អារម្មណ៍ក្នុងសិល្បៈដោយសារនោះជារឿងថ្មីសម្រាប់ពួកគេ។ ជាថ្មីម្តងទៀត ការជ្រើសរើសក្រុមអ្នកស្ម័គ្រចិត្តនិងការបែងចែកភារកិច្ចទៅក្រុមណាមួយទាក់ទងនឹងដំណើរការផលិតមហោស្រពជារួមធ្វើឡើងយឺតពេលបន្តិចនៅក្នុងដំណើរនេះ។ ក្រុមអ្នកហាត់ការពេញចិត្តនឹងការចូលរួមរបស់ក្រុមអ្នកស្ម័គ្រចិត្ត ប៉ុន្តែពេលខ្លះក៏ពួកគេបង្ហាញដែរថាពួកគេមកយឺតពេល (ឬមិនបានមកតែម្តង) ហើយមិនសូវបានជួយរៀបចំដូចការរំពឹងទុកទេ។ ទាក់ទងនឹងចំណុចនេះ ពួកគេចង់បានពេលវេលាចំណងទំនាក់ទំនងឱ្យបានកាន់តែច្រើនដើម្បីស្គាល់ក្រុមអ្នកស្ម័គ្រចិត្តនិងជួយពួកគេចូលរួមបានពិតប្រាកដក្នុងមហោស្រពនិងសម្រេចគោលបំណងនៃមហោស្រពនេះ៖

*«មនុស្សដែលពាក់ព័ន្ធទាំងអស់គួរមានពេលស្គាល់គ្នាមុនពេលចាប់ផ្តើមធ្វើការ។ ចំពោះខ្ញុំ ខ្ញុំស្គាល់អ្នកស្ម័គ្រចិត្តត្រឹមតែពីរនាក់ប៉ុណ្ណោះដែលធ្វើការជិតស្និទ្ធជាមួយខ្ញុំ។»*

(កិច្ចសម្ភាសន៍ ឃឿន កំសត់)

*«ខ្ញុំក៏ចង់បានគំនិតខ្លះពីក្រុមអ្នកស្ម័គ្រចិត្តដែរ។ នៅពេលពួកគេមកជួយយើងក្នុងការរៀបចំ ពួកគេមានគំនិតច្រើនណាស់ដែលអាចជួយយើងធ្វើការបានកាន់តែប្រសើរ។ [...] បើយើងមានពេល ឬបើពួកគេទទួលបានការបណ្តុះបណ្តាលច្រើនជាងនេះ ខ្ញុំយល់ថាពួកគេអាចធ្វើបានកាន់តែប្រសើរ។ ខ្ញុំយល់ថាបើបែបនេះមែននឹងមានឥទ្ធិពលវិជ្ជមានលើមហោស្រពរបស់យើង ដោយសារយើងនឹងបានបញ្ចូលគំនិតយុវជនពីខាងក្រៅមក។ ពួកគេក៏មានអារម្មណ៍ថាមហោស្រពនេះជាមហោស្រពរបស់ពួកគេដែរ ពួកគេមិនមែនត្រឹមតែជាអ្នកជួយទេ។»*

(កិច្ចសម្ភាសន៍ អ៊ុក លីគួយយូ)

ក្រុមអ្នកហាត់ការទាំងអស់ចង់ឱ្យក្រុមអ្នកស្ម័គ្រចិត្តចូលរួមឱ្យបានពេញលេញក្នុងមហោស្រពនេះ និងចង់ឱ្យពួកគេមានអារម្មណ៍ថានេះជាព្រឹត្តិការណ៍សម្រាប់ពួកគេក្នុងរបៀបមួយដែលជួយលើកកម្ពស់ខ្លឹមសារនិងការចូលរួមស៊ីជម្រៅ។ ជាក់ស្តែង មិនមែនក្រុមអ្នកស្ម័គ្រចិត្តទាំងអស់សុទ្ធតែចង់ឬមានបំណងចង់បានបទពិសោធន៍នោះទេ ប៉ុន្តែដូចការវែកញែកខាងក្រោមនេះ ការចូលរួមមិនបានពេញលេញមិនមែនមានន័យថាមហោស្រពនេះមិនមានឥទ្ធិពលអ្វីលើពួកគេសោះនោះទេ។ពេញលេញមិនមែនមានន័យថាមហោស្រពនេះមិនមានឥទ្ធិពលអ្វីលើពួកគេសោះនោះទេ។



# ភាពចម្រុះនិងសមភាពនៃការចូលរួម

ទាក់ទងនឹងចំណុចនេះ ក្រុមអ្នកហាត់ការមានក្តីបារម្ភចំពោះការធ្វើឱ្យជាក់ច្បាស់ថាទស្សនិកជនយល់ថាមានភាពងាយស្រួលចូលរួមក្នុងមហោស្រពនេះ ពួកគេរៀបចំឡើងដើម្បីលើកកម្ពស់ការចូលរួមយ៉ាងសកម្មដូចរៀបរាប់ខាងលើ។ បើត្រឡប់ទៅមើលគំនិតសំខាន់ជុំវិញការចូលរួមរបស់ពលរដ្ឋដែលបានកំណត់ទុកក្នុងការស្រាវជ្រាវខាងដើមរបស់យើង ពួកគេក៏យកចិត្តទុកដាក់ដល់ភាពចម្រុះនិងសមភាពនៃការចូលរួមដែរ បើទោះបីការណ៍នេះមិនបានអនុវត្តជោគជ័យជានិច្ចក៏ដោយ។ ក្នុងទិដ្ឋភាពជាច្រើន មហោស្រពនេះទទួលបានភាពត្រចះត្រចង់ក្នុងការព្យាយាមនាំក្រុមមនុស្សពីក្រុមផ្សេងៗមករួមគ្នាក្នុងរបៀបដែលឆ្លុះបញ្ចាំងប្រយោជន៍និងកង្វល់នៃយុវជន និងលើកកម្ពស់លំហទូលំទូលាយសម្រាប់បញ្ចេញគំនិតនិងជជែកគ្នា។ មានឧទាហរណ៍ជាច្រើននៃទិដ្ឋភាពនេះ ដូចជាការព្យួរសារលើដើមឈើបំណងជាដើម។ នៅត្រង់នេះ ទស្សនិកជន (ជាពិសេសក្រោយពេលសិក្ខាសាលា) ទទួលបានការលើកទឹកចិត្តឱ្យសរសេរអំពីអ្វីដែលពួកគេចង់ឃើញក្នុងពេល៥ឆ្នាំខាងមុខទាក់ទងនឹងសិល្បៈនិងការអភិវឌ្ឍសង្គម ហើយបន្ទាប់មកពួកគេយកសារទាំងនោះទៅចងជាប់នឹងដើមឈើនៅក្នុងសួន។ ទស្សនិកជនបានបន្សល់ទុកសារចំនួន៧៧ដែលពួកគេបានរៀបរាប់គំនិតជាច្រើន ប៉ុន្តែបានបង្ហាញបំណងយ៉ាងខ្លាំងក្លាក្នុងការចង់ឃើញសិល្បៈខ្មែរនៅលើឆាកអន្តរជាតិ ដោយសង្កត់ធ្ងន់លើតម្រូវការចែករម្លែក អភិរក្ស និងផ្សព្វផ្សាយចំណេះដឹងអំពីសិល្បៈនិងវប្បធម៌ សង្ឃឹមចង់បានបរិយាបន្នកាន់តែទូលំទូលាយក្នុងសិល្បៈ សង្គមដែលកាន់តែមានភាពស្មុកស្មាញ និងប្រជាធិបតេយ្យកាន់តែច្រើន និងចង់ឃើញសិល្បៈជាទូទៅទទួលបានតម្លៃកាន់តែខ្លាំង។ ខ្លឹមសារនេះឆ្លុះបញ្ចាំងតាមរយៈឧទាហរណ៍នៃយោបល់ខាងក្រោមនេះ៖



“

«អ្វីដែលខ្ញុំចង់ឃើញ៖ ប្រជាជនខ្មែរយល់ដឹងអំពីវប្បធម៌បុរាណ យុវជនបន្តរៀនអំពីសិល្បៈ ផ្តល់តម្លៃដល់សិល្បៈឱ្យដូចតន្ត្រី/ចម្រៀង ទទួលបានការគាំទ្រឱ្យស្មើនឹងការប្រគំតន្ត្រី។»

«ខ្ញុំចង់ឃើញរបាំ តន្ត្រី ចម្រៀង ភាពយន្ត មានការទទួលស្គាល់ទូលំទូលាយនៅក្នុងប្រទេសជិតខាង។»

«យើងត្រូវបន្តដើរទៅមុខ និងពុះពារដោយមិនខ្វល់នឹងឧបសគ្គរាប់មិនអស់ដែលយើងប្រឈម។ ខ្ញុំចង់ឃើញវិស័យទាំងអស់រីកចម្រើនក្នុងប្រទេសកម្ពុជា។ ខ្ញុំចង់ឃើញប្រទេសនេះមាន/អនុវត្តប្រព័ន្ធប្រជាធិបតេយ្យក្នុងរយៈពេល៥ឆ្នាំខាងមុខ។ ខ្ញុំចង់បានប្រាក់ខែល្អប្រសើរ។»

«ក្នុងនាមជាយុវជន ខ្ញុំយល់ថាដើម្បីជួយចូលរួមចំណែកក្នុងការអភិវឌ្ឍវិស័យសិល្បៈនិងវប្បធម៌ខ្មែរ តម្រូវឱ្យមានការចូលរួមពីមនុស្សទាំងអស់ពីវណ្ណៈផ្សេងៗ និងតម្រូវឱ្យយើងលើកកម្ពស់មរតកដូចតាយើងដល់មនុស្សដទៃទៀត។»

«សកម្មភាពទាំងឡាយដែលចូលរួមដល់ការអភិវឌ្ឍវិស័យវប្បធម៌និងសិល្បៈអាចមានពីការផ្សព្វផ្សាយនិងចែកចាយនៅលើបណ្តាញសង្គម និងគាំទ្រតាមរយៈការមើលនិងទិញផលិតផលវប្បធម៌។»

«ខ្ញុំចង់ឃើញការច្នៃប្រតិដ្ឋថ្មីក្នុងសិល្បៈនិងវប្បធម៌ខ្មែរ ខ្ញុំចង់ឱ្យការច្នៃប្រតិដ្ឋនេះមានអត្ថន័យនិងគំនិតដើម្បីជំរុញដល់ការអភិវឌ្ឍសង្គម។»

តាមរយៈសារទាំងនេះ ច្បាស់ណាស់ថាការបន្តថែរក្សាសិល្បៈ ការអភិវឌ្ឍសង្គម និងអន្តរទំនាក់ទំនងនៃធាតុទាំងនេះឆ្លុះបញ្ចាំងជាគម្រោងសង្គមមួយដែលតម្រូវឱ្យមានការចូលរួមពីមនុស្សគ្រប់គ្នា។



យុវជនក៏ទទួលបានការលើកទឹកចិត្តឱ្យក្លាយជាផ្នែកមួយនៃមហោស្រពនេះដែរតាមរយៈការអំពាវនាវទូទៅឱ្យមានការប្រកួតរូបថតអំពីមូលបទ«យុវជននិងអតីតកាល»ដែលផ្សព្វផ្សាយតាមរយៈទំព័រហ្វេសប៊ុកនៃព្រឹត្តិការណ៍នេះ។ ច្រកមួយនេះបង្កើតឡើងជាពិសេសសម្រាប់ក្រុមអ្នកថតរូបវ័យក្មេងមិនអាជីពនៅទូទាំងប្រទេសកម្ពុជា។ ក្រុមអ្នកហាត់ការជ្រើសរើសអ្នកថតរូបដែលល្អ ហើយផ្សព្វផ្សាយរូបថតរបស់ពួកគេលើទំព័របណ្ដាញសង្គមផងនិងតាំងបង្ហាញជាផ្នែកមួយនៃមហោស្រពនេះរួមជាមួយនឹងរូបថតពីអ្នកថតរូបជំនាញពីរនាក់ដែលទទួលបានការអញ្ជើញ។ បន្ទាប់មក ក្រុមទស្សនិកជនអាចបោះឆ្នោតជ្រើសរើសរូបថតណាដែលពួកគេចូលចិត្តតាមរយៈការចុចlikes/shares តាមសញ្ញាQRដែលមានបោះពុម្ពនៅខាងក្រោមរូបថតដែលដាក់តាំងបង្ហាញទាំងនោះ ឬតាមរយៈការបោះឆ្នោតនិងបញ្ចេញយោបល់នៅក្នុងប្រអប់ដែលចាក់សោ។ មធ្យោបាយនេះមិនត្រឹមតែផ្ដល់ឱ្យយុវជននូវសមត្ថភាពចូលរួមនិងបង្ហាញទេពកោសល្យរបស់ពួកគេក្នុងព្រឹត្តិការណ៍ធំៗប៉ុណ្ណោះទេ (ជារឿងសំខាន់ចំពោះក្រុមអ្នកប្រកួតប្រជែងមកពីបណ្ដាខេត្ត) ប៉ុន្តែក៏ផ្ដល់នូវសមត្ថភាពដើម្បីបង្ហាញការចូលចិត្តរបស់ពួកគេតាមរយៈយន្តការផ្សេងៗនៃការបោះឆ្នោតដែរ។ សំឡេងឆ្នោតពីយន្តការបោះឆ្នោតផ្សេងៗត្រូវយកមកបញ្ចូលគ្នា រួចប្រកាសជ័យលាភី ដែលមានរង្វាន់ជាប្រាក់បន្តិចបន្តួចដែរ។ រូបថតល្អជាងគេបីសន្លឹកខាងក្រោមនេះ ហើយជ័យលាភីគឺ *«គ្រួសារមួយដែលកក់ក្ដៅ»* ដែលសុត សុជីលី ជាអ្នកថតទទួលបានឆ្នោតទាំងអស់ចំនួន១៤៥១សំឡេង។ រូបថតទាំងនេះនិងខ្លឹមសារខ្លីៗទទួលបានការចាប់អារម្មណ៍ចំពោះរបៀបឆ្លុះបញ្ចាំងកង្វល់ផ្សេងៗរបស់យុវជន ដោយបង្ហាញនូវសារៈសំខាន់នៃវប្បធម៌ចំពោះគ្រួសារ និងគ្រួសារគំរូ បំណងចង់បានទំនាក់ទំនងសមូហភាពនៅផ្នែកផ្សេងៗក្នុងសង្គម និងសារៈសំខាន់នៃសិល្បៈនិងវប្បធម៌អតីតកាលដើម្បីកសាងអនាគតថ្មី ជាពិសេសនៅក្នុងពិភពលោកនៃសកលភាវូបនីយកម្មនេះ។ តាមរយៈសំណេរនិងកិច្ចសម្ភាសន៍ខ្លីជាមួយទស្សនិកជនដែលបានមើលរូបថតទាំងនេះ យើងក៏ដឹងថាមានយុវជនជាច្រើនយល់ឃើញថារូបថតទាំងនោះបានធ្វើឱ្យពួកគេគិតដល់កុមារភាពរបស់ពួកគេ ភាគច្រើនដោយសាររូបថតទាំងនោះមានយុវជនច្រើន ប៉ុន្តែក៏បានធ្វើឱ្យពួកគេស្ញប់ស្ញែងចំពោះភាពចម្រុះរបស់ប្រទេសកម្ពុជានិងទិដ្ឋភាពរបស់ប្រទេសនេះដែរ។



## គ្រួសារមួយដែលកក់ក្ដៅ

*«យុវជនជាទូទៅ និងមនុស្សគ្រប់គ្នាគឺតែងតែមានអតីតកាលនៃកុមារភាពក្នុងគ្រួសារដ៏កក់ក្ដៅមួយ។ ទម្រាំបង្កើតបានគ្រួសារមួយ មនុស្សយើងត្រូវប្រឈមនឹងបញ្ហាស្មុគស្មាញច្រើនណាស់។ ប៉ុន្តែ រូបភាពនេះឆ្លុះបញ្ចាំងថាឪពុកម្ដាយនៅតែអាចធ្វើជាឪពុកម្ដាយគំរូ ហើយអាចផ្ដល់ភាពកក់ក្ដៅដល់កូនៗជានិច្ច បើទោះជាជីវភាពពួកគាត់មិនសូវធូរធារក៏ដោយ។»*

**សុត សុជីលី** ខេត្តកណ្ដាល



## យើងតែមួយ

*«មេឃហាក់ដូចជាផ្ទាំងនៃប្រវត្តិអតីតកាល ឯខ្សែអំបោះជាសិល្បៈភ្ជាប់មនុស្សពីម្នាក់ទៅម្នាក់ មិនថាចាស់ក្មេង ប្រុសស្រី។ ផ្ទាំងទស្សនីយភាពនេះហើយជាសង្គមជាតិទាំងមូល ដែលទាមទារឱ្យយើងរួមគ្នា ដើរទៅជាមួយគ្នា ហើយរស់ជាមួយគ្នាដោយភាពតភាព។»*

**អ៊ូ បាណុង** ភ្នំពេញ



## ការអភិរក្សបេតិកភណ្ឌ៖

*«និស្សិតស្ថាបត្យកម្ម ស្វែងយល់អំពីស្ថាបត្យកម្មខ្មែរថ្មី»*

*«ស្ថាបត្យកម្មខ្មែរថ្មី គឺជានិមិត្តរូបនៃឯករាជ្យភាពថ្មីរបស់ប្រទេសកម្ពុជា និងបំណងប្រាថ្នាដើម្បីធ្វើទំនើបកម្ម។ ចលនានេះគឺជាការលាយបញ្ចូលគ្នានៃស្ថាបត្យកម្មខ្មែរបុរាណ និងរចនាបថអន្តរជាតិទំនើប ដោយអបអរសាទរបេតិកភណ្ឌវប្បធម៌ដ៏សម្បូរបែបរបស់កម្ពុជា។*

*រូបថតនេះចាប់យកពេលមួយដែលសិស្សជំនាន់ក្រោយ កំពុងចាប់អារម្មណ៍ក្នុងការស្វែងយល់ពីបេតិកភណ្ឌជាតិ ដោយសម្លឹងមើលអគារវិទ្យាស្ថានភាសាបរទេសសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ រូបថតនេះគឺជាការរម្លឹកពីសារៈសំខាន់នៃការអប់រំយុវជនអំពីបេតិកភណ្ឌនិងវប្បធម៌របស់ពួកគេ។ វាក៏ជាការអបអរសាទរដល់យុវជនដែលឆ្លៀតពេលសិក្សាស្វែងយល់ និងថែរក្សាស្ថាបត្យកម្មខ្មែរថ្មី ដោយបង្ហាញពីការស្វែងយល់អំពីអតីតកាល ដើម្បីសាងសង់អនាគតដ៏ល្អប្រសើរសម្រាប់កម្ពុជា។»*

**ម៉ក់ ម៉ូលីឫទ្ធរុទ្រ** ភ្នំពេញ











បន្ថែមលើការប្រកួតរូបថត ក្រុមអ្នកហាត់ការបានជ្រើសរើសការសម្តែង៤ទម្រង់ (របាំបុរាណ របាំសហសម័យ ការច្រៀងរ៉ែប និងការច្រៀងចាប៉ី) ពីការអំពាវនាវឱ្យមានការប្រកួតទេពកោសល្យបើកទូលាយ ជាថ្មីម្តងទៀតគឺផ្សព្វផ្សាយតាមរយៈទំព័រហ្វេសប៊ុករបស់ព្រឹត្តិការណ៍នេះ ទំព័របណ្តាញសង្គមហ្វេសប៊ុករបស់អង្គការសិល្បៈខ្មែរអមតៈ និងបណ្តាញសិល្បៈដទៃទៀត។ ទោះជាយ៉ាងណា ការរៀបចំនេះមានបំណងចង់បង្ហាញទេពកោសល្យដែលជួយជំរុញសិល្បករជាយុវជននិងសិល្បករដែលទើបប្រឡូកក្នុងវិថីសិល្បៈឱ្យសម្តែងសមត្ថភាព ដោយមិនរំលេចពីគំនិតប្រកួតប្រជែងក្នុងនោះទេ។ ដូច្នេះ ឱកាសជួបឆ្លើយឆ្លងជាមួយនឹងទស្សនិកជន និងការជ្រើសរើស«ជ័យលាភី»ត្រូវកាត់បន្ថយ ប៉ុន្តែក្រុមអ្នកហាត់ការចង់ផ្តល់តម្លៃស្មើគ្នាដល់ទម្រង់ផ្សេងៗនៃសិល្បៈដែលបានបង្ហាញ និងមិនកាត់សេចក្តីរវាងទម្រង់សិល្បៈទាំងនេះទេ។ ការណ៍នេះមានសារៈសំខាន់ជាពិសេសដោយសារឥទ្ធិពលមួយក្នុងចំណោមឥទ្ធិពលនៃការចូលរួមក្នុងដំណើរការនេះសម្រាប់ក្រុមអ្នកហាត់ការគឺការយល់ដឹងនិងឱ្យតម្លៃភាពចម្រុះនៃសិល្បៈ មិនមែនគិតត្រឹមតែទម្រង់ណាមួយនៃសិល្បៈនោះទេ។

*«ពីមុន ខ្ញុំយល់ថារបាំបុរាណមានតម្លៃជាងបើប្រៀបនឹងរបាំផ្សេងទៀត។ ទោះជាសិល្បៈគំនូរ ភាពយន្ត ការតែងនិពន្ធ ឬសិល្បៈអ្វីក៏ដោយ គ្រប់ទម្រង់នៃសិល្បៈមានតម្លៃស្មើគ្នានិងអត្ថន័យរៀងៗខ្លួន។ ព្រឹត្តិការណ៍បានបង្រៀនខ្ញុំឱ្យចេះវាយតម្លៃសិល្បៈបានស្មើគ្នា។»*

(ឃឿន កំសត់ អ្នកហាត់ការ)

ក្រុមអ្នកចូលរួមប្រកួតសម្តែងទេពកោសល្យ ដូចអ្នកដែលបានសរសេរសារភ្ជាប់លើដើមឈើដែរ តែងតែខ្វល់ខ្វាយរឿងថែរក្សាសិល្បៈឱ្យនៅមានជីវិតតាមរយៈការសម្តែងនិងបង្ហាញទេពកោសល្យរបស់ពួកគេ ក៏ដូចជាតាមរយៈការបង្រៀននិងការរៀនសិល្បៈ។ ទោះជាយ៉ាងណាពួកគេក៏ចង់លើកទឹកចិត្តយុវជនឱ្យមានភាពក្លាហាន ក្រោកឈរចំពោះអ្វីដែលពួកគេជឿជាក់ និងក្លាហានរៀបចំព្រឹត្តិការណ៍ដោយខ្លួនឯងឬទទួលបានការជំរុញទឹកចិត្តឱ្យធ្វើបែបនោះ៖

*«ការបង្ហាញទេពកោសល្យអាចបង្កើនភាពក្លាហានរបស់យុវជន ហើយយុវជនអាចបង្ហាញទេពកោសល្យរបស់ពួកគេ។ [...]ខ្ញុំសង្ឃឹមថាយុវជនដែលមានទេពកោសល្យអាចចូលរួមក្នុងមហោស្រពនានានៅពេលខាងមុខដោយសារវាជារឿងល្អចំពោះពួកគេដែលត្រូវបង្កើតទំនាក់ទំនងជាមួយអ្នកដទៃជាមួយគ្រូនិងសិល្បករផ្សេងទៀតដែលអាចបង្កើតជាសហគមន៍កាន់តែធំមួយបាន។»*

(វី មុនីបញ្ញា អ្នកចម្រៀងរ៉ែប)

*«អ្នកដទៃនឹងមានអារម្មណ៍ទទួលបានកម្លាំងចិត្តនៅពេលឃើញសកម្មភាពយុវជននេះ និងមានអារម្មណ៍អស្ចារ្យដោយសារភាពក្លាហាននៃអ្នករៀបចំព្រឹត្តិការណ៍នេះ។ មនុស្សខ្លះប្រហែលមានអារម្មណ៍ទទួលបានកម្លាំងចិត្តចង់រៀបចំព្រឹត្តិការណ៍ដោយខ្លួនឯង។»*

(សូ សារុន អ្នកចម្រៀងចាប៉ី)



នៅក្នុងចំណុចនេះ បំណងចង់លើកកម្ពស់សិល្បៈនិងវប្បធម៌ជាតិកើតមានព្រមគ្នានឹងគំនិតដែលយល់ឃើញថាមានសារៈសំខាន់ក្នុងការប្រើប្រាស់សិល្បៈដើម្បី**បង្កើតសាមគ្គីភាព ឆ្លើយតបទៅនឹងបញ្ហាសង្គម និងប្រមូលផ្តុំសក្តានុពលនៃយុវជន**ជាពិសេសដើម្បីធ្វើឱ្យសង្គមជាទូទៅកាន់តែប្រសើរឡើង។ ជាក់ស្តែង លោកសូ សារុន បានប្រើប្រាស់ចាប៉ីដើម្បីច្រៀងអំពីបញ្ហាសង្គម ដូចជាហិង្សាក្នុងគ្រួសារ ការប្រើប្រាស់គ្រឿងញៀន និងការលេងល្បែងភ្នាល់ជាដើម។ ក្រុមរបាំសហសម័យ(គ្រិស្នារក្ស)របស់លោក រឹទ្ធ ដារ៉ូ បានសម្តែងទស្សនីយភាពមួយឈ្មោះ «Dear G» (នារីជាទីស្រឡាញ់) ដើម្បីបង្ហាញពីអំពើហិង្សា និងការបំពារបំពានលើស្ត្រីនិងនារីវ័យក្មេង ដោយជម្នះនឹងទំនៀមវប្បធម៌ដែលច្រើនតែស្តីបន្ទោសលើមនុស្សស្រីនៅពេលគ្រួសារបែកបាក់គ្នា ឬពេលមានគេរំលោភ៖

*«ខ្ញុំដឹងរឿងនេះពីបណ្តាញសង្គម។ ខ្ញុំឃើញការបញ្ចេញយោបល់ជាច្រើនទាក់ទងនឹងការរំលោភបំពានលើកុមារនិងមនុស្សស្រី។ ជាក់ស្តែង បុរសចំណាស់ម្នាក់បានរំលោភក្មេងស្រីតូចម្នាក់។ ដំបូង ក្មេងស្រីនោះភ័យខ្លាចគាត់។ ប៉ុន្តែបុរសចាស់នោះចេះតែផ្តល់របស់លេងរហូតដល់នាងទុកចិត្តគាត់។ បន្ទាប់មកគាត់រំលោភក្មេងស្រីនោះ។ ប៉ុន្តែមនុស្សមិនបានស្តីបន្ទោសបុរសចាស់នោះទេ គេបែរជាបន្ទោសក្មេងស្រីទៅវិញ។ គេថានោះជាកំហុសរបស់នាង។ គេនិយាយអំពីរបៀបដែលនាងស្លៀកពាក់ ឬនិយាយថានាងបើកដៃឱ្យគេពេក។ យើងចង់ផ្លាស់ប្តូរការយល់ឃើញបែបនេះតាមរយៈផ្ទាំងទស្សនីយភាពរបស់យើង។ បើនាងជួបប្រទះនឹងបញ្ហាបែបនោះ យើងគួរជួយគាំទ្រនាង និងលុបលាងស្នាមខ្មៅទាំងអស់ចេញពីរូបនាង។ [...] តាមរយៈផ្ទាំងទស្សនីយភាពនេះ យើងរៀបរាប់ថាពណ៌របស់មនុស្សគឺដូចគ្នានឹងពណ៌របស់ឥន្ទធនូដែរ យើងស្រស់ស្អាតក្នុងរបៀបផ្ទាល់ខ្លួនរបស់យើង ប៉ុន្តែតើនឹងមានអ្វីកើតឡើងបើមានស្នាមខ្មៅនៅលើពណ៌របស់យើង? យើងចង់ប្រាប់ទស្សនិកជនរបស់យើងអំពីស្ថានភាពរបស់មនុស្សដែលឆ្លងកាត់បទពិសោធន៍បែបនោះ នាងសំងំនៅដាច់ពីគេឯង ហើយប្រឈមនឹងការឈឺចាប់នោះ។ មនុស្សខ្លះថែមទាំងសម្រេចចិត្តធ្វើអត្តឃាតទៀតផង។»*

(រឹទ្ធ ដារ៉ូ អ្នករបាំ)

ជុំវិញបញ្ហាទាំងនេះ សិល្បៈត្រូវគេឃើញថាមានទំនាក់ទំនងពីធម្មជាតិស្រាប់ទៅនឹងសង្គម ហើយត្រូវគេប្រើប្រាស់ដើម្បីឆ្លុះបញ្ចាំងបញ្ហាសង្គមដែលយុវជនប្រឈម ប៉ុន្តែក៏ត្រូវគេប្រើដើម្បីបង្កើតសង្គមគាំទ្រមួយដែលនឹងលើកទឹកចិត្ត ជាជាងបន្ទុះបង្អាប់។ សិល្បករម្នាក់ៗសង្ឃឹមចង់ប្រើប្រាស់សិល្បៈដើម្បីលើកកម្ពស់អ្វីដែលយុវជនមើលឃើញជាទម្រង់វឌ្ឍនភាពនៃការផ្លាស់ប្តូរសង្គម (ដោយរួមទាំងការឱ្យតម្លៃកាន់តែច្រើនដល់សិល្បៈប្រពៃណី) តាមរយៈទម្រង់សិល្បៈទាំងបុរាណនិងសហសម័យ។

ព្រឹត្តិការណ៍សំខាន់មួយដែលបង្កើតឱ្យមានភាពចម្រុះនិងការចូលរួមគឺតាមរយៈការបង្ហាញម៉ូដក្រោមការដឹកនាំរបស់រាជិនីម៉ូដ JC Kween ឈ្មោះ«ខ្ញុំគឺ...ហើយខ្ញុំជឿជាក់ថា»។ នៅទីនេះ បុគ្គល១០រូបមកពីក្រុមដែលមានសំឡេងតិច ក្នុងសង្គមបានទទួលការអញ្ជើញឱ្យចូលរួមដើរបង្ហាញម៉ូដក្នុងសម្លៀកបំពាក់ដែលពួកគេចង់ស្លៀកពាក់បង្ហាញឱ្យឃើញថាពួកគេជានរណា និងអះអាងម្ចាស់កម្មសិទ្ធិលើអត្តសញ្ញាណរបស់ពួកគេស្របទៅនឹងសំឡេងចម្រៀង«This is Me» ដកស្រង់ចេញពីខ្សែភាពយន្តរឿង «The Greatest Showman»។ អ្នកដើរបង្ហាញម៉ូដទាំងអស់នេះមានបុគ្គលដែលមានពិការភាពនិងមានបញ្ហាសុខភាពផ្លូវចិត្ត ក្រុមជនជាតិដើម ស្ត្រីអ៊ីស្លាម កម្មការិនីរោងចក្រស្ត្រីដែលរងការមាក់ងាយដោយសាររបៀបដែលពួកគេស្លៀកពាក់ និងបុគ្គលដែលស្រឡាញ់ភេទដូចគ្នា។ ជំហរគំនិតមួយចំនួនរបស់ពួកគេមានដូចជា៖

> “
>
> *ខ្ញុំឈ្មោះដារាជ។ ខ្ញុំជឿជាក់ថា អាពាហ៍ពិពាហ៍នៃអ្នកស្រឡាញ់ភេទដូចគ្នា (នៃសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា) នឹងមានច្បាប់ទទួលស្គាល់ក្នុងប្រទេសកម្ពុជានៅពេលឆាប់ៗនេះ។*
>
> *ខ្ញុំឈ្មោះតីភ័ស្ស។ ខ្ញុំសង្ឃឹមថាមនុស្សស្រីទាំងអស់មានសិទ្ធិស្លៀកពាក់តាមបែបណាដែលគេចង់បានដោយមិនមានការរើសអើង ឬមាក់ងាយ (ជាពិសេសស្ត្រីមូស្លីម) មិនថានៅកន្លែងធ្វើការ ឬនៅក្នុងទីសាធារណៈ។*
>
> *ខ្ញុំគឺសាណា។ ខ្ញុំជឿថាកម្មកររោងចក្រទាំងអស់នឹងមានការងារច្រើនធ្វើ ហើយមានប្រាក់ខែសមរម្យដើម្បីរស់ និងផ្គត់ផ្គង់គ្រួសាររបស់ពួកគេ។ ខ្ញុំសង្ឃឹមថាពួកគេអាចធ្វើការក្នុងបរិយាកាសមួយដែលផ្តល់ការគាំទ្រនិងមានប្រព័ន្ធគាំពារច្បាស់លាស់។*

ជំហរគំនិតទាំងនេះ ជាចលករយ៉ាងខ្លាំងចំពោះយុវជនជាច្រើននាក់ ហើយពោរពេញដោយការជំរុញចិត្តនិងថាមពលពេលមើលឃើញជំហរនៃបរិយាបន្ននិងភាពចម្រុះដោយផ្ទាល់បែបនេះ។

ទោះជាយ៉ាងណា នៅក្នុងការអនុវត្ត ក៏មានបញ្ហាប្រឈមខ្លះដែរក្នុងការលើកកម្ពស់ការចូលរួមប្រកបដោយសមភាព។ ទី១ ការស្វែងរកកន្លែងសមស្របដែលអាចរៀបចំកម្មវិធីចម្រុះ ហើយមានតម្លៃសមរម្យនិងងាយចូលបានជារឿងលំបាក។ សួនCoconut Park មានបន្ទប់ជាន់លើដែលឡើងបានតែតាមជណ្តើរ ហើយក៏មានការរៀបចំសិក្ខាសាលាមួយចំនួននៅទីនោះដែរ ជាពិសេសសម្រាប់អ្នកនៅក្នុងផ្នែករបាំ។ ដំបូងឡើយ សិក្ខាសាលាទាំងអស់គ្រោងនឹងរៀបចំឡើងនៅក្នុងសួនធំនេះ ប៉ុន្តែមានបញ្ហាទំនាក់ទំនងនិងការសម្របសម្រួល ដោយសារក្រុមអ្នកបង្ហាញទេពកោសល្យត្រូវហាត់សមនៅលើឆាកធំ ក្នុងពេលដែលកំពុងតែមានសិក្ខាសាលា។ ជាលទ្ធផល សិក្ខាសាលារបាំ ដែលត្រូវមានភ្លេង ក៏ប្តូរទៅជាន់លើវិញនៅនាទីចុងក្រោយ។ ការផ្លាស់ប្តូរនេះនាំឱ្យជនដែលមានពិការភាពមួយចំនួនមិនអាចចូលរួមបាន ហេតុដូច្នេះហើយក៏មានការខកចិត្តនិងអារម្មណ៍ដែលគេមិនបានរាប់រក ជារឿងដែលក្រុមអ្នកហាត់ការដឹងនិងមិនសប្បាយចិត្ត ប៉ុន្តែមិនអាចដោះស្រាយបានពេញលេញ។ ក្រុមអ្នកហាត់ការក៏មានកង្វល់ដែរអំពីទីតាំងដែលស្ថិតនៅក្នុងតំបន់ក្រុមអភិជន បើទោះជាកន្លែងនោះនៅជិតក្រុង(កោះពេជ្រ)ក៏ដោយ និងបារម្ភចំពោះកត្តាដទៃទៀតដែលនៅក្នុងការពិចារណាក្រោយមកពួកគេយល់ថាមានតម្លៃថ្លៃ ដូចជាតម្លៃនំបញ្ចុកជាដើម ដូច្នេះ មនុស្សត្រូវចេញពីទីតាំងមហោស្រពនៅពេលពួកគេឃ្លានក្នុងពេលល្ងាច ជាជាងនៅមើលរហូតដល់ចប់។



# ០៥

# ឥទ្ធិពលនៃការចូលរួមក្នុងមហោស្រពនេះចំពោះទស្សនិកជន

**ចំណុចចុងក្រោយដែលអាចយកមកពិចារណាបានចំពោះមហោស្រពនេះទាក់ទងនឹងការចូលរួមរបស់ពលរដ្ឋក្នុងចំណោមយុវជនគឺត្រូវពិចារណាដល់ឥទ្ធិពលមានក្រុមអ្នកហាត់ការ ក្រុមអ្នកស្ម័គ្រចិត្ត និងទស្សនិកជនដែលបានចូលរួម។ ចំណុចនេះមានៈ**

- ការជជែកដេញដោលជុំវិញបរិមាណនិងគុណភាពនៃការចូលរួម
- ការយល់ដឹងកាន់តែច្រើនអំពីសិល្បៈ
- ការបង្កើតបណ្តាញនិងសហគមន៍ពីនានាភាព



# បរិមាណនិងគុណភាពនៃការចូលរួម

ចំណុចគន្លឹះដែលត្រូវពិចារណា គឺប្រភេទនៃការចូលរួមដែលជំរុញ (ឬមិនជំរុញ) ដោយមហោស្រពនេះ និងរបៀបដែលអាចវាយតម្លៃជោគជ័យនៃមហាស្រពនេះ។ សំណួរដែលផុសឡើងគឺតើការចូលរួមរបស់ពលរដ្ឋប្រភេទណាដែលសិល្បៈអាចនឹងរក្សាបានក្នុងបរិបទនេះ។ ការឆ្លើយតបនិងគុណតម្លៃត្រង់នេះដែលនឹងរងឥទ្ធិពលដោយជៀសមិនរួចពីជំហរផ្សេងៗនៃក្រុមអ្នកឆ្លើយតប តើជាការចូលរួមយ៉ាងជោគជ័យដោយផ្អែកលើចំនួនទស្សនិកជនមែនទេ? តើផ្អែកលើការចុចមើលឬចូលចិត្តរបស់ទស្សនិកជន? តើការចូលរួមនេះមានអត្ថន័យយ៉ាងណា ហើយតើការចូលរួមបែបនេះពិតជាសំខាន់ដែរទេ? តើការចូលរួមរបស់ពលរដ្ឋដែលជោគជ័យត្រូវផ្អែកលើសមត្ថភាពដើម្បីរក្សាការគិតល្អិតល្អន់ ឬការបង្កើតអារម្មណ៍សហគមន៍ឬក៏ភាពជាម្ចាស់? តើធាតុណាមួយដែលមានតម្លៃខ្លាំងបំផុត? ទោះបីក្រុមអ្នកហាត់ការទទួលបានកម្រៃខ្លះ ក៏ពួកគេបានធ្វើការយ៉ាងពេញដៃពេញជើងលើសពីកម្រៃនោះដែរ។ ត្រង់ចំណុចនេះ ការកំណត់ក្របខ័ណ្ឌ«អ្នកស្ម័គ្រចិត្ត»នៃការចូលរួមដែលប្រើប្រាស់ក្នុងវិស័យសង្គមអាចនាំទៅរកការទម្លាក់តម្លៃនៃសិល្បៈនិងក្រុមមនុស្សដែលពាក់ព័ន្ធនឹងសិល្បៈ។ ការសិក្សាស្រាវជ្រាវនិងការងារអនុវត្តជាច្រើនអំពីសិល្បៈការចូលរួមរបស់ពលរដ្ឋ និងការអភិវឌ្ឍសង្គមផ្តល់តម្លៃដល់សិល្បៈចំពោះរបៀបដែលគេប្រើប្រាស់សិល្បៈក្នុងសកម្មភាព ឬចំពោះរបៀបដែលសិល្បៈបង្ហាញការស្រមើស្រមៃថ្មីនៃសង្គម ទោះជាយ៉ាងណាចំណុចនេះមិនអាចសន្និដ្ឋានបានទេ ហើយទំនាក់ទំនងរវាងសិល្បៈនិងវិស័យសង្គមមានលក្ខណៈស្រដៀងគ្នាណាស់។ ការណ៍នេះកើតឡើងដោយសារគេមិនអាចទាយចិត្តទស្សនិកជនដែលមានបទពិសោធន៍ផ្សេងៗគ្នា និងអាចចាប់យកសារខុសៗគ្នាចេញពីព្រឹត្តិការណ៍។

ក្នុងការពិចារណាបញ្ហាបរិមាណនិងគុណភាពនៃការចូលរួម ចំណុចដែលគួរគូសបញ្ជាក់មួយទៀតគឺថា ពេលខ្លះយុវជនមកចូលរួមដោយគ្រាន់តែចង់សប្បាយនឹងសិល្បៈជាការកម្សាន្តប៉ុណ្ណោះ។ ទស្សនិកជនរីករាយនឹងកម្មវិធីមហោស្រព ពួកគេចូលចិត្តមើលទម្រង់សិល្បៈផ្សេងៗដែលយកមកបង្ហាញជាមួយគ្នា ហើយពួកគេយល់ថាភាពចម្រុះដែលផ្តល់ជូននោះគួរឱ្យ*«ស្ញប់ស្ញែង»*និងអាចមើលបាន *«មិនរញ៉េរញ៉ៃពេក មិនពិបាកចូលរួមពេក ហើយមិនស្មុគស្មាញពេក»* (ទស្សនិកជនដែលផ្តល់បទសម្ភាសន៍ខ្លីៗ)។ ហេតុដូច្នេះហើយ ក្នុងទិដ្ឋភាពខ្លះ មហោស្រពនេះបានជួយបង្ហាញជាទម្រង់មួយនៃការចូលរួម៖

*«ខ្ញុំបានសួរមិត្តរបស់ខ្ញុំ ហើយពួកគេនិយាយថាពួកគេមិនដែលបានឃើញក្រុមស្គរស្ត្រីមេធា របាំសហសម័យ និងក្រុមស្គរប៉ុកពីមុនមកទេ។ ចំពោះស្គរធំជាពិសេស ពួកគេនិយាយថាមិនដែលឃើញទេ។ ពួកគេធ្លាប់ឃើញតែការប្រគំតន្ត្រីប្រជាប្រិយ និងភ្លេងបុរាណប៉ុណ្ណោះ។ ពួកគេលើកឡើងថា ពួកគេអរគុណនិងសប្បាយចិត្តដែលបានឃើញការសម្តែងទាំងអស់នោះ។»*

(កិច្ចសម្ភាសន៍ មាឃ បុប្ផារតនះ)

សមាជិកទស្សនិកជនខ្លះកត់សម្គាល់ថាពួកគេពិបាករកមើលការសម្តែងក្រៅពីព្រឹត្តិការណ៍ធំៗដែលចាក់ផ្សាយតាមទូរទស្សន៍ ហើយពួកគេចង់ឃើញការសម្តែងផ្ទាល់បន្ថែមទៀត និងការលាយបញ្ចូលគ្នាកាន់តែច្រើនថែមទៀត។ ចំណុចនេះមានលក្ខណៈលេចធ្លោជាពិសេសដោយសារប្រទេសកម្ពុជាទើបតែរៀបចំព្រឹត្តិការណ៍ធំៗ ដូចព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍ ដែលគេបានបង្ហាញវប្បធម៌ឱ្យឃើញយ៉ាងច្បាស់តាមរយៈពិធីបើកនិងបិទដែលចាក់ផ្សាយតាមទូរទស្សន៍។



ទោះជាយ៉ាងណា មិនមែនមានន័យថាការគ្រាន់តែមើលការសម្តែងជាការយល់តែសម្បកក្រៅ ហើយទាល់តែសិក្ខាសាលាទើបនាំទៅរកការចូលរួមកាន់តែជ្រៅជ្រះនោះទេ។ ជាក់ស្តែង អ្នកស្ម័គ្រចិត្តម្នាក់ដែលបានមើលការសម្តែងទាំងនោះលើកឡើងថា*«មហោស្រពនេះជំរុញចិត្តខ្ញុំខ្លាំងណាស់។ ខ្ញុំអាចមើលឃើញទម្រង់សិល្បៈថ្មីៗ ជាពិសេសបានមើលការសម្តែងរបស់សិល្បករមកពីខេត្តទៀតផង។»* (កិច្ចសម្ភាសន៍ខ្លី អ្នកស្ម័គ្រចិត្ត)។ ការសម្តែងនិងព្រឹត្តិការណ៍ដែលបង្ហាញច្រើនតែជួយលើកកម្ពស់គំនិតវឌ្ឍនភាពដែលយុវជនយល់ឃើញថាជំរុញទឹកចិត្ត ជាពិសេសនៅជុំវិញភាពចម្រុះ សមភាព និងសិទ្ធិ។ ជាក់ស្តែង របាំសហសម័យ«សេរីភាព»របស់ក្រុមSilverBelle បានផ្តល់នូវការបកស្រាយជំហរសង្គមរបស់ស្ត្រី ដោយមានអ្នករាំជាស្ត្រីម្នាក់ចាប់ផ្តើមសម្តែងជាអាយ៉ងនៅក្រោមការគ្រប់គ្រងពីដៃគូជាបុរស មុនពេលបញ្ចប់នៅទីបំផុតដោយការមានសេរីនិងសម្តែងអំពីខ្លួនឯងវិញ បើទោះជាផ្ទាំងទស្សនីយភាពនោះក៏អាចបកស្រាយជាការបង្ហាញសេរីភាពនៃការបញ្ចេញមតិក្នុងសង្គមជាទូទៅបានដែរ។ ទស្សនិកជនមើលស្គាល់ធាតុទាំងអស់នៃការសម្តែងទាំងនេះ ហើយទទួលបានការជំរុញចិត្តពីការសម្តែងទាំងនោះ ជាពិសេសក្រុមស្គរស្ត្រីមេធា ដោយសារគេកម្របានឃើញអ្នកវាយស្គរជាស្ត្រីណាស់ ពីព្រោះក្នុងប្រវត្តិសាស្ត្រជាបម្រាមវប្បធម៌មនុស្សស្រីមិនអាចប៉ះស្គរបានទេ៖

*«ក្រុមអ្នកវាយស្គរ រម្លឹកយើងឱ្យដឹងថា យើងមិនត្រូវបោះបង់សុបិនខ្លួនឯងជាស្ត្រីចោលទេ បើទោះជាអ្នកមានកូនក៏ដោយ។»*

(កិច្ចសម្ភាសន៍ខ្លីជាមួយទស្សនិកជន)

ទស្សនិកជនជាច្រើនរៀបរាប់របៀបដែលពួកគេភ្ញាក់ផ្អើល ឬ*«ញាប់ញ័រ»*(កិច្ចសម្ភាសន៍ខ្លីជាមួយទស្សនិកជន) ដោយសារការសម្តែងនេះនិងឥទ្ធិពលរបស់វា។ ស្រដៀងគ្នានេះដែរ សិក្ខាសាលាអំពីសុខភាពផ្លូវចិត្តក៏ទទួលបានជោគជ័យខ្លាំងដែរ ហើយអ្នកចូលរួមជាច្រើន ក៏ដូចជាលោក សុង សេង បានយល់ឃើញពីលក្ខណៈពិសេសនិងប្រយោជន៍នៃសិក្ខាសាលានេះ៖

*«នេះជាលើកទីមួយរបស់ខ្ញុំក្នុងការរៀបចំសិក្ខាសាលាអំពីសុខភាពផ្លូវចិត្តទាក់ទងនឹងសិល្បៈ។ ជារឿងគួរឱ្យចាប់អារម្មណ៍ណាស់ដែលបានឮរាគ្និននិងអ្នកចូលរួមចែករម្លែកបទពិសោធន៍របស់ពួកគេ។ ខ្ញុំយល់ថារឿងនេះពិតជាសំខាន់ណាស់ ហើយខ្លួនខ្ញុំផ្ទាល់គិតថាគួរតែមានសិក្ខាសាលាបែបនេះច្រើនដង។»*

(កិច្ចសម្ភាសន៍ សុង សេង)

ទស្សនិកជនចង់ឃើញព្រឹត្តិការណ៍ច្រើនទៀតអំពីប្រធានបទនេះនៅពេលអនាគត ពួកគេយល់ថាពួកគេបានយល់ដឹងច្រើនអំពីសុខភាពផ្លូវចិត្តនៅក្នុងរបៀបវិជ្ជមាន។ ពួកគេយល់ឃើញថា មានប្រយោជន៍ចំពោះ *«ការយល់ដឹងបច្ចេកទេសអំពីរបៀបមើលថែខ្លួនឯង»* *(កិច្ចសម្ភាសន៍ខ្លីជាមួយទស្សនិកជន)* និងទទួលបានកម្លាំងចិត្ត។

ជាងនេះទៅទៀត កិច្ចសម្ភាសន៍ខ្លីៗជាច្រើនជាមួយទស្សនិកជន សារនៅលើដើមឈើ និងកិច្ចសម្ភាសន៍ជាមួយអ្នកស្ម័គ្រចិត្ត បានរៀបរាប់របៀបដែលគ្រាន់តែការមើលសិល្បៈក៏ជាទម្រង់នៃការចូលរួមនិងលើកកម្ពស់ដែរ ដោយសារសកម្មភាពនោះនាំពួកគេទៅចាប់អារម្មណ៍កាន់តែខ្លាំងក្នុងសិល្បៈ ហើយការចូលរួមនេះឯងបានជួយគាំទ្រសិល្បករ៖

*យើងត្រូវចែករម្លែក ថែរក្សា និងផ្សព្វផ្សាយចំណេះដឹងអំពីសិល្បៈនិងវប្បធម៌ដើម្បីឱ្យវានៅយូរអង្វែង។ ខ្ញុំចង់ឃើញការចែករម្លែកនិងការចូលរួមបន្ថែមទៀត ការពាក់ព័ន្ធកាន់តែច្រើន។ ការចូលរួម ការស្ម័គ្រចិត្ត ការតែងនិពន្ធនិងផ្សព្វផ្សាយសំណេរអំពីសិល្បៈ។ ប៉ុន្តែជាទូទៅ ការផ្សព្វផ្សាយតាមរយៈបណ្តាញសង្គម។*
*(ដើមឈើសារបំណង)*

ការផ្សព្វផ្សាយតាមរយៈការចែកចាយលើបណ្តាញសង្គមអំពីព្រឹត្តិការណ៍នេះក៏ច្រើនតែឃើញនៅក្នុងកិច្ច សម្ភាសន៍ខ្លីៗជាមួយទស្សនិកជន និងក្រុមអ្នកស្ម័គ្រចិត្តថាជាមធ្យោបាយសំខាន់មួយនៃការចូលរួមក្នុងសិល្បៈដែរ ដោយការផ្សព្វផ្សាយព័ត៌មាននិងការលើកកម្ពស់ការយល់ដឹងអំពីព្រឹត្តិការណ៍សិល្បៈ។ ក្រុមអ្នកឆ្លើយតបនិយាយថាពួកគេនឹង *«ចំណាយពេលបន្ថែមទៀត»* *(កិច្ចសម្ភាសន៍ខ្លីជាមួយទស្សនិកជន)* សម្រាប់សិល្បៈ បើទោះបីបន្តិចបន្តួចក្តី ប៉ុន្តែពួកគេមានគំនិតថ្មីអំពីសិល្បៈនិងតម្លៃនៃសិល្បៈ ដោយសារពួកគេបានចូលរួមមហោស្រពនេះ។ ហេតុដូច្នេះហើយ ការភពប្រសព្វនឹងសិល្បៈ ពិតជាបានជួយជំរុញឱ្យមានការចូលរួមទាំងក្នុងពេលភ្លាមៗ និងក្នុងពេលអនាគតទៀតបាន។







# ការយល់ដឹងអំពីសិល្បៈ

ក្នុងការគិតបន្ថែមទៀតអំពីឥទ្ធិពលនៃការចូលរួម ចំណុចដែលគួរគូសបញ្ជាក់មួយទៀតគឺថាជាទូទៅ តាំងពីទស្សនិកជនរហូតដល់ក្រុមអ្នកហាត់ការ មហោស្រពនេះបានជួយយុវជនជាច្រើនឱ្យយល់ដឹងកាន់តែច្រើនអំពីសិល្បៈ។ តាមពិត នេះជាហេតុផលសំខាន់ដែលក្រុមអ្នកស្ម័គ្រចិត្តដាក់ពាក្យមកជួយ គឺពួកគេចង់ឃើញសិល្បៈកាន់តែច្រើន ដើម្បីយល់ដឹងបន្ថែមអំពីសិល្បៈ ដោយសារភាពថា*«សូម្បីតែនិស្សិតសិល្បៈក៏មិនមានចំណេះដឹងទូលំទូលាយអំពីសិល្បៈដែរ»* *(កិច្ចសម្ភាសន៍ខ្លីជាមួយអ្នកស្ម័គ្រចិត្ត)*។ ទស្សនិកជននិងអ្នកស្ម័គ្រចិត្តជាច្រើន(ហើយមិនមានអ្នកហាត់ការក្នុងនោះទេ) បញ្ចេញយោបល់អំពីរបៀបដែលពួកគេមិនធ្លាប់បានឃើញការអាននៅឆាកពីមុនមកទេ។ ពួកគេធ្លាប់ឃើញល្ខោននិយាយប៉ុន្តែមិនដែលឃើញការអាននៅលើឆាកទេ។ បន្ទាប់ពីទស្សនីយភាពនៃការអានលើឆាក«កូនមើលហ្នំ! ឥន្ទធនូស្អាតណាស់!» ទស្សនិកជនម្នាក់សួរត្រង់ៗរកចំណុចខុសគ្នានៅក្នុងវគ្គសំណួរ-ចម្លើយ ដោយប្រើប្រាស់ឱកាសនោះដើម្បីប្រាស្រ័យទាក់ទងជាមួយសិល្បករ ក្នុងគោលបំណងស្វែងយល់បន្ថែមទៀតដោយខ្លួនឯង (ហើយបើពង្រីកទៅ គឺមនុស្សគ្រប់គ្នា)។



# ការបង្កើតបណ្តាញ និងសហគមន៍ពីនានាភាព

របៀបសំខាន់មួយទៀតដែលមហោស្រពនេះបង្កើតលំហសម្រាប់ការចូលរួមរបស់ពលរដ្ឋក្នុងរបៀបដែលមានឥទ្ធិពលលើយុវជនគឺតាមរយៈការផ្តោតនៃមហោស្រពនេះលើការបង្កើតបណ្តាញ និងសហគមន៍ពីនានាភាព។ នៅក្នុងកិច្ចពិភាក្សាជាមួយក្រុមអ្នកជំនាញ ជាពិសេសអំពីយុវជន សិល្បៈ និងការអភិវឌ្ឍសង្គម វាគ្មិនជាច្រើនមកពីផ្នែកផ្សេងៗគ្នា (រួមទាំងមកពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ) បានជំរុញទឹកចិត្តយុវជនឱ្យទទួលស្គាល់សារៈសំខាន់នៃសិល្បៈនិងការអភិរក្សវប្បធម៌៖

> *«ខ្ញុំទទួលបានការជំរុញចិត្តពីមនុស្សដែលធ្វើការក្នុងវិស័យសិល្បៈមិនឱ្យបោះបង់មរតកវប្បធម៌ចោល និងលើកកម្ពស់/អភិរក្សវប្បធម៌។ សិល្បៈអាចដាស់សម្បជញ្ញៈរបស់យុវជន រារាំងពួកគេមិនឱ្យភ្លេចអត្តសញ្ញាណជាតិខ្មែរ ដែលដូនតារបស់យើងបានប្រឹងប្រែងថែរក្សា។ នៅពេលពួកគេចូលរួម ពួកគេអាចយល់ដឹងនិងភ្ញាក់រឭក ហើយបើនៅក្នុងករណីរបស់ខ្ញុំវិញ ខ្ញុំមិនបានសិក្សា ឬយល់ដឹងច្រើនអំពីសិល្បៈពីមុនមកទេ ប៉ុន្តែក្រោយពីចូលរួមមក ខ្ញុំបានដឹងសារៈសំខាន់និងតម្រូវការ។»*
>
> (កិច្ចសម្ភាសន៍ខ្លីជាមួយអ្នកចូលរួមសិក្ខាសាលា)

ទស្សនិកជនមួយចំនួនបានផ្តល់តម្លៃដល់ទស្សនៈពីក្រសួងវប្បធម៌ និងចាត់ទុកទស្សនៈនេះថាជាការឆ្លើយតប«ត្រឹមត្រូវ» ជាពិសេសទាក់ទងនឹងការលើកកម្ពស់វប្បធម៌និងអត្តសញ្ញាណខ្មែរ។ ទោះបីអ្នកទៅមើលសិល្បៈដែលមានបទពិសោធន៍ច្រើននិយាយថាការពិភាក្សាបែបនោះជា *«រឿងធម្មតាប៉ុន្តែមានតម្លៃ»* (កិច្ចសម្ភាសន៍ខ្លីជាមួយទស្សនិកជន) ក៏ពួកគេកោតសរសើរការសង្កត់ធ្ងន់លើការគិតល្អិតល្អន់ចំពោះយុវជនក្នុងទំនាក់ទំនងជាមួយសិល្បៈនិងគោលបំណងរបស់ពួកគេ។ ទោះជាយ៉ាងណា រឿងសំខាន់ដែលត្រូវកត់សម្គាល់គឺថាទស្សនិកជនជាច្រើនយល់ថាមហោស្រពនេះបានបង្កើត«លំហសុវត្ថិភាព»មួយជាកន្លែងដែលមនុស្សអាចបញ្ចេញទស្សនៈចម្រុះ៖

> *«ចំពោះខ្ញុំ អ្វីដែលខ្ញុំសប្បាយបំផុតគឺខ្ញុំអាចមើលឃើញយុវជនខ្មែរយើងមានគំនិតផ្ទាល់ខ្លួនឯង ដូចជាការបង្ហាញអំពីខ្លួនឯង និងនិយាយក្នុងទីសាធារណៈ។ វាអាចជាចំណុចចាប់ផ្តើមសម្រាប់ខ្មែរយើងដើម្បីអាចឈរលើឆាកអន្តរជាតិតាមរយៈការនិយាយចេញក្នុងទីសាធារណៈដោយមិនភ័យខ្លាច។ អ្វីក៏ដោយដែលពួកគេចង់និយាយ គេអាចនិយាយបាននៅទីនេះ។»*
>
> កិច្ចសម្ភាសន៍ខ្លីជាមួយទស្សនិកជន)
>
> *«ព្រឹត្តិការណ៍នេះធ្វើឱ្យខ្ញុំមិនមានសម្ពាធអ្វីទាំងអស់។ ខ្ញុំអាចនិយាយដោយមិនខ្លាចសូម្បីតែយោបល់ដែលមិនអាចបញ្ចេញបាននៅក្នុងកន្លែងខ្លះទៀតក៏ដោយ។ ប៉ុន្តែនៅទីនេះបន្ទាប់ពីខ្ញុំនិយាយរួចខ្ញុំមានអារម្មណ៍ដូចមានគេស្តាប់ឮខ្ញុំ។រឿងសំខាន់បំផុតចំពោះបុគ្គលម្នាក់គឺមានគេស្តាប់សម្តីដែលបញ្ចេញមក។»*
>
> (កិច្ចសម្ភាសន៍ខ្លីជាមួយទស្សនិកជន)

ទស្សនិកជនមិនមានអារម្មណ៍ថាមាននរណាវិនិច្ឆ័យទេ ហើយពួកគេរីករាយក្នុងការយល់ដឹងបន្ថែមអំពីទស្សនៈរបស់អ្នកដទៃ។ ទាក់ទងនឹងទិដ្ឋភាពនេះ ទស្សនៈរបស់រដ្ឋាភិបាលអំពីតួនាទីនៃសិល្បៈ វប្បធម៌ និងការអភិវឌ្ឍជាតិ ឬមោទនភាពជាតិ ត្រូវគេបង្ហាញនិងចូលរួម ប៉ុន្តែនោះជាសំឡេងមួយក្នុងចំណោមការចូលរួមប្រកបដោយអត្ថន័យនិងការពិចារណាជាច្រើនទៀត។ នៅក្នុងផ្នែកនេះ មហោស្រពនេះបានបង្កើតលំហមួយសម្រាប់ការចូលរួមស៊ីវិលរវាងសិល្បករនិងទស្សនិកជន ជាកន្លែងមួយដែលបានជំរុញពួកគេឱ្យគិតប្រកបដោយអត្ថន័យអំពីតួនាទីនៃសិល្បៈក្នុងសង្គម។ ដូចទស្សនិកជនម្នាក់លើកឡើងថា វាជា *«ការបណ្តុះសម្បជញ្ញៈ»* *(កិច្ចសម្ភាសន៍ខ្លីជាមួយទស្សនិកជន)* ពោលគឺទស្សនិកជនមានអារម្មណ៍ថាមហោស្រពនេះលើកឡើងបញ្ហាដែលយុវជន«គួរតែ»គិតនិងខ្វល់ខ្វាយ ជំរុញពួកគេឱ្យរៀននិងទទួលចំណេះដឹង ហើយក្នុងពេលជាមួយគ្នានោះដែរ ក៏បានលើកប្រធានបទដែលឆ្លុះបញ្ចាំងកង្វល់យុវជនបច្ចុប្បន្ននេះដែរ។ ចំណុចនេះទទួលបានការបញ្ជាក់កាន់តែច្បាស់តាមរយៈរបៀបដែលទស្សនិកជននិងក្រុមអ្នកស្ម័គ្រចិត្តជាច្រើននាក់នៅក្នុងកិច្ចសម្ភាសន៍ខ្លីៗលើកឡើងអំពីរបៀបដែល *«មនុស្សម្នាក់ៗមានស្មារតីសាមគ្គី»* *(កិច្ចសម្ភាសន៍ខ្លីជាមួយទស្សនិកជន)* ហើយរបៀបដែលយុវជនអាច *«ភ្ជាប់ទំនាក់ទំនងគ្នាទៅវិញទៅមក»* *(កិច្ចសម្ភាសន៍ខ្លីជាមួយទស្សនិកជន)* ដោយគូសបញ្ជាក់របៀបនៃការចូលរួមក្នុងសិល្បៈបានបង្កើតអារម្មណ៍នៃទំនាក់ទំនងនិងសហគមន៍ដែលគ្របដណ្តប់លើភាពខុសគ្នានិងភាពចម្រុះ។



# សេចក្តីសង្ខេបអំពីការរកឃើញ និងអនុសាសន៍



ការសិក្សានេះផ្តល់កិច្ចពិភាក្សាស៊ីជម្រៅដំបូងគេអំពីរបៀបដែលសិល្បៈទាក់ទងនឹង សង្គម និងរបៀបប្រមូលយុវជនមកចូលរួមក្នុងដំណើការនេះ។ តាមរយៈការផ្តោតលើដំណើរនៃការរៀបចំនិងផលិតមហោស្រព៧ពណ៌នៅក្នុងខែធ្នូ ឆ្នាំ២០២៣ វាបានជំរុញឱ្យមានការផ្តោតល្អិតល្អន់លើរបៀបនៃការភ្ជាប់យុវជននឹងសិល្បៈអាចលើកកម្ពស់ធាតុស្នូលនៃការចូលរួមរបស់ពលរដ្ឋក្នុងសង្គម តាមរយៈបំណិននៃការចរចានិងការសម្រេចចិត្ត ការបង្កើតកិច្ចពិភាក្សាពីភាពចម្រុះ ការលើកកម្ពស់ដល់ការស្ម័គ្រចិត្តនិងភាពជាម្ចាស់ការរួម ព្រមទាំងការពិចារណាដល់របៀបផ្សេងៗនៃការចូលរួមរបស់យុវជនក្នុងសិល្បៈ (ពោលគឺតាមរយៈការរៀន ការមើល ការចូលរួមផ្ទាល់ក្នុងសកម្មភាព ការផ្តល់សកម្មភាពសម្រាប់បង្ហាញខ្លួនឯង ការបោះឆ្នោតលើបណ្តាញសង្គម)។ ការសិក្សានេះក៏ពិនិត្យមើលភាពតានតឹងជុំវិញសកម្មភាពនិងដំណើរការទាំងអស់នេះដែរ ដោយការគូសបញ្ជាក់បញ្ហាលំបាកក្នុងការកសាង «ភាពជាម្ចាស់ការ» និងថាមវន្តភាពជាក្រុម ក៏ដូចជាកង្វះគោលដៅច្បាស់លាស់ជុំវិញប្រភេទនៃការចូលរួមដែលចង់បានឬត្រូវការ និងរបៀបដែលមហោស្រពនេះអាចនឹងមានភាពផ្សេងគ្នានៅក្នុងក្រុមមនុស្សខុសគ្នា (ហួសពីយុវជនជាទូទៅ)។ ការស្រាវជ្រាវនេះក៏បានរុករកភាពល្មៀងគ្នានៅជុំវិញការចូលរួមស៊ីវិលដែរ ជាពិសេសកិច្ចពិភាក្សាអំពីបរិមាណឬគុណភាព និងមធ្យោបាយផ្សេងៗដែលសិល្បៈអាចភ្ជាប់ទៅនឹងសង្គម។

នៅក្នុងកម្រិតមួយ មហោស្រពនេះនិងសកម្មភាពសិល្បៈទាំងឡាយដែលមហោស្រពនេះបង្ហាញជូនមានទំនាក់ទំនងដោយផ្ទាល់ទៅនឹងសង្គម តាមរយៈគោលបំណងនៃមហោស្រព និងជម្រើសកម្មវិធីដែលបង្កើតឡើងជាបន្តបន្ទាប់។ ក្រុមអ្នកហាត់ការបានជ្រើសរើសការសម្តែងយ៉ាងច្បាស់ ការអានលើឆាកឬការអានបែបច្នៃប្រតិដ្ឋ ដោយលើកឡើងបញ្ហាក្នុងសង្គមដែលពួកគេចាប់អារម្មណ៍ក្នុងនាមជាយុវជន ហើយដែលបង្កប់គុណតម្លៃស្នូលនៃភាពចម្រុះនិងសមភាពរបស់ពួកគេ។ ផ្នែកនេះមានតាំងពីការសម្តែងដែលលើកឡើងអំពីសិទ្ធិស្ត្រីទៅដល់សមភាពនិងការបង្ហាញអំពីខ្លួនឯង ការទទួលស្គាល់ក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ការរុកកួនតាមអ៊ីនធឺណិត និងលទ្ធផលនៃការបើកបរក្នុងភាពស្រវឹង។ ក្រុមអ្នកហាត់ការក៏បានបង្កើតកម្មវិធីមួយដែលជាទូទៅបានជំរុញមនុស្សពីក្រុមផ្សេងគ្នាមកចូលរួម បង្ហាញអំពីខ្លួនពួកគេ និងតំណាងឱ្យក្រុមភាគតិច ជាពិសេសនៅក្នុងកម្មវិធីការដើរបង្ហាញម៉ូដ។ ពេលខ្លះក៏មានសកម្មភាពនិងការសម្តែងបែបនេះដែលបានបង្ហាញដោយផ្ទាល់នូវបំណងចង់បានសិទ្ធិស្មើគ្នា ជាពិសេសសម្រាប់ស្ត្រី។ សកម្មភាពដូចជាការច្រៀងចម្រៀងអំពីគោលដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ កិច្ចពិភាក្សាប្រកបដោយអត្ថន័យអំពីសិល្បៈនិងការអភិវឌ្ឍសង្គម និងអំពីសិល្បៈនិងសុខភាពផ្លូវចិត្ត ក៏បានអនុញ្ញាតឱ្យមហោស្រពនេះបង្កើតបាននូវបទពិសោធន៍នៃការចែករំលែករួមគ្នាមួយដែលមានតម្លៃសម្រាប់សង្គម។ កាន់តែសំខាន់ទៀតនោះគឺមហោស្រពនេះអាចបង្កើតលំហរួមនិងមានសុវត្ថិភាពជាកន្លែងដែលអាចបញ្ចេញទស្សនៈផ្សេងគ្នាដោយមិនមានការវិនិច្ឆ័យ។ ត្រង់ចំណុចនេះ ចំណុចសំខាន់ដែលគួរកត់សម្គាល់នោះគឺថាក្នុងពេលដែលកិច្ចពិភាក្សាជាច្រើនអំពីសិល្បៈក្នុងប្រទេសកម្ពុជារៀបចំឡើងស្របតាមគោលនយោបាយរបស់រដ្ឋាភិបាលអំពីជាតិសាសនានិងអត្តសញ្ញាណ នេះគ្រាន់តែជាទស្សនៈមួយក្នុងចំណោមទស្សនៈជាច្រើនដែលបង្ហាញនៅក្នុងមហោស្របនេះ។ តាមពិត មហោស្រព៧ពណ៌បានរៀបចំឱ្យមានការជួបប្រសព្វសិល្បៈនិងកិច្ចពិភាក្សាយ៉ាងជោគជ័យ ដោយសារវាបានភ្ជាប់ទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងកង្វល់របស់យុវជនក្នុងសង្គមស៊ីវិល និងរៀបចំឡើងក្នុងកម្រិតឆ្ងាយបន្តិចពីរដ្ឋាភិបាល។

ជាងនេះទៅទៀត កម្មវិធីមហោស្រពនេះបានអនុញ្ញាតឱ្យមានបែបផែនផ្សេងៗនៃការចូលរួម តាំងពីការត្រឹមតែសប្បាយនឹងការរៀនរាំឬគូររូប ហើយក្នុងពេលជាមួយគ្នាក៏បានឃើញកិច្ចពិភាក្សាប្រកបដោយអត្ថន័យនិងកាន់តែស៊ីជម្រៅអំពីទំនាក់ទំនងរវាងសិល្បៈនិងសង្គម។ កម្មវិធីខ្លីៗដែលរៀបចំឡើងមានលក្ខណៈឆ្លើយឆ្លងគ្នាត្រូវគេមើលឃើញថាមានភាពទាក់ទាញនិងងាយស្រួលចូលរួមពីទស្សនិកជន និងផ្តល់នូវច្រកចូលមួយសម្រាប់ការយល់ដឹងបន្ថែមទៀតអំពីសិល្បៈនិងបញ្ហាសង្គមដែលសំខាន់ចំពោះយុវជន។ ទោះជាយ៉ាងណា គេមិនអាចសន្និដ្ឋានថាមនុស្សជាច្រើនដែលមើលការសម្តែងទាំងនោះជារបៀបចូលរួមក្នុងសង្គមស៊ីវិលដែលមិនសូវមានអត្ថន័យបើប្រៀបនឹងមនុស្សចំនួនតិចចូលរួមក្នុងសិក្ខាសាលានោះទេ។ យុវជនមើលឃើញការយល់ដឹងអំពីសិល្បៈថាមានសារៈសំខាន់ចំពោះវប្បធម៌ សង្គម និងអត្តសញ្ញាណជាតិ ហើយការភពប្រសព្វនឹងទម្រង់សិល្បៈផ្សេងៗជួយចិញ្ចឹមគំនិតចង់ចេះចង់ដឹងរបស់ពួកគេ។ ការទស្សនាការសម្តែងថ្មីៗក៏បានជំរុញទឹកចិត្តយុវជនឱ្យគិតអំពីបញ្ហាសង្គមដែរ ហើយប្រហែលនាំពួកគេទៅសកម្មភាពសិល្បៈនិងសកម្មភាពសង្គមស៊ីវិលបន្ថែមទៀតផង។ តាមពិត ក្រុមអ្នកហាត់ការនិងក្រុមអ្នកស្ម័គ្រចិត្តសុទ្ធតែជាយុវជនដែលចង់បានបទពិសោធន៍ថ្មីៗ ចង់បង្កើតភាពប្លែកនិងចូលរួមក្នុងរបៀបខ្លះ។ មហោស្រពនេះលើកទឹកចិត្តពួកគេបន្ថែមទៀតក្នុងផ្លូវនេះ ជាពិសេសក្នុងទំនាក់ទំនងជាមួយសិល្បៈ។ ការសូនរូបដីឥដ្ឋ ការនិពន្ធទំនុកចម្រៀង និងការគូររូបក៏មានលក្ខណៈចូលរួមដែរនិងអនុញ្ញាតឱ្យយុវជនបង្ហាញខ្លួនឯងក្នុងរបៀបច្នៃប្រតិដ្ឋ ប្រហែលក្នុងរបៀបដែលពួកគេមិនធ្លាប់បានធ្វើបែបនោះពីមុនមកទេ។ ត្រង់ចំណុចនេះមិនមែនគ្រប់ទម្រង់នៃការចូលរួមសុទ្ធតែភ្ជាប់សិល្បៈទៅនឹងសង្គម នោះទេ ប៉ុន្តែវាបានអនុញ្ញាតឱ្យយុវជនបង្ហាញខ្លួនពួកគេ ហើយការខុសប្លែកនេះក៏ធ្វើឱ្យមហោស្រពមានលក្ខណៈគួរឱ្យចាប់អារម្មណ៍និងសប្បាយដែរ។ បន្ថែមពីលើនេះ ការអំពាវនាវឱ្យមានការប្រកួតរូបថត និងការប្រកួតទេពកោសល្យបានជួយមនុស្សគ្រប់គ្នាឱ្យដាក់ស្នាដៃចូលរួម និងបោះឆ្នោត ចែករំលែកនិងពិភាក្សា ដែលសុទ្ធតែជាសកម្មភាពសមូហភាពចាំបាច់ក្នុងការលើកកម្ពស់សង្គម មួយប្រកបដោយភាពរីកចម្រើន។



ដូច្នេះហើយ មហោស្រពនេះបានលើកកម្ពស់បំណិនដែលត្រូវការសម្រាប់ការចូលរួមស៊ីវិល ជាពិសេសសម្រាប់ក្រុមអ្នកហាត់ការ ដែលត្រូវហ្វឹកហាត់ការចរចាការសម្របសម្រួល ការទូត ការគោរព និងទំនួលខុសត្រូវរួម។ មានបញ្ហាខ្លះជុំវិញភាពជាអ្នកដឹកនាំ និងបញ្ហាខ្លះក្នុងការបង្កើតឱ្យមាន«ភាពជាម្ចាស់ការ»រវាងក្រុមអ្នកហាត់ការ និងអង្គការសិល្បៈខ្មែរអមតៈ ដែលឆ្លុះបញ្ចាំងវិសមភាពក្នុងវ័យ បទពិសោធន៍ ហើយឥទ្ធិពលទៀតផង។ ប៉ុន្តែក្រុមអ្នកហាត់ការបានទទួលសេរីភាពច្រើនក្នុងការសម្រេចចិត្តដែលអនុញ្ញាតឱ្យពួកគេធ្វើជាម្ចាស់ការរួមនៃព្រឹត្តិការណ៍នេះ បើទោះបីមានសម្ពាធថវិកាដែលបានរាំងស្ទះដល់មហិច្ឆតារបស់ពួកគេក៏ដោយ។ ការជជែកដេញដោលនិងការខ្វែងគំនិតគ្នាដែលកើតឡើងក៏អាចចាត់ទុកជាការឆ្លុះបញ្ចាំងលើបញ្ហាកាន់តែធំទៀតដែលមានបង្ហាញតាំងពីពេលចាប់ផ្ដើមនៅជុំវិញទំនួលខុសត្រូវរបស់ខាងណាក្នុងការផ្សព្វផ្សាយនិងការទាក់ទាញយុវជនឱ្យចូលរួមក្នុងសិល្បៈ នៅក្នុងរបៀបណាខ្លះ និងដើម្បីទៅដល់គោលដៅណាខ្លះ។ ទស្សនិកជនក្នុងមហោស្រពនេះតែងតែផ្ដល់យោបល់ថាជាទំនួលខុសត្រូវរបស់យុវជនខ្លួនឯងដែលត្រូវស្វែងរកបន្ថែមទៀតគាំទ្រសិល្បៈ និងចែករម្លែកព័ត៌មានអំពីសិល្បៈ។ ប៉ុន្តែមិនមែនមនុស្សគ្រប់គ្នាចូលរួមក្នុងរបៀបដូចគ្នាទេ (ជាក់ស្ដែងមានអ្នកស្ម័គ្រចិត្តដែលមកយឺតពេលជាដើម) ប៉ុន្តែក្រុមអ្នកហាត់ការមានកង្វល់ដូចគ្នាក្នុងការព្យាយាមបង្កើតបរិយាបន្ន និងបើកទូលាយបើទោះបីបំណងនេះមិនសូវទទួលបានជោគជ័យក៏ដោយ។ សំណួរមួយដែលមិនព្រមរលាយបាត់នោះគឺថាតើព្រឹត្តិការណ៍បែបនេះលើកកម្ពស់ដល់ការចូលរួមតែម្ដងឬការចូលរួមយូរអង្វែងក្នុងសិល្បៈនិងសង្គមប៉ុន្តែច្បាស់ណាស់ថាមានការចង់បានសកម្មភាពចូលរួមបែបនេះបន្ថែមទៀតក្នុងចំណោមយុវជន។

# អនុសាសន៍

- មហោស្រពនេះបានក្លាយជាព្រឹត្តិការណ៍កាន់តែធំមួយ ប្រហែលធំជាងការស្រមៃឬអាចគ្រប់គ្រងបានទៅទៀត។ អាចមានការពិចារណាបន្ថែមទៀតចំពោះការបង្កើតព្រឹត្តិការណ៍ប្រភេទនេះ និងជំហានដែលត្រូវការដើម្បីជួយសម្រួលដល់ការចូលរួមរបស់ក្រុមអ្នកហាត់ការ។

- ការរំពឹងទុកកាន់តែច្បាស់លទ្ធផលអ្វីខ្លះដែលចង់សម្រេចបាន និងប្រភេទនៃការចូលរួមដែលចង់ឱ្យមាន នឹងជួយបង្កើតរចនាសម្ព័ន្ធដំណើរការរួមនិងបង្កើត«ភាពជាម្ចាស់ការ»ពីមនុស្សគ្រប់គ្នា។ សូចនាករកាន់តែប្រសើរដើម្បីបញ្ជាក់ចំណុចអ្វីខ្លះថាជោគជ័យនឹងជួយពង្រឹងការផ្តោតនៃកម្មវិធី និងការវាយតម្លៃកម្រិតជោគជ័យនៃព្រឹត្តិការណ៍ ឧទាហរណ៍ តើការចូលរួមដោយជោគជ័យផ្អែកលើចំនួនទស្សនិកជន ឬជម្រៅនិងភាពលម្អិតនៃចំណេះដឹងដែលទស្សនិកជនទទួលបាន? តើការចូលរួមដោយជោគជ័យមានលក្ខណៈដូចម្តេចចំពោះក្រុមផ្សេងទៀត (ពោលគឺ ក្រុមអ្នកហាត់ការ ក្រុមអ្នកស្ម័គ្រចិត្ត ក្រុមបុគ្គលិកអង្គការសិល្បៈខ្មែរអមតៈ និងក្រុមទស្សនិកជន)?

- សមាសភាពនៃក្រុមអ្នកហាត់ការតម្រូវឱ្យមានការពិចារណាបន្ថែមទៀត ជាពិសេសការរក្សានៅត្រឹមកម្រិតទីក្រុងដើម្បីបង្កលក្ខណៈឱ្យមានការចូលរួមកាន់តែប្រសើរ។ ទោះជាយ៉ាងណាក៏មិនគួរមើលរំលងបណ្តាខេត្តនោះទេ។ ប្រហែលប្រសើរជាងនេះបើផ្តល់បទពិសោធន៍នេះដល់សហគ្រិនសិល្បៈវ័យក្មេងដែលមានចំណេះដឹងនិងបទពិសោធន៍ខ្លះស្រាប់ ប៉ុន្តែជាអ្នកដែលអាចប្រើប្រាស់មហោស្រពនេះដើម្បីអភិវឌ្ឍជំនាញ និងសមត្ថភាពរបស់ពួកគេក្នុងវិស័យនេះ។ ជម្រើសមួយទៀត ក្រុមចម្រុះនៃសិល្បករនិងមនុស្សដែលមិនមែនជាសិល្បករនឹងបង្កើតបានកិច្ចសហការ គំនិត និងមធ្យោបាយថ្មីនៃការធ្វើការ ដោយសារក្រុមហាត់ការមានគំនិតប្លែក និងជោគជ័យសម្រាប់ការភ្ជាប់សិល្បៈជាមួយបញ្ហាសង្គម ការប្រមូលយុវជនមកចូលរួម និងការឆ្លុះបញ្ចាំងកង្វល់របស់យុវជនក្នុងសង្គមស៊ីវិល។

- កម្មវិធីបណ្តុះបណ្តាលដែលមានរចនាសម្ព័ន្ធកាន់តែច្បាស់លាស់ អំពីសិល្បៈនឹងផ្តល់ឱ្យក្រុមអ្នកហាត់ការនូវការតម្រង់ទិសកាន់តែរឹងមាំ និងជួយពួកគេឱ្យសម្រេចចិត្តបានកាន់តែមានប្រសិទ្ធភាព។ ត្រូវមានការចូលរួមដោយផ្ទាល់កាន់តែច្រើនក្នុងសិល្បៈសម្រាប់អ្នកដែលមិនមានចំណេះដឹងមូលដ្ឋានរឹងមាំ។ ការជួបជុំនិងការប្រាស្រ័យដោយផ្ទាល់មានប្រសិទ្ធភាពបំផុតក្នុងការរុញច្រានការអភិវឌ្ឍមហោស្រពនេះឆ្ពោះទៅមុខ ដើម្បីការចែករំលែកចំណេះដឹងនិងបទពិសោធន៍ និងដើម្បីការពិភាក្សាគំនិត។ ក្រុមអ្នកហាត់ការផ្តល់យោបល់ថាការជួបជុំដោយផ្ទាល់គួរតែធ្វើឡើង ជាប្រចាំដើម្បីរក្សាសាមគ្គីភាពក្នុងក្រុមឬ«ស្មារតីជាក្រុម»។

- ក្រុមអ្នកហាត់ការបានរៀនសូត្រច្រើនអំពីសិល្បៈ អភិវឌ្ឍជំនាញថ្មីៗ និងភ្ជាប់ទំនាក់ទំនងរវាងសិល្បៈនិងបញ្ហាសង្គម។ ទោះជាយ៉ាងណា ប្រភេទនៃការចូលរួមដែលបង្កើតឡើងនេះមានលក្ខណៈចម្រុះគ្នា ហើយមានតុល្យភាពរវាងបរិមាណនិងគុណភាពនៃការចូលរួមជាមួយនឹងបញ្ហាសង្គម។

- ការចូលរួមអាចពាក់ព័ន្ធនឹងការបង្កើនកម្រិតយល់ដឹងបញ្ហាសំខាន់ៗ ដែលយុវជនវ័យក្មេងកំពុងប្រឈម ហើយមហោស្រពនេះបានប្រើប្រាស់សិល្បៈដើម្បីឆ្លើយតបនឹងគំនិតនេះ។ មហោស្រពនេះក៏ទទួលបានជោគជ័យខ្លាំងដែរក្នុងការអភិវឌ្ឍជំនាញ និងលើកកម្ពស់លំហសុវត្ថិភាពនៃការពិភាក្សាគ្នាជាមួយនឹងសំឡេងចម្រុះ។

- មានការរំពឹងចង់បានអ្វីខ្លះនិងព្រំដែនបែបណាខ្លះចំពោះសិល្បៈ តើគេគួរតែលើកកម្ពស់ការគៀរគរមតិឬទេ? ការណ៍នេះប្រហែលមិនអាចទៅរួចទេនៅក្នុងបរិបទបច្ចុប្បន្ននេះ(ជាក់ស្តែង ក្រុមអ្នកហាត់ការបានដកគំនិតរបស់ពួកគេពាក់ព័ន្ធនឹងការធ្វើការដោយផ្ទាល់ជាមួយនឹងអង្គការដែលធ្វើការលើរឿងសិទ្ធិមនុស្សដោយផ្ទាល់។ បន្ទាប់ពីពិចារណារួចមក ពួកគេយល់ថាមិនមានសុវត្ថិភាពចំពោះពួកគេចំពោះអង្គការនិងសិល្បករផងដែរ)។

- កញ្ចប់ថវិកាកាត់តែធំ ការចូលរួមពីបណ្តាញផ្សព្វផ្សាយកាន់តែប្រសើរ និងវិធីសាស្ត្រផ្សព្វផ្សាយថ្មីៗ (ដូចជាការសហការជាមួយនឹងបុគ្គលមានឥទ្ធិពលលើបណ្តាញសង្គម ការប្រើប្រាស់យុវជនដើម្បីបង្កើតនិងចែកចាយមាតិកា) គួរតែយកមកពិចារណា។ មនុស្សគ្រប់គ្នាក្នុងក្រុមរៀបចំមហោស្រពនេះលើកឡើងអំពីបញ្ហាក្នុងការអញ្ជើញក្រុមសិល្បករមកសម្តែងក្នុងកញ្ចប់តម្លៃដែលពួកគេមាន ហើយក៏មិនស្របនឹងតម្លៃពេលវេលារបស់សិល្បករទាំងនោះដែរ។

- នៅមិនច្បាស់ទេថាក្រុមអ្នកហាត់ការនឹងទៅណាទៀតបន្ទាប់ពីនេះ ដំណើរការនេះបានបង្កើតសមត្ថភាពរបស់ពួកគេក្នុងទិដ្ឋភាពខ្លះប៉ុន្តែនៅខ្វះផ្នែកជាច្រើនទៀត។ ក្រុមអ្នកហាត់ការនេះមានភាពសកម្មណាស់ក្នុងការងារស្ម័គ្រចិត្ត ដូច្នេះតើជារឿងមួយ«ផ្សេងទៀត»ឬជាតួនាទីកាន់តែធំជាងនេះបន្តិចទេនៅក្នុងប្រវត្តិបទពិសោធន៍ការងាររបស់ពួកគេ? ដំណើរការនេះមិនបានបង្កើតសមត្ថភាពក្នុងវិស័យសិល្បៈទេ ហើយក៏មិនបានលើកទឹកចិត្តពេញលេញឱ្យវិស័យនេះគិតហ្មត់ចត់អំពីទំនាក់ទំនងរវាងសិល្បៈ និងការអភិវឌ្ឍសង្គមឱ្យហួសពីកម្រិតទទួលយករបស់ទស្សនិកជននោះទេ។ ទោះជាយ៉ាងណា ក្រុមអ្នកហាត់ការមានគំនិតថ្មីៗនិងបានបង្កើតកម្មវិធីចែករំលែកចំណេះដឹង ដែលគួរឱ្យចាប់អារម្មណ៍ចំពោះវិស័យនេះ។

- ក្រុមអ្នកហាត់ការបានផ្តល់យោបល់ឱ្យមានរបៀបបំពេញការងារផ្ទាល់ បន្ថែមទៀតឬការជ្រើសរើសឱ្យធ្វើការកាន់តែប្រសើរនៅកន្លែងដែលពួកគេបំពេញការងារ ក្នុងការិយាល័យអង្គការសិល្បៈខ្មែរអមតៈ និងទទួលបានប្រាក់ខែសមស្របសម្រាប់រយៈពេលនៃការងារ(ពោលគឺ៣រសៀលក្នុងមួយសប្តាហ៍)។ ពួកគេយល់ថាការធ្វើបែបនេះនឹងលើកទឹកចិត្តឱ្យមានការចែករំលែកកាន់តែច្រើននិងការសម្របសម្រួលរវាងគោលដៅនៃមហោស្រពនេះជាមួយនឹងបុគ្គលិកអង្គការសិល្បៈខ្មែរអមតៈ។ ក្នុងនោះដែរក៏មានការផ្តល់យោបល់ឱ្យមានការទទួលស្គាល់កាន់តែច្រើនចំពោះបរិមាណនៃការងារដែលពាក់ព័ន្ធនិងការផ្តល់កម្រៃឱ្យបានសមស្រប។



# References


Breed, A. and Prentki, T. (eds) (2018) *Performance and Civic Engagement*. Basingstoke: Palgrave Macmillan.

Brennert, K. and Yean, R. (2023) Cambodia: *Artistic Freedom Report*. Arts Equator. https://artsequator.com/cambodia-country-report/

Cin, M., Walker, C., Suleymanoglu-Kurum, R., Gunter, A., Dogan, N., Truter, L., Ahimbisibwe, F., Olaniyan, T.C. (2023) Political Participation of Refugee and Host Community Youths: Epistemic Resistance through Artistic and Participatory Spaces. *Journal of Youth Studies* 1–18. https://doi.org/10.1080/13676261.2023.2273346

Cooke, B. and Kathari, U. (2001) Participation: *The new tyranny?* London: Zed Books.

Cooke, P. and Soria-Donlan, I. (eds) (2019) *Participatory arts in international development.* London: Routledge.

Ear, S. (2012) Aid Dependence in Cambodia: How Foreign Assistance Undermines Democracy. New York: Columbia University Press.

Mkwananzi, F., Cin, M.F. and Marovah, T. (2023) Transformative youth development through heritage projects connecting politics, creative and cultural capabilities. *International Journal of Heritage Studies.* 29:581-597.

Öjendal, J. and Lilja, M. (2009) Beyond Democracy in Cambodia: *Political reconstruction in a post-conflict society*. Copenhagen: NIAS Press.

Rogers, A., Yean, R., Keat, S., Hem, V. and Krolikowska, J. (2021). Creative Expression and Contemporary Arts Making Among Young Cambodians. Swansea: Swansea University. https://doi.org/10.23889/sureport.56822,

Rogers, A., Tola, S., Monthary, M., Seyhah, V., & Nicholas, L. (2023). *Cambodian Audience Engagement in the Performing Arts: Cambodian Living Arts 2022 Cultural Season*. Swansea: Swansea University https://doi.org/10.23889/SUreport.65084,

Schröder, P. and Young, S. (2019). *The Implications of Closing Civic Space for Sustainable Development in Cambodia*. Brighton: Institute of Development Studies.

Transparency International (2022) *Cambodian Youth Policy Survey Report.* https://www.ticambodia.org/wp-content/uploads/Cambodian-Youth-Policy-Survey-Report_EN.pdf

Young, S. (2021) Citizens of photography: visual activism, social media and rhetoric of collective action in Cambodia. *South East Asia Research* 29: 53-71

Young, S. (2023) Visual Citizenship in Cambodia—From Apocalypse to Visual "Political Emancipation" In Pinney, C. et al (eds). *Citizens of Photography: The camera and the political imagination*, Durham, Duke University Press, pp. 111-149.